ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber
Chambre de Premiere instance


ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 13-Dec-2011, 09:35
CMS/CFO: Sann Rada


# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះនៅដំណាក់កាលដំបូង

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១១**

**ម៉ោង ០៩: ១១នាទី**

**សវនាការលើកទី៧**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី

លោក ដាន អានសាន

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក អាន់ឌ្រូ ខេលី *(Mr.Andrew CAYLEY)*

លោក វីល្លៀម ស្មីត *(Mr. William SMITH)*

លោក សេង ប៊ុនឃាង

លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក ច័ន្ទ តារាស្មី

លោក ឌេល លីសាក់ *(Mr. Dale LYSAK)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក មៃ៉ខល ផេសមិន

*(Mr. Michiel PESTMAN)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកគែន

*(Mr. Arthur VERCKEN)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក មៃ៉ខល កាណាវាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោកស្រី ម៉ុច សុវណ្ណារី

លោក សំ សុគង់

លោក គឹម ម៉េងឃី

លោក ឡោ ជុនធី

លោក ហុង គឹមសួន

លោក គ្រីស្ទីន ម៉ាទីណូ

*(Mr. Chritine MARTINAU)*

កញ្ញា ហ្វីលីពីន ស៊ុតហ្ស៍

*(Ms. Philipine SUTZ)*

លោក ប៉ាស្កាល់ អូប៊ីង

*(Mr. Pascal AUBOIN)*

លោកស្រី នូស៊ីន សាកាវ៉ាទី

*(Ms. Nushin SAKARATI)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក កូវ កែវរតនៈ

**មន្ត្រីអង្គភាពគាំពារសាក្សី/អ្នកជំនាញ៖**

លោក ញ៉ែម សំណាង

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក ម៉ៃល ផេសមិន | អង់គ្លេស |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក អាង ឧត្តម | ខ្មែរ |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| លោក សុន អរុណ | ខ្មែរ |
| លោក អាកទួរ វែកគែន | បារាំង |
| លោកស្រី នូស៊ីន សាកាវ៉ាទី | អង់គ្លេស |
| លោក ពេជ អង្គ | ខ្មែរ |
| លោក ឡុង នរិន្ទ (TCW-395) | ខ្មែរ |
| លោក ញ៉ែម សំណាង | ខ្មែរ |

## ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី ឡុង នរិន្ទ** (TCW-395)

សួរដោយលោក ឌេល លីសាក់ ផ្តើមពី .................... ទំព័រ០៥
សួរដោយលោក ច័ន្ទ តារាស្មី ផ្តើមពី .................... ទំព័រ៥៥
សួរដោយលោក សំ សុគង់ ផ្តើមពី .................... ទំព័រ៧០
សួរដោយលោកស្រី នូស៊ីន សាកាវ៉ាទី ផ្តើមពី .................... ទំព័រ៨០

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:១១:៥៣]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការសវនាការពិភាក្សាដេញដោល ហើយនៅព្រឹកនេះ អង្គជំនុំជម្រះប្រកាសបន្តនូវការស្តាប់សក្ខីកម្មរបស់សាក្សីមួយរូបតាមប្រព័ន្ធសោតទស្សន៍ ដែលពីម្សិលមិញបានធ្វើ ប៉ុន្តែមិនទាន់ចប់។

មុននឹងផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញា អង្គជំនុំជម្រះសូមជម្រាបជូនទៅអង្គភាពគាំពារសាក្សី និងអ្នកជំនាញថា ដោយប្រមើលមើលពេលវេលាទៅខាងមុខនេះ សាក្សីបម្រុងទុក TCW-542 ដែលអង្គជំនុំជម្រះបានគ្រោងស្តាប់សក្ខីកម្មនៅក្នុងសប្តាហ៍នេះ ឬយ៉ាងយូរនៅក្នុងសប្តាហ៍ក្រោយទំនងជាមិនអាចប្រព្រឹត្តតាមផែនការដែលបានគ្រោងទុកទេ។ ហេតុដូច្នេះ សាក្សី TCW-542 អាចត្រឡប់ទៅលំនៅដ្ឋាន ឬទៅកាន់គោលដៅដែលខ្លួនមានបំណងចង់ទៅបានហើយ នៅថ្ងៃនេះ។ ឯកាលបរិច្ឆេទកំណត់ការស្តាប់សាក្សីរូបនេះ អង្គជំនុំជម្រះនឹងជម្រាបជូននៅពេលក្រោយ ហើយទំនងជាអាចនឹងប្រព្រឹត្តទៅនៅក្នុងដើមឆ្នាំ២០១២។

[០៩:១៣:៤៤]

បង្គាប់ឲ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញចាត់ចែងរៀបចំការវិលត្រឡប់របស់សាក្សីរូបនេះទៅកាន់គោលដៅដែលគាត់ចង់ទៅឲ្យបានត្រឹមត្រូវ។

បាទ, ជាកិច្ចបន្តទៀតនេះ គឺស្តាប់សក្ខីកម្មរបស់សាក្សី ឡុង នរិន្ទ។

អរុណសួស្តីលោក ឡុង នរិន្ទ! ស្តាប់ឮទេលោក ឡុង នរិន្ទ? នៅព្រឹកនេះ គឺអង្គជំនុំជម្រះបន្តការស្តាប់នូវសក្ខីកម្មរបស់លោកបន្តទៅទៀត ហើយកម្មវិធីម្សិលមិញបានកំពុងតែដំណើរការដោយសហព្រះរាជអាជ្ញា។ ដូច្នេះ អង្គជំនុំជម្រះប្រគល់វេទិកានេះទៅសហព្រះរាជអាជ្ញា ដើម្បីដំណើរការនៃការសួរដេញដោលចំពោះសាក្សីរូបនេះ។ ហើយតាមម្សិលមិញ គឺសំណើសុំរបស់សហព្រះរាជអាជ្ញាថា ដាក់ឯកសារ ប្រសិនបើដាក់ឯកសារចំពោះមុខអង្គជំនុំជម្រះ ដើម្បីសួរដេញដោល គឺសូមប្រាប់អំពីលេខកូដលេខសម្គាល់ឯកសារឲ្យបានជាក់ច្បាស់ផង។

[០៩:១៥:១៨]

**លោក ឌេល លីសាក់៖**

អរុណសួស្តីលោកប្រធាន អង្គសវនាការជាទីគោរព។ ឯកសារនេះ គឺឯកសារដែលបានលើកឡើងដោយសហព្រះរាជអាជ្ញា ដែលយើងបានដាក់និងស្នើសុំឲ្យប្រើប្រាស់ជាមួយនឹងសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីចំនួនប្រាំបីនាក់។

ឯកសារថ្មីគឺមិនមាននៅក្នុងសំណុំរឿងទេ នៅពេលដែលយើងរកឃើញនៅពេលនោះ។ ដូច្នេះហើយ នៅពេលនេះយើងមានឯកសារនេះជាភាសាខ្មែរ អង់គ្លេស និងបារាំង។ ហើយយើងបានចែកជូនឯកសារជាក្រដាសជូនទៅដល់អង្គជំនុំជម្រះនិងភាគី។ លេខERN ខ្មែរនោះ គឺ E131/1.45, ERN លេខ 0075300, លេខខ្មែរ ERN គឺ 00003709 រហូតដល់ 00003725, លេខ ERN ជាភាសាអង់គ្លេស គឺ 00754298 រហូតទៅដល់ 00754306។ បាទ សូមអភ័យទោសចំពោះលេខ ERN ជាភាសាបារាំង ខ្ញុំសូមសួរខាងសហសេវិករបស់ខ្ញុំសិន។

[០៩:១៧:១២]

លេខ ERN ជាភាសាបារាំងគឺ 00752252 ទៅដល់ 356។ ដូច្នេះ ឯកសារនេះ វាមាននៅក្នុងសំណុំប្រព័ន្ធរបស់យើង។ ក៏ប៉ុន្តែយ៉ាងណាក៏ដោយ យើងបានផ្តល់ជូនជាឯកសារហ្នឹងជាក្រដាសជាភាសាខ្មែរ បារាំង និងអង់គ្លេស ដើម្បីការពារក្នុងករណីរកមិនឃើញ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលបង្ហាញឯកសារ! មានជាភាសាខ្មែរ ហើយភាសាអង់គ្លេស។

**មន្ត្រីរដ្ឋបាល៖**

ជាភាសាខ្មែរ (ឮមិនច្បាស់)

**ប្រធានអង្គជំនុំ៖**

បាទ?

**មន្ត្រីរដ្ឋបាល៖**

ជាភាសាខ្មែរ។

**ប្រធានអង្គជំនុំ៖**

ភាសាខ្មែរចុះ-- ដាក់នៅភាសាខ្មែរអាហ្នឹងអេ្វះ?

**មន្ត្រីរដ្ឋបាល៖**

បាទ។

**លោក ខេល លីសាក់៖**

យើងចង់បង្ហាញឯកសារខ្មែរនៅលើអេក្រង់ ដើម្បីឲ្យសាក្សីគាត់យល់។ ហើយប្រសិនបើភាគីណាមួយចង់បានបារាំង និងភាសាអង់គ្លេស ជាឯកសារក្រដាសនោះ គឺយើងអាចផ្ដល់ជូនបាន ក៏ប៉ុន្តែដើម្បីជាប្រយោជន៍ទៅដល់សាក្សី យើងខ្ញុំសូមបង្ហាញជាភាសាខ្មែរនៅលើអេក្រង់។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណ សូមអញ្ជើញ!

**លោក ខេល លីសាក់៖**

លោកប្រធានជាទីគោរព! ខ្ញុំដឹងថាខាងមេធាវីតំណាងលោក ខៀវ សំផន ចង់បានឯកសារនេះជាភាសាបារាំង។ ដូច្នេះហើយ យើងខ្ញុំសូមអនុញ្ញាតយកភាសាបារាំងនេះចែកឲ្យជូនទៅដល់គាត់។

**លោក អាកទួរ វែកគែន៖**

បាទ, សូមឲ្យបញ្ជូនសម្រាប់គ្រប់ភាសាមកទាំងអស់មកបាទ។

*(មន្ត្រីតុលាការចែកឯកសារជូនភាគី)*

[០៩:២០:២៩]

**ប្រធានអង្គជំនុំ៖**

មន្ត្រីច្បាប់យកឯកសារអង់គ្លេស និងបារាំងជូនលោកចៅក្រម យកទាំងអស់មក យកទាំងភាសាខ្មែរមក។

**លោក សុន អរុណ៖**

សូមគោរពលោកប្រធាន ខ្ញុំថា បើជាការល្អ សូមចែកឲ្យគ្រប់ខាង*ប៉ាទី*ទៅមានទាំងខ្មែរ ទាំងអង់គ្លេសមក ពីព្រោះខាងមេធាវីឲ្យ ខាងខ្ញុំអីអត់មានទេ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ, អីចឹងចុះ។ ឥឡូវងាយស្រួលគឺអនុវត្តអីចឹងទៅ ហើយបញ្ចាំបំពេញបន្ថែមពីលើឯកសារដែលបាន*ស្លាយ*នៅលើអេក្រង់ទូរទស្សន៍នេះ គឺសូមភាគីដែលដាក់ឯកសារហ្នឹង គឺរៀបចំនូវឯកសារជា

ក្រដាសសម្រាប់ចែកជូនភាគីទៅតាមអក្សរភាសា ដែលគាត់ប្រើទាំងអង្គជំនុំជម្រះផង។ ហើយយើងអនុវត្តដូច្នេះតរៀងទៅនៅក្នុងការបង្ហាញឯកសារផ្សេងៗ នៅក្នុងអំឡុងពេលនៃដេញដោលលើសំណុំរឿងក្តីនេះ។

[០៩:២៣:១២]

រួចរាល់ឬនៅ? រួចរាល់ហើយសូមអញ្ជើញសហព្រះរាជអាជ្ញា!

**លោក ម៉ែខល ផេសមិន៖**

ខាងខ្ញុំមិនទាន់បានទទួលឯកសារនេះនៅឡើយទេ។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ខាងសហមេធាវីនាំមុខជាភាសាបារាំងនោះ ក៏អត់មានទាន់បានទទួលដែរលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

ក្រឡាបញ្ជីឡើងរៀបមើល រៀបរយដើម្បីឲ្យអស់មើល អ្នកណាខ្វះខាត ឲ្យរៀបរួចឲ្យហើយសឹមដំណើរការ។

[០៩:២៤:១០]

**លោក ម៉ៃខល កាណាវាស៖**

សូមគោរពលោកប្រធាន! នៅថ្ងៃអនាគតនេះ គឺការផ្តល់ជូនឯកសារនេះ គួរតែចែកជូនមុនពេលកិច្ចដំណើរការនីតិវិធីចាប់ផ្តើម ដើម្បីជាការគោរពទៅដល់ភាគី។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណនូវការផ្តល់នូវមតិយោបល់ដ៏ល្អនេះ។ អ៊ីចឹង យើងរំឭកម្តងទៀតថា ភាគីណាដែលមានបំណងដាក់បង្ហាញឯកសារនៅលើអេក្រង់ទូរទស្សន៍ នៅក្នុងអំឡុងពេលពិភាក្សាដេញដោលសំណុំរឿងក្តី០០២/០១ តាំងពីដើមទាល់ចប់ត្រូវរៀបចំនូវឯកសារជាក្រដាសទាំងបីភាសា ហើយចែកជូនដល់អង្គជំនុំជម្រះ និងភាគី ដែលពាក់ព័ន្ធហ្នឹង ឲ្យបានសព្វគ្រប់ជាមុន មុននឹងចាប់ផ្តើមដំណើរការ។ អ៊ីចឹងគឺសូមឲ្យត្រៀមលក្ខណៈឲ្យបានត្រឹមត្រូវ ឲ្យឆាប់រហ័សចៀសវាងការចំណាយពេលឥតប្រយោជន៍។

អង្គជំនុំជម្រះសូមផ្តល់វេទិកាទៅសហព្រះរាជអាជ្ញាបន្តការដេញដោល។ សូមអញ្ជើញ!

**លោក ឌេល លីសាក់៖**

គឺដើម្បីបញ្ជាក់ប្រតិចារឹកឲ្យបានច្បាស់លាស់ ខ្ញុំបាននិយាយជាមួយនឹងខាងមេធាវីការពារក្តី

អៀង សារី កាលពីម្សិលមិញ ដែលបានស្នើសុំឯកសារនោះ។ ខ្ញុំក៏បានផ្ញើជូនអ៊ីម៉ែលទៅដល់គាត់ ហើយខ្ញុំក៏បានប្រាប់លេខ ERN ទៅដល់គាត់ផងដែរ។ ហើយប្រសិនបើគាត់រកមិនឃើញ ឲ្យទាក់ទងមកយើងខ្ញុំ។ ហើយខ្ញុំថា លើកក្រោយ ខ្ញុំសូមជម្រាបថា លើកក្រោយ ខ្ញុំនឹងធ្វើទៅតាមការបង្គាប់។

ហើយចំណុចទីពីរ គឺនៅពេលនេះ ខ្ញុំសូមអនុញ្ញាតសុំអង្គុយដើម្បីសួរដេញដោលទៅសាក្សីដដែល ដើម្បីជាការងាយស្រួលសម្រាប់សាក្សីមើលឃើញរូបខ្ញុំ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាតតាមការស្នើសុំ។ សូមអញ្ជើញ!

[០៩:២៧:០៥]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** អរុណសួស្តីលោក ឡុង នរិន្ទ, តើលោកសុខសប្បាយទេព្រឹកនេះ?

**លោក ឡុង នរិន្ទ៖**

**ឆ៖** បាទ។

**ស៖** នៅពេលដែលយើងឈប់កាលពីម្សិលមិញនោះ គឺខ្ញុំត្រៀមនឹងបង្ហាញលោកនូវប្រវត្តិរូបដែលលោកបានសរសេរ។ នៅពេលនេះ ខ្ញុំសូមអនុញ្ញាតបង្ហាញនូវពីរទំព័រនៃប្រវត្តិរូបរបស់លោក ហើយសូមស្នើសួរទៅលោកអ៊ំ ថាតើលោកអ៊ំស្គាល់នូវប្រវត្តិរូបនោះដែរឬទេ? គឺឯកសារលេខ 0003710?

**លោក ញ៉ែម សំណាង៖**

អ៊ំមើលឃើញទេអ៊ំ?

**ឆ៖** បាទ។ នេះឃើញច្បាស់ អំមិញអាធំៗអំមិញមិនច្បាស់។

**លោក ញ៉ែម សំណាង៖**

ចុះវ៉ែនតាអ៊ំប្រើនៅឯណា? វ៉ែនតាអ៊ំ?

**ស៖** លោកឡុង នរិន្ទ ទំព័រដែលលោកអ៊ំមើលឃើញនេះ តើលោកអ៊ំស្គាល់ថាជាអក្សររបស់លោកអ៊ំដែរឬទេ?

**ឆ៖** បាទ។

**ស៖** បើសិនបើយើងចូលទៅទំព័រដំបូង សូមបង្ហាញទំព័រដំបូង។

**ឆ៖** ប្រវត្តិរូបសមមិត្ត។

**លោក ញ៉ែម សំណាង៖**

សូមជម្រាបលោកប្រធាន មើលអត់អស់ទេ អត់ចំកណ្ដាល។ អក្សរហ្នឹងឃើញពាក់កណ្ដាល។

**ឆ៖** ប្រវត្តិរូបសមមិត្ត វិត។

**ស៖** ថាតើនេះជាប្រវត្តិរូបដែលលោកបានរៀបចំឡើង ក្រោយពីលោកបាននិយាយជាមួយនឹង អៀង សារី ដូចដែលលោកបានជម្រាបកាលពីម្សិលមិញ មែនដែរឬទេ?

[០៩:៣០:០៥]

**ឆ៖** បាទ, អាហ្នឹងខ្ញុំសរសេរក្រោយពីហ្នឹងមក។

**ស៖** ទំព័រទីមួយនៃប្រវត្តិរូបនេះ តើទំព័រទីមួយនេះជា-- សរសេរជាអក្សររបស់លោកអ៊ំសរសេរ ដូចគ្នាមែនដែរឬទេ?

**ឆ៖** បាទ។

**ស៖** ហើយឈ្មោះដែលបានសរសេរនៅទំព័រនុ៎ង ថាតើឈ្មោះនោះជាឈ្មោះបដិវត្តន៍របស់លោកអ៊ំ ដែលលោកអ៊ំបានប្រើប្រាស់ក្នុងពេលកម្ពុជាប្រជាធិបតេយ្យមែនដែរឬទេ?

**ឆ៖** បាទៗ។

**ស៖** ខ្ញុំចង់សួរបញ្ជាក់កាលពីម្សិលមិញ ដើម្បីឲ្យបានច្បាស់ទាំងអស់គ្នា តាមអ្វីដែលលោកអ៊ំចាំនោះ ថាតើនៅពេលដែលលោកអ៊ំសរសេរប្រវត្តិរូបនេះ គឺសរសេរនៅក្នុងឆ្នាំណាដែរ?

[០៩:៣១:៣១]

**ឆ៖** ខ្ញុំមិនចាំច្បាស់ទេ ឥឡូវ យូរណាស់ទៅហើយ ៣០ឆ្នាំប្លាយហើយ។

**ស៖** គឺសរសេរនៅពេលដែលលោកអ៊ំសរសេរ-- ការសរសេរប្រវត្តិរូបនោះគឺនៅពេលដែលលោកអ៊ំធ្វើការនៅក្រសួងការបរទេសចាប់ពីថ្ងៃទី១៧ ខែមេសា ៧៥ ដល់ ៦ មករា ឆ្នាំ១៩៧៩ មែនដែរឬទេ?

**ឆ៖** បាទ។

**ស៖** តើលោកអ៊ំចាំដែរឬទេ គឺការសរសេរឡើងនេះ គឺនៅពេលដែលចាប់ផ្ដើមនៃរបបកម្ពុជាប្រជាធិបតេយ្យនៅក្នុងចន្លោះដើមរបបនោះ ឬក៏នៅចុងរបបនោះ?

**ឆ៖** នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យហើយ ដែលខ្ញុំសរសេរប្រវត្តិរូបហ្នឹង។

**លោក អាកទូរ វែកគែន៖**

លោកប្រធានសូមអភ័យទោស។ សហភាគា-- បាទ យើងមានការលំបាកក្នុងការទទួលស្គាល់ឯកសារនេះ ដោយសារតែលោក ឡុង នរិន្ទ គាត់ត្រូវបានស្តាប់ចម្លើយតាមរយៈវីដេអូ។ ដូច្នេះ ខ្ញុំគិតថាគាត់-- លោក ឡុង នរិន្ទ នេះគាត់មានពិបាកក្នុងការមើលទំព័រទីមួយនៃឯកសារនោះ ដើម្បីជាមូលដ្ឋានសម្រាប់ធ្វើសុពលកម្មទៅលើឯកសារទាំងមូលតែម្តង។ ដូច្នេះ ដើម្បីឲ្យវាមានសុពលភាពនោះ មុននឹងឲ្យលោកសហព្រះរាជអាជ្ញាបន្តសួរសំណួរ សូមឲ្យលោក ឡុង នរិន្ទ នុំងគាត់មើលឯកសារនេះទាំងមូលតែម្តង ដើម្បីឲ្យគាត់ទទួលស្គាល់ថា នេះជាពិតជាឯកសាររបស់គាត់មែន។ ពេលនោះ បើមិនអ៊ីចឹងទេ វាមានការស្រពេចស្រពិល ហើយនៅពេលនេះគឺថា ធ្វើម៉េចឲ្យគាត់ទទួលស្គាល់ឯកសារទាំងមូល ឬក៏គាត់ស្គាល់តែត្រឹមគម្រប ឬក៏ពាក្យមួយចំនួនដែលបានបង្ហាញជូនគាត់ ហើយដែលវាអត់-- ជួនកាលអត់ឃើញក្នុងឯកសារនេះ ជួនកាលមើលអត់ដាច់ទេ នៅលើអេក្រង់។

[០៩:៣៤:១៦]

ហើយខ្ញុំក៏ខ្ញុំមើលមិនឃើញច្បាស់ដែរ ហើយដល់អ៊ីចឹង ខ្ញុំគិតថាលោក ឡុង នរិន្ទ ក៏គាត់ប្រហែលជាគាត់មើលមិនច្បាស់ដែរ នៅក្នុងវីដេអូនេះ។ ដូច្នេះ ឯកសារនេះជាភាសាបារាំង គឺមាន ១៥ទំព័រ។ ដូច្នេះខ្ញុំសូមលើកឡើងនៅពេលនេះតែម្តង ដើម្បីថាកុំឲ្យមានការលំបាកនៅពេលក្រោយ។ តើសុំឲ្យ-- គាត់ឲ្យ សូមឲ្យលោក ឡុង នរិន្ទ ពិនិត្យមើលឯកសារនេះទាំងមូល ទាំងអស់តែម្តង។ គឺថាសុំឲ្យគាត់ហ្នឹងទទួលស្គាល់ថា នេះជាឯកសារទាំងមូលរបស់គាត់សិនលោកប្រធាន។

បាទ, សូមអរគុណ។

[០៩:៣៤:៥៦]

**ប្រធានអង្គជំនុំ៖**

អរគុណ។ ប៉ុន្តែអម្បាញ់មិញនេះ យើងបានកត់សម្គាល់ឃើញ ឡុង នរិន្ទ បានអាននូវគម្របនៃឯកសារនេះ ហើយគាត់ទទួលស្គាល់ថានេះ គឺជាអក្សរដែលសរសេរដោយខ្លួនគាត់។ ដោយឡែកនៅក្នុងទំព័រផ្សេងទៀត ក៏ដូចគ្នាដែរ។ ហើយដើម្បីឲ្យបានច្បាស់លាស់ គឺសូមបញ្ជាក់សាជាថ្មីម្តងទៀតចំពោះលោក ឡុង នរិន្ទ។ ឥឡូវហ្នឹងលោកអាចមើលឃើញនូវឯកសារដែលដាក់បង្ហាញនេះទេ ឬក៏មើលមិនឃើញទេ ឬក៏មើលឃើញគ្រាន់តែវាមិនច្បាស់ដោយសារមូលហេតុអក្សរតូចពេក ឬក៏មូលហេតុអ៊ីត្រូវការប្រើប្រាស់នូវវ៉ែតា។

អង្គជំនុំជម្រះអនុញ្ញាតឲ្យលោកប្រើប្រាស់វ៉ែនតាដើម្បីក្នុងការពិនិត្យមើលឯកសារនេះ ជាពិសេសគឺភិនភាគអក្សរ។

**លោក ឡុង នរិន្ទ៖**

មើលមិនច្បាស់ទេ ព្រិលៗ។

**ប្រធានអង្គជំនុំ៖**

ស្តាប់បានទេ?

**លោក ឡុង នរិន្ទ៖**

អ៊ំត្រូវការវ៉ែនតា បាទ។

[០៩:៣៦:២០]

**លោក ញ៉ែម សំណាង៖**

(ឮមិនច្បាស់) អ៊ំអានេះតូចខ្លាំងពេក ឬយ៉ាងម៉េច? តូចខ្លាំងពេក សាកមើលបន្តិចមើល។ រៀងចង្អៀតប៉ុន្តែអ៊ំមើលបានទេប៉ុណ្ណឹង។ ព្រិលភ្នែកទេ?

**លោក ឡុង នរិន្ទ៖**

គ្រាន់បើជាងអត់វ៉ែនតានេះ។

**លោក ញ៉ែម សំណាង៖**

នេះគ្រាន់បើជាងអត់វ៉ែនតាអ៊ំ?

**លោក ឡុង នរិន្ទ៖**

ប៉ុន្តែមិនដូចដែលវ៉ែនតាខ្ញុំហ្នឹង វាវាស់អីស្រួលប្លួល។

**លោក ញ៉ែម សំណាង៖**

ចុះវ៉ែនតាអ៊ំទៅណាទៅ?

**លោក ឡុង នរិន្ទ៖**

នៅហោប៉ៅអាវក្នុងបន្ទប់។

[០៩:៣៩:១២]

**លោក ញ៉ែម សំណាង៖**

ជម្រាបលោកប្រធាន! សាក្សីបានរកវ៉ែនតាឃើញហើយលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណ។ ហើយមុននឹងចាប់ផ្ដើមទៀត សួរទៅសហព្រះរាជអាជ្ញាថាតើឯកសារទាំងនេះលោកត្រូវសួរដេញដោលទៅចំពោះសាក្សីរូបនេះនូវឯកសារទាំងមូល ឬក៏ទំព័រ ដកស្រង់តែទំព័រមួយចំនួនទេ យកមកក្នុងការយកមកសួរដេញដោលក្នុងពេលនេះ?

**លោក ញ៉ែម សំណាង៖**

ជម្រាបលោកប្រធាន។ ឃើញនៅនេះអត់សូវច្បាស់ប៉ុន្មានទេលោកប្រធាន សូម្បីខ្ញុំមើលខាងក្រៅអត់សូវច្បាស់ រាងដាមលោកប្រធាន អក្សរ។

**ប្រធានអង្គជំនុំ៖**

បាន។ហើយខ្ញុំសួរទៅសហព្រះរាជអាជ្ញាសិន ដើម្បីឲ្យគាត់ឆ្លើយសិន តើគាត់ត្រូវការដេញដោលនូវឯកសារទាំងមូល ឬក៏នៅទំព័រណាខ្លះ ដើម្បីយើងផ្ទុះបញ្ចាំង ការពិនិត្យ ពិច័យឲ្យបានហ្មត់ចត់ បញ្ជាក់អំពីសុពលភាពនៃឯកសារនេះជាមុនសិន មុននឹងដេញដោល។

**លោក ឌេល លីសាក់៖**

លោកប្រធាន លោក លោកស្រីចៅក្រមជាទីគោរព! គឺខ្ញុំមិនសួរគ្រប់ទំព័រនោះទេ គឺប្រហែលជាចំនួនបីទំព័រតែប៉ុណ្ណោះដែលខ្ញុំនឹងសួរសំណួរជាក់ជាក់ទៅដល់គាត់។ ដូច្នេះអ្វីដែលខ្ញុំស្នើសុំនោះ គឺសូមឲ្យពង្រីកវា ដើម្បីឲ្យទំព័រដែលយើងពិនិត្យដេញដោលនោះមានលក្ខណៈធំស្រួលមើល។

[០៩:៤០:៥២]

ដូច្នេះហើយសូមឲ្យពង្រីកនូវកថាខណ្ឌទីមួយ ដែលយើងខ្ញុំនឹងសួរទៅលើសាក្សី ឬការពង្រីកធំនេះ គឺដើម្បីឲ្យសាក្សី និងយើងទាំងអស់គ្នាអាចមើលឃើញ ហើយយើងអាចកត់ជាប្រតិចារិកសម្រាប់សាក្សីផងដែរ។

ដូច្នេះហើយជាដំបូងនេះ គឺខ្ញុំសូមអនុញ្ញាតឲ្យធ្វើការពង្រីកនូវកថាខណ្ឌដំបូងនេះ ដើម្បីឲ្យសាក្សីនិងយើងទាំងអស់គ្នាអាចមើលឃើញ។ សូមអរគុណ។

[០៩:៤១:៣១]

**ប្រធានអង្គជំនុំ៖**

អរគុណ! ប៉ុន្តែអំមិញនេះមានការមតិជំទាស់របស់មេធាវី នួន ជា បញ្ជាក់អំពីសុពលភាព ឬមិនមានសុពលភាពនៃឯកសារនេះ។ ដោយសារសាក្សីមើលមិនច្បាស់ អ៊ីចឹងហើយដំណាក់ដំបូងនេះត្រូវរក

មធ្យោបាយដើម្បីឲ្យគាត់បញ្ជាក់លើទម្រង់នៃឯកសារនេះជាមុនសិន ថាតើជាឯកសារពិតជាសរសេរដោយដៃគាត់មែនដែរឬទេ? បន្ទាប់មក គឺផ្តល់ឱកាសទៅលោក ដើម្បីឲ្យលោកសាកសួរលើទំព័រណាដែលលោកចង់ដេញដោលដោយពង្រីកដូចគ្នា ដើម្បីឲ្យសាក្សីហ្នឹងបានពិនិត្យច្បាស់។

អ៊ីចឹង មានពីរដំណាក់កាល។ ដំណាក់នៃបញ្ជាក់ឯកសារដោយជំទាស់ដោយមេធាវីការពារក្តី ដើម្បីបញ្ជាក់អំពីសុពលភាពថាពិតជាឯកសារដែលសរសេរដោយដៃគាត់ បន្ទាប់មក គឺបញ្ជាក់អំពីខ្លឹមសារដែលចង់ដេញដោល។

នេះការគិត ហើយជាការល្អណាស់ដោយមានគំនិតក្នុងការពង្រីក ពីព្រោះមធ្យោបាយប្រព័ន្ធបច្ចេកវិទ្យានេះ គឺយើងអាចពង្រីកអក្សរសមរម្យ ដែលអាចនឹងមើលឃើញបាន។ អ៊ីចឹងអ្នកបច្ចេកទេសគ្រប់គ្រងអាហ្នឹង គឺរៀបចំបង្ហាញនូវឯកសារនេះ ដើម្បីឲ្យបានអក្សរធំ ដើម្បីឲ្យគាត់បានមើល។

[០៩:៤២:៥២]

ទីមួយ គឺសួរបញ្ជាក់អំពីបញ្ហាសុពលភាព ថាតើពិតជាឯកសារនេះត្រូវសរសេរដោយដៃគាត់ទេ ព្រោះគាត់សរសេរ គាត់ស្គាល់អក្សរគាត់ហើយ។

សូមអញ្ជើញ!

**លោក ខេល លីសាក់៖**

លោកប្រធាន អ្វីដែលខ្ញុំស្នើឡើងអម្បាញ់មិញនេះ គឺយើងធ្វើការបញ្ចាំងទៅលើឯកសារនេះលើរាល់ទំព័រតែម្តង ហើយយើងនឹងសូមឲ្យគាត់បញ្ជាក់នូវគ្រប់ទំព័រ ថាតើគ្រប់ទំព័រនោះគឺជាអក្សររបស់គាត់ដែរឬទេ? បន្ទាប់មកយើងនឹងសួរដេញដោលទៅកថាខណ្ឌ ឬទំព័រដែលយើងចង់ពិនិត្យ។

[០៩:៤៣:៤៣]

**សួរដោយលោក ខេល លីសាក់៖**

**ស៖** ដូច្នេះយើងសូមឲ្យសាក្សីពិនិត្យមើលចាប់ពីដើមទំព័រ រហូតទៅដល់ចុងទំព័រ គឺឯកសារនេះគឺបានរក្សាទុកនៅក្នុងបណ្ណសាររបស់យើងរួចហើយ។ ក៏ប៉ុន្តែយ៉ាងក៏ដោយ គឺយើងគួរតែ-- យើងសូមស្នើសុំឲ្យលោក ឡុង នរិន្ទ ហ្នឹងពិនិត្យគ្រប់ទំព័រ ចាប់ពីដើមរហូតទៅដល់ទំព័រចុងក្រោយ ហើយដើម្បីឲ្យលោកសាក្សីបញ្ជាក់ ថាតើគ្រប់ទំព័រទាំងអស់នោះ គឺជាអក្សររបស់លោកសាក្សីដែរឬទេ?

**លោក ឡុង នរិន្ទ៖**

**ឆ៖** បាទ។

[០៩:៤៥:០០]

**ស៖** អ្វីដែលខ្ញុំចង់សួរបញ្ជាក់ពីលោកអ៊ំ ឡុង នរិន្ទ លើកលែងតែទំព័រចុងក្រោយដែលជាតារាង។ ដូច្នេះខ្ញុំសូមសួរថា ក្រៅពីតែទំព័រចុងក្រោយ ថាតើទំព័រចុងក្រោយហ្នឹង គឺជាអក្សររបស់លោកអ៊ំដែរ ឬក៏យ៉ាងម៉េច?

ទំព័រដែលយើងបង្ហាញអម្បាញ់មិញទាំងអស់ហ្នឹង ថាតើគ្រប់ទំព័រទាំងអស់ហ្នឹង គឺជាអក្សររបស់អ៊ំទាំងអស់ ឬក៏យ៉ាងម៉េច?

[០៩:៤៦:១០]

**ប្រធានអង្គជំនុំ៖**

ស្តាប់ឮទេ? ហើយ សំណាង ខ្លួនឯងស្តាប់ឮទេ សំណាង នៅជិតហ្នឹង? ហើយអាចប្រាប់គាត់បានទេអំពីសំណួរដែលសួរអំមិញហ្នឹង ដើម្បីបញ្ជាក់ប្រាប់គាត់ឡើងវិញនូវសំណួរដែលសួរនេះ។

**លោក ញ៉ែម សំណាង៖**

បាទៗ។

**ប្រធានអង្គជំនុំ៖**

ហើយដើម្បីឲ្យគាត់-- បើគាត់ស្តាប់មិនអស់ ឬក៏មិនយល់មិនអស់ហ្នឹង គឺអាចសួរប្រាប់ឡើងវិញដើម្បីឲ្យគាត់ឆ្លើយបានណ៎ា បើពុំដូច្នោះទេមិនអាចធ្វើអ្វីបានទេ។

**លោក ញ៉ែម សំណាង៖**

ស្តាប់បានទេអ៊ំអំមិញ?

[០៩:៤៦:៣៥]

**លោក ឡុង នរិន្ទ៖**

**ឆ៖** អំមិញហ៎?

**លោក ញ៉ែម សំណាង៖**

បាទ!

**ឆ៖** អំមិញចាំទេ គេសួរថាម៉េចអំមិញ?

**លោក ញ៉ែម សំណាង៖**

សួរថាទំព័រទាំងអស់ដែលអ៊ំបានមើលអំមិញនេះ តើជាអក្សររបស់អ៊ំទាំងអស់ ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ, ទំព័រទាំងអស់ ដែលខ្ញុំបានមើលអំមិញនេះ ហ្នឹងគឺជាអក្សរខ្ញុំហើយ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកប្រធាននៅពេលនេះ គឺខ្ញុំសូមអនុញ្ញាតត្រឡប់មកទំព័រដែលមានលេខ០០០០៣៧១០ ដើម្បីអាចឲ្យខ្ញុំសួរដេញដោលទៅលើសាក្សី ទៅលើកថាខណ្ឌនៅក្នុងទំព័រនុ៎ង។ ប្រសិនបើយើងអាចនៅលើអេក្រង់សូមបញ្ចាំងនូវកថាខណ្ឌទីពីរ ដែលនៅក្នុងកថាខណ្ឌនោះចាប់ផ្ដើមដោយអក្សរថា "អា ចាច់ ជា"។ លោក ឡុង នរិន្ទ សំណួរទីមួយរបស់ខ្ញុំចង់សួរនៅក្នុងថ្ងៃនេះ គឺថាកាលពីម្សិលមិញលោកអ៊ំបានរៀបរាប់ ថាលោកអ៊ំបាននិយាយជាមួយនឹងលោក អៀង សារី ហើយ លោក អៀង សារី បានសួរលោកអ៊ំថា តើលោកអ៊ំជា សេ.អ៊ី.អា ឬក៏មិនមែន? ហើយលោកក៏បានសួរលោកអ៊ំថាមានទំនាក់ទំនងអ្វីជាមួយនឹង ចាច់ ជា? ដូច្នេះ ខ្ញុំសូមសួរថា បុគ្គលដែលលោកអ៊ំបាននិយាយសំដៅទៅកាលពីម្សិលមិញនោះ តើមានឈ្មោះនៅក្នុងប្រវត្តិរូបនេះទេ?

[០៩:៤៨:៤១]

**លោក ឡុង នរិន្ទ៖**

**ឆ៖** មាន។ ចាច់ ជា។

**ស៖** ដូច្នោះ ថាតើលោកអ៊ំបានរៀនជាមួយ ចាច់ ជា នៅសាលាគរុកោសល្យមែនដែរឬទេ? ហើយ គឺ ចាច់ ជា នេះហើយដែលលោក អៀង សារី បានសួរអំពីនោះ។ សំណួរ ខ្ញុំចង់សួរថា តើបុគ្គលរូបនេះដែលជា ចាច់ ជា នេះក្រោយមកគាត់ក្លាយជាទៅជាប្រធាននៃសាលាមួយនៅជំនាន់ លន់ នល់ តើមែនដែរ ឬទេ? គឺគាត់ក្រោយមកគាត់ក្លាយទៅជាអនុប្រធានក្រសួងអប់រំនៅជំនាន់ លន់ នល់ តើមែនដែរ ឬទេ?

[០៩:៤៩:៥៧]

**ឆ៖** ចាច់ ជា ជាប្រធាន អង្គាល់ហ្នឹងគាត់ឡើងធ្វើប្រធានសមាគមន៍និស្សិតនៅសាលាគរុកោសល្យហ្នឹង។

**ស៖** តើលោកបានដឹង ឬក៏មិនបានដឹងថា លោក ចាច់ ជា នេះ គឺមានតួនាទីមួយដែរជាមួយនឹងខាងប្រធាន ឬក៏រដ្ឋមន្ត្រីនៅក្នុងសម័យ លន់ នល់?

**ឆ៖** បាទ នៅសម័យ លន់ នល់ ចាច់ ជា មានការទំនាក់ទំនងជាមួយនិងខាងរដ្ឋាភិបាលច្រើន។

**ស៖** តើលោកអ៊ំអាចប្រាប់តុលាការដែរឬទេថា ថាច់ ជា នេះគឺត្រូវបានកូនសិស្សចាប់ធ្វើជាចំណាប់ខ្មាំងនៅក្នុងទីក្រុងភ្នំពេញនៅក្នុងឆ្នាំ១៩៧៤ ហើយត្រូវបានគេបាញ់សម្លាប់ចោលជាមួយនឹងរដ្ឋមន្ត្រីក្រសួងអប់រំដែរ តើមែនដែរឬទេ?

**ឆ៖** អារឿងហ្នឹង ខ្ញុំអត់ដឹងទេ។ ខ្ញុំ-- អង្កាល់ហ្នឹងដូចជាមានសម្លាប់អីចឹង ប៉ុន្តែមិនដឹងសម្លាប់អ្នកណាខ្លះទេ ពេលដែលកូនសិស្សចាប់ហ្នឹង អង្កាល់ហ្នឹង។ ខ្ញុំភ្លេចទៅហើយ រឿងយូរមកហើយ។ ដូចជា ថាច់ ជា (ឮមិនច្បាស់)។

[០៩:៥២:៣០]

**ស៖** តើលោកអ៊ំអាចប្រាប់តុលាការបានទេដែរឬទេ ហេតុអ្វីបានជាលោកអ៊ំហៅ ថាច់ ជា នេះហៅ អា ថាច់ ជា?

**ឆ៖** ពីព្រោះអង្កាល់ហ្នឹង គឺពួកខ្ញុំហើយនិង ថាច់ ជា ហ្នឹង លេងបាល់លេងអីជាមួយគ្នា ហៅតែអាទៅអាមកហ្នឹង។ តាមពិត ខ្ញុំមិនរៀនរហូតៗទៅដល់ថ្នាក់ទីបញ្ចប់ទេជាមួយ ថាច់ ជា ហ្នឹង រៀនតែប៉ុន្មានឆ្នាំទេ គឺរៀនឆ្នាំ-- រៀននៅថ្នាក់ទី៦ ហើយនិងថ្នាក់ទី៥ រួចទៅដូចជាបែកគ្នាហើយ។ នែ៎ ថាច់ ជា រៀនផ្សេង ខ្ញុំរៀនថ្នាក់ផ្សេង។ ប៉ុន្តែនៅលេងបាល់អីជាមួយគ្នា ពីព្រោះជាក្រុមសាលាគរុកោសល្យហ្នឹង ហើយខ្ញុំជានិស្សិតនៅហ្នឹងដែរ ដូច្នោះ លេងបាល់នៅក្នុងក្រុមជាមួយគ្នា។

**ស៖** បានន័យថា លោកអ៊ំ ហៅ ថាច់ ជា នេះគឺគ្រាន់តែចង់មានន័យថាជាទំនាក់ទំនងជិតស្និទ្ធតែប៉ុណ្ណោះ ដែលថាហៅថា "អា" នុ៎ង។ ហេតុអ្វីបានជាលោក អៀង សារី ចង់ឲ្យលោកអ៊ំពន្យល់អំពីទំនាក់ទំនងលោកអ៊ំជាមួយនឹងបុគ្គលរូបនុ៎ង?

**ឆ៖** ពីព្រោះ អាហ្នឹងខ្ញុំមិនដឹងច្បាស់ទេ ប៉ុន្តែតាមមើលទៅបែបមានគេចោទប្រកាន់ខ្ញុំថា ខ្ញុំជាភ្នាក់ងារ សេ.អ៊ី.អា អីចឹងបានគាត់ឲ្យសរសេរប្រវត្តិរូបឲ្យច្បាស់លាស់។

[០៩:៥៥:០៦]

**ស៖** កាលពីម្សិលមិញ លោកអ៊ំបាននិយាយថា លោក អៀង សារី ប្រាប់លោកអ៊ំថា ថាច់ ជា គឺជាភ្នាក់ងារ សេ.អ៊ី.អា តើត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ។ ដែល ខ្ញុំដឹងថា ថាច់ ជា ជាភ្នាក់ងារ សេ.អ៊ី.អា ហ្នឹង គឺដោយសារតែ នេះហ្នឹងនែ៎ ការទាក់ទងរបស់ ថាច់ ជា ច្រើនតែទៅជាមួយនឹងស្ថានទូតប៉ែកខាង សេ.អ៊ី.អា។ ខុសពីខ្ញុំ គឺខ្ញុំទៅទាក់ទងច្រើនតែជាមួយនឹងស្ថានទូតប្រទេសសង្គមនិយម ឬក៏អព្យាក្រឹត ដូចជាប្រទេសឥណ្ឌាអីចឹង។

**ស៖** ថាតើហេតុអ្វីបានជាលោកអ៊ំដឹងថា បុគ្គលរូបហ្នឹងទាក់ទងជាមួយនឹងខាង សេ.អ៊ី.អា នៅតាមស្ថានទូត តើលោកអ៊ំដឹងតាមរបៀបណា?

**ឆ៖** ខ្ញុំអត់-- មែនទែនទៅខ្ញុំដឹងដោយសារ អង្កាល់ហ្នឹងនៅសាលាគរុវិជ្ជាហ្នឹងមានបញ្ចាំងហ្វីលហើយហ្វីលហ្នឹងទៅខ្ចីពីស្ថានទូតមក។ ដូច្នេះ ខ្ញុំបើថាទៅខាងស្ថានទូតប្រទេសសង្គមនិយមគឺខ្ញុំហើយទៅ ហើយនិងអព្យាក្រឹត។ ហើយបើទៅខាងប្រទេសខាងលោកខាងលិចហ្នឹង គឺ ថាច់ ជា ហ្នឹងទៅ។

[០៩:៥៧:៣១]

**ស៖** ខ្ញុំសូមសួរត្រឡប់ទៅក្រោយបន្តិច លោកអ៊ំ ឡុង នរិន្ទ។ តើលោកអ៊ំអាចជម្រាបយើងខ្ញុំដែរឬទេ តើគោលបំណងដែលគេឲ្យរៀបចំប្រវត្តិរូបក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ តើគេមានគោលបំណងអ្វីដែរ?

**ឆ៖** ជាគោលបំណងធំនោះ ខ្ញុំអត់ដឹងអីទេ ប៉ុន្តែជាការប៉ាន់ប្រមាណ គឺថាដើម្បីឲ្យច្បាស់ថា តើអ្នកហ្នឹងជាស្អី? ជាភ្នាក់ងារស្អី ឬអត់ទេ?

**ស៖** នៅពេលដែលលោកអ៊ំនិយាយថា លោកអ៊ំទាក់ទងជាមួយនឹងស្ថានប័នផ្សេង ឬក៏ទូតផ្សេងនោះ ថាតើលោកអ៊ំនិយាយសំដៅថាលោកអ៊ំជាអ្វីដែរ?

**ឆ៖** អង្កាល់ហ្នឹង ខ្ញុំជានិស្សិតនៅសាលាគរុវិជ្ជាហ្នឹង។ ទៅខ្ចី មែនទែនទៅបញ្ហាធំ គឺទៅខ្ចីហ្វីលយកមកបញ្ចាំងឲ្យថែកគ្នា ឲ្យសិស្ស និស្សិតមើលប៉ុណ្ណឹងទេ។

[០៩:៥៩:២៨]

**ស៖** ខ្ញុំចង់សួរថា ខ្ញុំសូមឲ្យលោកអ៊ំបង្ហាញអំពីហេតុផលដែលគេឲ្យសរសេរប្រវត្តិរូប ហើយនៅក្នុងហ្នឹងលោកអ៊ំបាននិយាយថា លោកអ៊ំជាប់ទាក់ទងជាមួយនឹងអង្គការ ឬក៏ស្ថាប័នមួយចំនួន។ ដូច្នេះខ្ញុំចង់សួរថាតើអង្គការហ្នឹងគេចាប់អារម្មណ៍តែពីរឿងអ៊ំជាប់ពាក់ព័ន្ធជាមួយអ្នកណាខ្លះ មែនដែរឬទេនៅពេលដែលគេសរសេរប្រវត្តិរូបនុ៎ង?

**ឆ៖** អង្គការហ្នឹងមែនទែនទៅគឺថា មានតែអង្គការស្កុត ប៉ុណ្ណឹង ព្រោះខ្ញុំចូលស្កុតមុនដំបូងនៅស្កុតយុត្តិវង្ស។ ដល់ក្រោយមកវាបាក់បែកគ្នា ខ្ញុំមកបង្កើតក្រុមភវវឌ្ឍន៍។ អត់មានអង្គការអីផ្សេងនេះទេ ដូចអត់មានអង្គការអីផ្សេងជានយោបាយអីទេ មានតែស្កុតហ្នឹង។

**ស៖** នៅពេលដែលលោកអ៊ំសរសេរប្រវត្តិរូបនេះ តើលោកអ៊ំយល់ដែរឬទេថា គេគិតថាចង់ឲ្យលោកអ៊ំហ្នឹងបង្ហាញសេចក្តីស្មោះត្រង់ទៅដល់បក្ស ហើយគេចង់ឲ្យលោកអ៊ំបង្ហាញថាតើលោកអ៊ំជាប់

ពាក់ព័ន្ធជាមួយនឹងភ្នាក់ងារ សេ.អ៊ី.អា ឬក៏ជាប់ពាក់ព័ន្ធជាមួយនឹងខ្មាំងរបស់បក្សដែរឬទេ? តើគេចង់បានអាអ៊ីចឹងអ្វែ?

**ឆ៖** ខ្ញុំអត់ដឹងទេ។ គ្រាន់តែថាឲ្យខ្ញុំសរសេរប្រវត្តិរូបហ្នឹងតាមឲ្យស្មោះ ហើយឲ្យអស់។

[១០:០១:៥៩]

**លោក ញ៉ែម សំណាង៖**

លោកប្រធានសាក្សីចង់ទៅបត់ជើង លោកប្រធានសូមអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទ, អនុញ្ញាតសូមអញ្ជើញ!

**លោក ញ៉ែម សំណាង៖**

[១០:០៤:៤៩]

លោកប្រធានសាក្សីបានត្រឡប់មកហើយ។

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណ។ សូមអញ្ជើញសហព្រះរាជអាជ្ញាបន្តសំណួរ!

[១០:០៥:០៨]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ឥឡូវនេះ ខ្ញុំចង់បង្ហាញទំព័រ 0003724 នៃប្រវត្តិរូបរបស់លោក លោក ឡុង នរិន្ទ! ខ្ញុំសូមបង្ហាញជូននៅលើអេក្រង់នេះ។

**លោក ឡុង នរិន្ទ៖**

**ឆ៖** កន្លែងខ្លះទ្រង់ដាប។

**ស៖** ខ្ញុំនឹងពង្រីកឲ្យធំទៅលើផ្នែកខាងលើនៃទំព័រនេះ លោកអាចអានបានទេលោក? លោក ឡុង នរិន្ទ លោកអាចអានបានទេ?

**លោក ញ៉ែម សំណាង៖**

ជម្រាបលោកប្រធាន! ឯកសារហ្នឹងដាច់ទៅខាងស្តាប់លោកប្រធាន ប្រសិនជាងាកមកឆ្វេងបន្តិចអាហ្នឹងបានអស់។

**ប្រធានអង្គជំនុំ៖**

បាននៅ? ឃើញនៅ?

**លោក ឡុង នរិន្ទ៖**

ឃើញហើយ។

**លោក ញ៉ែម សំណាង៖**

ឃើញៗអស់លោកប្រធាន តែអត់ច្បាស់វាតូចវិញ លោកប្រធាន។ ដល់ពេលពង្រីកទៅវាបែកទៅខាងស្តាំដៃ អ៊ីចឹងទៅមើលអត់អក្សរ ពេលពង្រីកឃើញច្បាស់។

[១០:០៧:០០]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** សឹមខ្ញុំបញ្ជាក់ជាដំបូងសិនថា ទំព័រនេះគឺជាសំណេរផ្ទាល់ដៃរបស់លោកមែនទេ លោក ឡុង នរិន្ទ?

**លោក ឡុង នូរិន្ទ**

**ឆ៖** បាទ, អក្សរខ្ញុំសរសេរខ្លួនឯងហើយអាហ្នឹង។

**ស៖** អ៊ីចឹងខ្ញុំសូមពង្រីកវាទៅផ្នែកខាងលើនៃទំព័រនេះ ហើយខ្ញុំសូមអានអ្វីដែលបានសរសេរនៅលើប្រវត្តិរូបនេះ នៅលើទំព័រនេះ។ នៅផ្នែកខាងលើនៃទំព័រនេះ គឺយើងមានពាក្យថា សរុប ហើយឃ្លានៅខាងក្រោមគឺសរសេរដូចតទៅនេះ ខ្ញុំសូមដកស្រង់៖ "ក្នុងរយៈកាលសិក្សាជីវិតរបស់ខ្ញុំ ក្នុងការទាក់ទង គឺខ្មៅងងឹតស្អុងស្អុបទាក់ទងនឹងពួកដែលក្រោយមក ក្បត់ប្រទេសជាតិ ឬចូលដៃនឹងពួកអាក្បត់ម្យ៉ាងទៀតការរស់នៅក៏មិនស្អាតស្អំ។ ឧទាហរណ៍ គឺខ្ញុំដូរលុយរកស៊ីចងការ មានបាន សីលធម៌នារីបុរសក៏មិនស្អាតស្អំ ដោយសារគុណអង្គការ យើងខ្ញុំបានវិលមករកផ្លូវត្រូវ ផ្លូវបដិវត្តន៍កម្ពុជា។ ខ្ញុំបានខិតខំកសាងខ្លួនតាមការណែនាំរបស់អង្គការ។" អ្វីដែលខ្ញុំចង់សួរលោក នៅពេលនេះ លោក ឡុង នរិន្ទ គឺសូមឲ្យលោកជួយពន្យល់អង្គជំនុំជម្រះថា ហេតុអ្វីបានជាលោកសរសេរឃ្លាទាំងអស់នេះ នៅក្នុងប្រវត្តិរូបរបស់លោកនេះ?

[១០:០៩:០០]

**ឆ៖** ខ្ញុំសរសេរក្នុងហ្នឹងព្រោះចង់បញ្ជាក់ថា ខ្ញុំស្មោះត្រង់ទាំងអស់ គឺអត់មានលាក់លៀមអីទេ។ អង្គាល់ដែលនៅពីជានិស្សិតហ្នឹង វាមានអ៊ីចឹង គឺថា-- ហើយក៏បានចូលធ្វើបដិវត្តន៍ ខំកសាងខ្លួន។

**ស៖** ឃ្លាដែលសរសេរថា លោកមានទំនាក់ទំនងជាមួយពួកដែលក្រោយមកបានក្បត់ប្រទេសជាតិ ឬក៏ចូលដៃជាមួយនឹងពួកអាក្បត់។ តាមរយៈឯកសារនេះ គឺថាមានឯកសារយោងមួយចំនួនដែលប្រើពាក្យថា *ខន់ថេមថេប៊ល* គឺ “អា”នេះឯង ។ សំណួរខ្ញុំសួរថាបន្ថែមទៅលើការទាក់ទងទៅជាមួយនឹង ថាច់ ជា មានអ្នកដទៃទៀតដែលគេបានស្នើឲ្យលោកពន្យល់ ដែលលោកធ្លាប់បានទាក់ទងអ្នកទាំងនោះកាលពីមុនៗមក?

**ឆ៖** បាទ។

**ស៖** ចាតើអ្នកណាដែលប្រាប់លោកថាមនុស្សទាំងនោះ គឺជាប្រភេទមនុស្សក្បត់ដូច្នេះ? អ្នកណាបានប្រាប់លោកថា មនុស្សទាំងនោះគឺជាអ្នកក្បត់ប្រទេសជាតិ ឬចូលដៃជាមួយពួកអាក្បត់ ហើយឲ្យលោកពន្យល់ពាក្យពេចន៍ទាំងអស់នេះនៅក្នុងប្រវត្តិរូបរបស់លោក? អ្នកណាដែលជាអ្នកដែលលោកត្រូវទំនាក់ទំនងជាមួយ និងនិយាយជាមួយនេះ?

**ឆ៖** ខ្ញុំក្រៅពីនេះក្នុងមិត្តភក្តិដែលជិតស្និទ្ធគឺមាន រស់ ពិន ដែលសរសេរជាអ្នកកវី ប៉ុន្តែមិនដឹងសរសេរអត់ទេក្រោយមក។ ង៉ូវ វ៉ា នៅកំពង់ធំ។ គឺដោយសារអង្កាល់ហ្នឹង វានិស្សិតដូចចែកចេញជាពីរក្រុមហើយ គឺថាម្នាក់ មួយក្រុម អាហ្នឹងខ្លួនឯង តាំងខ្លួនឯងទមែនទែន ជាអ្នកស្អាតស្អំ គឺពួកឆ្វេងហ្នឹង ហើយម្នាក់ទៀត ខាងមួយក្រុមទៀតហ្នឹងគឺគេសេរី ខាងក្រុមសេរី។ ដល់អ៊ីចឹងគឺថាក្រុមមួយហៅក្រុមមួយ តែគេមិនចូលក្នុងក្រុមខ្លួន គឺសុទ្ធតែពួកក្បត់ទាំងអស់ហ្នឹង។

[១០:១៣:០០]

**ស៖** សំណួររបស់ខ្ញុំ គឺដូច្នេះទេលោក ឡុង នរិន្ទ។ គឺថាអៀង សារី បានកំណត់អត្តសញ្ញាណរបស់មនុស្សម្នាក់ គឺលោក ថាច់ ជា ដែលលោកបានពន្យល់ថាលោកបានទាក់ទងជាមួយគាត់នោះ។ តើលោកមានបង្ហាញអត្តសញ្ញាណរបស់មនុស្សដទៃទៀត ដែលលោកធ្លាប់មានទំនាក់ទំនងជាមួយកាលពីមុនៗមកទេ?

**ឆ៖** ខ្ញុំភ្លេចហើយ មិនដឹងបានជម្រាបគាត់អត់ទេ។

**ស៖** នៅលើទំព័រដែលខ្ញុំបានបង្ហាញលោកក៏មានការសរសេរអំពីសីលធម៌របស់លោក ដែលលោកថាសីលធម៌របស់លោក គឺមិនស្អាតស្អំទេ។ ហេតុអ្វីក៏លោកចាំបាច់ត្រូវរាយការណ៍ជូនទៅបក្សអំពីសីលធម៌ជាមួយនឹងនារីភេទរបស់លោកនេះ?

**លោក ញ៉ែម សំណាង៖**

អ៊ំៗ យល់ទេអ៊ំ?

**ឆ៖** អត់។

**លោក ញ៉ែម សំណាង៖**

សហព្រះរាជអាជ្ញាសួរថា តើហេតុអីក៏អ៊ំចាំបាច់បង្ហាញអំពីសីលធម៌មិនស្អាតស្អំជាមួយនឹងនារីដទៃទៀត?

[១០:១៤:៥១]

**ឆ៖** អាហ្នឹងគឺមែនទែនទៅ គឺខាងបើយើង អង្កាល់ពេលនុ៎ងគឺថា អ្នកដែលនៅខាង-- ដូចខ្ញុំថា អ៊ីចឹង ខាងឆ្វេងគឺច្រើនតែពួកគេតាំងខ្លួនជាអ្នកស្អាតស្អំ។ ហើយដូច្នោះមួយម្ខាងទៀត ខាងស្តាំហ្នឹងគឺមិនស្អាតស្អំ។ ដូច្នោះខ្ញុំមានមិត្តភក្តិនៅខាងស្តាំក៏មាន នៅខាងឆ្វេងក៏មាន។

**ស៖** តើមានអ្វីកើតឡើងទៅលើក្រុមមនុស្សដែលយល់ថាមិនល្អ ដែលលោកបានរាយការណ៍ថា ជាអ្នកដែលក្បត់ប្រទេសជាតិ ឬក៏ចូលដៃជាមួយនឹងពួកក្បត់ ឬក៏ក្បត់បក្សនោះ មានអ្វីកើតឡើងចំពោះអ្នកទាំងនោះ?

**លោក ញ៉ែម សំណាង៖**

អ៊ំយល់សំណួរទេអ៊ំ?

**ឆ៖** អត់យល់។

[១០:១៦:២២]

**លោក ញ៉ែម សំណាង៖**

សួរថា មានអ្វីកើតឡើងចំពោះអ្នកដែលអ៊ំរាយការណ៍ថា ក្បត់បក្ស? មនុស្សក្បត់ជាតិអ៊ីចឹងណាអ៊ំ?

**ឆ៖** បាទ, មែនទែនទៅអត់មានអីជាកើតឡើងទេ ព្រោះសុទ្ធនៅជានិស្សិតទាំងអស់គ្នាហ្នឹង។ ដូច្នោះចង់ថាអ្នកក្បត់ក៏ចេះតែថាទៅ មិនដឹងច្បាស់។

**ស៖** លោក ឡុង នរិន្ទ ខ្ញុំនិយាយអំពីរយៈពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ តើមានអ្វីកើតឡើងទៅលើអ្នកដែលធ្វើការនៅក្រសួងការបរទេស ដែលត្រូវបានគេរកឃើញថា ជាអ្នកក្បត់ប្រទេសជាតិ ឬក៏ជាអ្នកចូលដៃជាមួយនឹងពួកអាក្បត់?

[១០:១៧:៣២]

**ឆ៖** ដល់ពេល-- ពេលហ្នឹងហើយ គឺថាដូចអត់មានទេ។

**ស៖** ឥឡូវនេះសូមលោកនិយាយអំពីមនុស្សមួយចំនួន ដែលលោកលោកបានរៀបរាប់ឈ្មោះនៅក្នុងប្រវត្តិរូបរបស់លោក?

**ឆ៖** បាទ។

**ស៖** បើសិនជាណាយើងចូលទៅមើលប្រវត្តិរូបជាភាសាខ្មែរ ត្រង់ទំព័រ ០០០៣៧៣៦។ អាចថាលោកមើលត្រង់កថាខណ្ឌ ឃ ទាក់ទងទៅនឹងទំនាក់ទំនង មានពាក្យថា "ទំនាក់ទំនង"។

[១០:១៨:២២]

សូមអភ័យទោសលោកប្រធាន!

**លោក អាកឡូវ វ៉ែកតែន៖**

សូមបញ្ជាក់អំពីលេខទំព័របានទេ ដើម្បីឲ្យយើងអាចតាមទាន់។

[១០:១៩:៥៦]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ឥឡូវនេះ គឺថាខ្ញុំយោងទៅលើទំព័រជាភាសាអង់គ្លេស ០០៣៧-- ហើយជាភាសាបារាំង ០០៧៥៧៣៥៨ ដល់ ០០៣៧៥៨១៦។ មានកថាខណ្ឌមួយនៅក្នុងទំព័រនេះ ដែលលោកបានយោងទៅលើទំនាក់-- លោកមានទំនាក់ទំនងជាមួយមនុស្សមួយចំនួន លោកថាស្ថិតនៅក្នុងក្រុមជាមួយនឹងលោក សារិន ចក់ តើលោក-- ខ្ញុំប្រហែលជាគិតថាខ្ញុំអានត្រូវឈ្មោះនេះ ខ្ញុំអាចអានត្រូវ គឺ សារិន ឆាក នេះ តើ សារិន ឆាក នេះជាអ្នកណាដែរ?

[១០:២០:៥៧]

**លោក ឡុង នរិន្ទ៖**

**ឆ៖** សារិន ឆាក ជារដ្ឋមន្ត្រីការបរទេសអង្គាល់សម័យព្រះករុណា សីហនុ នៅប៉េកាំង។

**ស៖** ហើយនៅពេលដែលលោកនិយាយអំពីក្រុមរបស់គាត់ ឬក៏ពួករបស់គាត់នេះ តើលោកមានន័យថាយ៉ាងដូចម្ដេចដែរ?

**ឆ៖** អង្គាល់ដែលខ្ញុំនិយាយពីៗគាត់ ពី សារិន ឆាក អង្គាល់ហ្នឹងព្រោះខ្ញុំធ្វើការនៅក្រសួងការបរទេស ក៏ សារិន ឆាក នៅដែរ។

[១០:២២:១២]

**លោក អាកឡូរ វែកគែន៖**

បាទ, លោកប្រធាន ខ្ញុំសូមរំខានបន្តិចទៀត ទាក់ទងនឹងឯកសារដែលឲ្យជាភាសាបារាំងនេះ ខ្ញុំអត់មានលេខ ERN នោះទេ។ អ៊ីចឹងខ្ញុំមិនអាចតាមសវនាការហ្នឹងបានទេ ការពិភាក្សាដេញដោលនេះនោះ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បាទ គឺទំព័រ៧ លើ ១៧ លេខ ERN គឺថានៅលើគេទាំងអស់នៅខាងឆ្វេងដៃលេខ ERN នោះ។ ទំព័រ ៧ លើ ១៥។

[១០:២៥:១៧]

**ប្រធានអង្គជំនុំ៖**

លោកសហព្រះរាជអាជ្ញាអាចបន្តបានហើយ!

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** សំណួរដែលខ្ញុំចង់ព្យាយាមសួរទៅលោកនេះ លោក ឡុង នរិន្ទ គឺមនុស្សទីមួយដែលលោកបានបង្ហាញឈ្មោះនៅក្នុងកថាខណ្ឌដែលយើងកំពុងមើលនេះ គឺលោក ទេព សំអាន លោកអាចជម្រាបខ្ញុំបានទេ តើលោក ទេព សំអាន ហ្នឹងជាអ្នកណាដែរ?

**លោក ឡុង នរិន្ទ៖**

**ឆ៖** ទេព សំអាន!

**លោក ញ៉ែម សំណាង៖**

តើជានរណាអ៊ំ?

**ឆ៖** សំអាន ហ្នឹងមែនទែនទៅគាត់ជាអ្នកធ្វើការៗជាសមាជិកទូតចាស់នៅ ដូចនៅអេហ្ស៊ីប មិនដឹងនៅ មែនទែននៅអាហ្វ្រិក។ គឺគាត់នៅក្នុង-- គាត់ធ្លាប់ធ្វើការជាមួយនឹងលោក សារិន ឆាក ដែរ។ ដល់មកប៉េកាំង គាត់មកជាមួយគ្នាហ្នឹងដែរ។

[១០:២៧:០២]

**ស៖** ថាតើគាត់ជា កាលនោះគាត់ជាឯកអគ្គរដ្ឋទូតទៅកាន់ប្រទេសអាល់បានី ឬក៏យ៉ាងម៉េច? ស៊ុំកែ គឺគាត់ជាឯកអគ្គរដ្ឋទូតទៅកាន់ប្រទេសអាល់សេរី មែនទេ? គឺលោក ទេព សំអាន នេះឯង។

**ឆ៖** មិនមែនឯកអគ្គរដ្ឋទូត គាត់ដូចជាលេខាទីបី ឬទីពីរ អ៊ីចឹង ខ្ញុំមិនដឹង។ ឬក៏ជាអាតាសេខាង -- *អាតាសេគុលដឺវ៉េ* មិនដឹង *អាតាសេកុំ* នែខាង *កុំមែហ្សេល* ក៏មិនដឹង។

**សៈ** នៅក្នុងឆ្នាំ១៩៧៦ តើគាត់ស្ថិតនៅប្រទេសអាល់សេរី ដដែល ឬក៏គាត់បានវិលត្រឡប់មកកម្ពុជាវិញហើយ?

**ឆ៖** គាត់ត្រឡប់មកកម្ពុជាវិញហើយ។

**សៈ** ហើយនៅក្នុងឆ្នាំ១៩៧៦ តើគាត់ធ្វើការនៅក្រសួងការបរទេសមែនទេ?

[១០:២៨:៣២]

**ឆ៖** ក្នុង៧៦ ហ្នឹង គាត់ត្រឡប់មកស្រុកវិញ ក៏ប៉ុន្តែអ្នកដែលមកស្រុកហ្នឹង គឺថាមកត្រូវចូលប៉េកាំងសិន។ ដូច្នោះគាត់ធ្វើការនៅក្រសួងការបរទេស នៅប៉េកាំង អង្កាល់ហ្នឹង។

**សៈ** ហើយបន្ទាប់ពីគាត់ត្រឡប់មកកម្ពុជាវិញ មកពីប៉េកាំងមក គាត់ តើគាត់ធ្វើការនៅក្រសួងការបរទេសនៅភ្នំពេញ មែនទេ?

**ឆ៖** ខ្ញុំមិនចាំទេ។

**សៈ** លោក ឡុន នរិន្ទ បញ្ជីអ្នកទោសនៅមន្ទីរស-២១ គឺបាននៅចំណុចត្រង់ឃ្លា២៦-១ គឺថាបានឃើញឈ្មោះ ទេព សំអាន នេះគឺបានចូលទៅមន្ទីរស-២១ នៅថ្ងៃទី២៣ តុលា ៧៦។ ដូច្នេះមុនខែតុលា ១៩៧៦ នេះ តើគាត់នៅធ្វើការក្រសួងការបរទេសឬ?

[១០:៣០:១៤]

**ឆ៖** ហ្នឹងខ្ញុំមិនច្បាស់ទេ។ ពីព្រោះមកដល់ស្រុកខ្មែរទៅហើយហ្នឹងគឺគាត់ ប៉ុន្តែគាត់ដូចអត់មកចូលនឹងក្រសួងការបរទេស ដែលលោក អៀង សារី គ្រប់គ្រងទៅហើយទេ។

**សៈ** តើលោកមានបានដឹងទេ នៅពេលដែលលោកសរសេរប្រវត្តិរូបរបស់លោកនេះ? លោកមានបានដឹងថា លោក ទេព សំអាន គឺជាមនុស្សម្នាក់ដែលត្រូវបានគេបោសសម្អាត ត្រូវបានចាប់ខ្លួនដោយបក្ស?

**ឆ៖** ខ្ញុំអត់បានដឹងទេ។

[១០:៣១:២៧]

**សៈ** តើលោកមានការភ្ញាក់ផ្អើលទេ ដែលថាមនុស្សមួយចំនួនដែលលោករៀបរាប់ឈ្មោះនៅក្នុងប្រវត្តិរូបរបស់លោកនោះ គឺថាត្រូវបានគេចាប់ខ្លួនបញ្ជូនទៅមន្ទីរសន្តិសុខ ស-២១?

**ឆ៖** ខ្ញុំអត់បានដឹងទេ។

**ស៖** នៅក្នុងកថាខណ្ឌដដែលនេះ គឺលោកមាននិយាយឈ្មោះ វ៉ាន់ ពីនី ថាតើលោក វ៉ាន់ ពីនី នេះជាអ្នកណាដែរ?

**ឆ៖** លោក វ៉ាន់ ពីនី ហ្នឹងអង្គាល់ពីមុននុ៎ង គឺគាត់ធ្វើការជាលេខា ដូចលេខាទីពីរក៏ មិនដឹងទេ ទូតនៅអេហ្ស៊ីប ហើយដល់នេះមកៗស្រុកខ្មែរ លោកមកចូលនៅប៉េកាំង ដែលធ្វើការនៅក្រសួងការបរទេសដែរ។

[១០:៣៣:១៣]

**ស៖** តើលោក វ៉ាន់ ពីនី នេះគាត់ស្ថិតនៅក្នុងប្រទេសអេហ្ស៊ីបឬ កាលពីក្នុងចន្លោះឆ្នាំ១៩៧៦ ទៅដល់ ១៩៧៧?

**ឆ៖** ខ្ញុំអត់ចាំទេ។

**ស៖** តើលោកនៅចាំទេថា ហេតុអីចាំបាច់លោកត្រូវពន្យល់អំពីទំនាក់ទំនងរបស់លោកជាមួយនឹងលោក វ៉ាន់ ពីនី នៅក្នុងប្រវត្តិរូបរបស់លោក?

**ឆ៖** ក្នុងពេលថា ធ្វើការនៅប៉េកាំងហ្នឹង មានអ្នកណាៗខ្លះនៅហ្នឹង។

**ស៖** អ្នកណាដែលស្នើឲ្យលោកពន្យល់បែបនេះ?

[១០:៣៤:៤៩]

**លោក ញ៉ែម សំណាង៖**

អ៊ំយល់សំណួរទេ អ៊ំ?

[១០:៣៤:៥៤]

**ឆ៖** បាទ, កំពុងតែគិត មិនដឹងជានរណា។ មិនដឹងជានរណាស្នើឲ្យទេជា ឯកសារមក។

**ស៖** តើជាកម្មាភិបាលដែលលោកធ្វើការជាមួយនៅក្រសួងការបរទេសនោះឬ ដែលៗបើសូមឲ្យលោកបញ្ជាក់អំពីទំនាក់ទំនងនេះ?

**ឆ៖** ដូចអត់ទេ អង្គាល់គេកាត់តែម្តង ដែលថាមកនេះអត់ទេ។ អត់អ្នកណាស្នើអីស្អីៗ។

**ស៖** មើលទៅហាក់បីដូចជាលោកមានៗមានភាពស្ទាក់ស្ទើរបន្តិចក្នុងការផ្តល់សក្ខីកម្មនេះ តើមានអ្វីដែលធ្វើឲ្យលោកស្ទាក់ស្ទើរក្នុងការផ្តល់សក្ខីកម្មនៅក្នុងថ្ងៃនេះទេ លោក ឡុង នរិន្ទ?

**ឆ៖** អត់មានអី។

**សៈ** អ៊ីចឹងមានន័យថាលោកមិនមានភាពស្ទាក់ស្ទើរ ក្នុងការផ្តល់សក្ខីកម្មប្រឆាំងទៅនឹងអតីតចៅហ្វាយនាយរបស់លោកទេឬ គឺលោក អៀង សារី នេះឯង?

**ឆៈ** បាទ, អត់មានអីស្ទាក់ស្ទើរទេ។ បើខ្ញុំចាំថាចាំ។

**សៈ** លោក ខ្ញុំសូមត្រឡប់ទៅចម្លើយរបស់លោកដែលលោកបានផ្តល់មកឲ្យសហចៅក្រមស៊ើបអង្កេតកាលពីពីរបីឆ្នាំមុននេះ ប៉ុន្តែមុននឹងចូលទៅដល់ចំណុចនេះ ខ្ញុំចង់និយាយអំពីទំនាក់ទំនងរបស់លោកជាមួយនិងលោក អៀង សារី។ គាត់ អៀង សារី គឺជាមនុស្សម្នាក់ដែលលោកបានស្គាល់ជិត ៤០ឆ្នាំមកហើយ តើនេះត្រឹមត្រូវទេ? សូមកែប្រែ អ្នកបកប្រែសុំកែប្រែ លោក អៀង សារី-- បាទ អ្នកបកប្រែសូមកែប្រែ តើលោក អៀង សារី គឺជាមនុស្សម្នាក់ដែលលោកបានស្គាល់ជាងបួនឆ្នាំមកហើយ តើមែនទេ? បាទ ខ្ញុំសូមសួរសំណួរឡើងវិញ សំណួរគឺថាតើលោកបានស្គាល់លោក អៀង សារី ជិតបួនឆ្នាំមែនទេ?

**ឆៈ** បាទ។ ពីព្រោះអង្គាល់ដែលរាជរដ្ឋាភិបាលនៅប៉េកាំងនោះ អង្គាល់ហ្នឹងគឺគាត់ក៏ជាវីរជនលោក អៀង សារី លោកជាអ្នកពិសេសដែរ ដូចតំណាងពិសេសរបស់ការតស៊ូនៅខាងក្នុងប្រទេស។

**សៈ** ហើយលោក អៀង សារី គឺជារដ្ឋមន្ត្រីក្រសួងការបរទេសនៅក្នុងអំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យនៅពេលដែលលោកនៅធ្វើការនៅក្រសួងនេះ។ តើនេះត្រឹមត្រូវទេ?

**ឆៈ** បាទ។

**សៈ** ហើយ តើទំនាក់ទំនងរបស់លោកជាមួយនឹង អៀង សារី នៅតែមានទំនាក់ទំនងជាមួយគ្នាបន្តទៀតទេ បន្ទាប់ពី៧ មករា ១៩៧៩ មក?

[១០:៣៩:៣២]

**ឆៈ** បាទ ដល់ក្រោយ៧ មករា មកអត់មានការទាក់ទងអីទៀតទេ ពីព្រោះគាត់នៅក្នុង គាត់រស់នៅក្នុងគ្រួសារគាត់ទៅ ហើយខ្ញុំមានប្រពន្ធមករស់នៅគ្រួសារខ្ញុំមក។

**ប្រធានអង្គជំនុំ៖**

អរគុណអ៊ំ ឡុង នរិន្ទ។ ឥឡូវហ្នឹងដល់ពេលសមល្មមនឹងឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក ២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោង១១ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការនីតិវិធីបន្តទៅទៀត។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៤០ នាទី ដល់ម៉ោង ១១:០៣ នាទី)*

[១១:០៣:៣២]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការដេញដោលលើសាក្សី ឡុង នរិន្ទ។

សួស្តីលោក ឡុង នរិន្ទ។

**លោក ញ៉ែម សំណាង៖**

ឮទេអ៊ំ ឮចៅក្រមសួរទេអ៊ំ?

ឮៗលោកចៅក្រមសួរទេអ៊ំ?

**លោក ឡុង នូរិន្ទ៖**

អ៊ំមិញនេះ។

**ប្រធានអង្គជំនុំ៖**

ហើយសំណាងអម្បាញ់មិញនៅក្នុងពេលសម្រាកអង្គជំនុំជម្រះបានអនុញ្ញាតឲ្យការរៀបចំផលិតនូវឯកសារជាក្រដាសហ្នឹងឲ្យទៅលោក ឡុង នរិន្ទ ហ្នឹងអាចធ្វើបានទេអំមិញហ្នឹង?

**លោក ញ៉ែម សំណាង៖**

សហការីម្នាក់ទៀតដែល សុខា កំពុងតែទៅកន្លែងព្រីនហើយលោកប្រធាន។ អត់ទាន់ដឹងព័ត៌មានថាបាន ឬក៏មិនបានយ៉ាងម៉េចអត់ទាន់ដឹង លោកប្រធានចាំបន្តិចទៀតប្រហែលជា៥នាទីទៀតដឹងហើយ។

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណ។ ហើយពេលណាបានប្រាប់មកខ្ញុំណា។

**លោក ញ៉ែម សំណាង៖**

បាទ, លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

ហើយជាបន្តសូមប្រគល់វេទិកាទៅសហព្រះរាជអាជ្ញាដើម្បីបន្តការសួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

[១១:០៤:៥៩]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ នៅពេលដែលយើងឈប់អម្បាញ់មិញលោក ឡុង នរិន្ទ បានជម្រាបយើងខ្ញុំថា លោកមិនមានការទាក់ទងជាមួយនឹងលោក អៀង សារី ទៀតទេក្រោយពីការបញ្ចប់របបកម្ពុជាប្រជាធិបតេយ្យ។

**ស៖** តើមែនដែរឬទេ? ខ្ញុំស្តាប់ឮអ៊ីចឹងមែនដែរឬទេ?

ខ្ញុំសូមសួរម្តងទៀត។ តើខ្ញុំស្តាប់ឮដូច្នេះដែរឬទេ នៅពេលដែលមុនឈប់សម្រាកហ្នឹង លោកអ៊ំបានជម្រាបថា លោកអ៊ំអត់មានទាក់ទងជាមួយនឹងលោក អៀង សារី ទៀតទេក្រោយពីការបញ្ចប់របបកម្ពុជាប្រជាធិបតេយ្យក្រោយថ្ងៃទី៧ មករា ឆ្នាំ១៩៧៩ តើមែនដែរឬទេ?

**លោក ឡុង នរិន្ទ៖**

**ឆ៖** (មិនឮសំឡេង)

**ស៖** តើលោកអាចជម្រាបតុលាការថាតើចលនារបស់ជាតិកម្ពុជាប្រជាធិបតេយ្យ គឺយើងហៅថា *ឌីណឹម* (DNUM) នេះ តើវាជាអ្វីដែរ?

**លោក ញ៉ែម សំណាង៖**

ចលនាប្រជាធិបតេយ្យដែលហៅកាត់ថា *ឌីណឹម* (DNUM)។

**ឆ៖** ចង់ថាចលនាប្រជាធិបតេយ្យហ្នឹង?

**លោក ញ៉ែម សំណាង៖**

សូមអធ្យាស្រ័យ សូមលើកសំណួរម្តងទៀតដោយសាក្សីយល់មិនបានច្បាស់។ សូមអនុញ្ញាតទាន។

[១១:០៧:២០]

**ស៖** ខ្ញុំឱ្យលោកជួយពន្យល់ជូនតុលាការថាតើចលនាបង្រួបបង្រួមជាតិប្រជាធិបតេយ្យ *ឌីណឹម* ហ្នឹងជាអ្វីដែរ?

**ឆ៖** ចលនាមែនទែនទៅ-- កម្ពុជាប្រជាធិបតេយ្យរបស់-- តាមពិតទៅ--

**ស៖** ខ្ញុំសូមសួរម្តងទៀតលោក ឡុង នរិន្ទ។ សំណួររបស់ខ្ញុំចង់សួរថា សូមឲ្យលោកជួយជម្រាបតុលាការថា *ឌីណើម* ឬក៏ចលនារួបរួមជាតិប្រជាធិបតេយ្យនេះជាអ្វីដែរ?

[១១:០៩:៣៥]

**ឆ៖** បាទ អាហ្នឹងជាចលនាហ្នឹង គឺជាចលនានយោបាយទេ គឺថាយើងខំធ្វើយ៉ាងម៉េចឲ្យជាតិយើងបានរួបរួមគ្នា ពីព្រោះជាតិយើងកាលណារួបរួមគ្នាខ្លាំង។ អត់រួបរួមគ្នាទេ បាក់បែក គឺដូចសម័យក្រោយអង្គរហ្នឹងអ៊ីចឹង។ អត់ដែលប្រជុំ ដែលប្រជអីទេ។

**ស៖** ដូច្នេះ វាជាចលនានយោបាយ។ សូមលោកជម្រាប ថាតើអ្នកណាជាអ្នកបង្កើតចលនានយោបាយនេះឡើង ហើយគេបង្កើតនៅក្នុងឆ្នាំណាដែរ? នៅពេលណាដែរ?

**ឆ៖** មែនទែនទៅ ចលនាហ្នឹងគឺថា ស្តី(?) គាត់យកប្រធាន ហើយខ្ញុំជាគណៈលេខាធិការ (ឮមិនច្បាស់)។

**ស៖** ថាតើលោក អៀង សារី មានតួនាទីអ្វីដែរនៅក្នុងចលនានុ៎ង?

**ឆ៖** ក្នុងចលនាហ្នឹង គឺគាត់ជាប្រធាន។

**ស៖** តើនៅក្នុងអំឡុងពេលណាដែរ ដែលលោកជាគណៈលេខាធិការនៃចលនារួបរួមជាតិប្រជាធិបតេយ្យនោះ?

**ឆ៖** តាំងពីបង្កើតមកហ្មង?

**ស៖** តើនេះជាចលនាដែលបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៩៤ នៅពេលដែលលោក អៀង សារី ផ្តាច់ខ្លួនចេញពីមេដឹកនាំខ្មែរក្រហមផ្សេងនោះ មែនដែរឬទេ?

**ឆ៖** បាទ, ពេលហ្នឹងហើយ។

[១១:១២:៣៥]

**ស៖** តើចលនានេះ នៅមាននៅមកទល់សព្វថ្ងៃនេះដែរឬទេ?

**លោក ញ៉ែម សំណាង៖**

តើចលនាហ្នឹង មានរហូតមកដល់សព្វដែរឬទេ?

**ឆ៖** បាទ, បើជាទស្សនៈគឺមាន ក៏ប៉ុន្តែជាក់ស្តែងអត់មានបញ្ហូល។

**ស៖** តាមទ្រឹស្តី តាមទស្សនៈ ថាតើលោក អៀង សារី នៅតែជាប្រធាននៃចលនារួបរួមជាតិប្រជាធិបតេយ្យនោះទៀតដែរឬទេ?

**ឆ៖** ចលនានេះ កើតមករហូតអ៊ីចឹងមក គឺមែនទែនអត់មានអីប្រជុំប្រជអី ហើយឲ្យមានសកម្មភាពអីឲ្យច្បាស់លាស់ ឲ្យជាក់ស្តែងនោះ អត់ទាន់មានទេ។

**ស៖** ក្រៅពីការអាន តើលោកមានទំនាក់ទំនងអ្វីផ្សេងទៀតជាមួយនឹងលោក អៀង សារី ដែរឬទេនៅក្នុងចលនាបង្រួបបង្រួមជាតិប្រជាធិបតេយ្យនុ៎ង?

**ឆ៖** ក្នុងចលនាហ្នឹង បើយុទ្ធសាស្ត្រ គឺលោក អៀង សារី គាត់ជាប្រធានចលនា ហើយខ្ញុំជាគណៈលេខាធិការចលនាហ្នឹង។

**លោក ញ៉ែម សំណាង៖**

សូមជម្រាបប្រសាសន៍លោកប្រធាន ឯកសារមានមកដល់ដៃខ្ញុំហើយ ហើយបានប្រគល់ជូនសាក្សីហើយ លោកប្រធាន។

[១១:១៤:៤៥]

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណ។ ហើយឯកសារនេះ អាចប្រើប្រាស់នៅពេលដែលភាគី ឬដទៃទៀត ដែលមានការសួរនាំដល់ទាក់ទងជាមួយនឹងឯកសារហ្នឹង យើងពិនិត្យទៅតាមជាក់ស្តែងនៃទំព័រ ឬក៏កថាខណ្ឌដែលមានការផ្គុះដើម្បីយកមកដេញដោល ហើយ សំណាង ឯងជួយសម្រួលដល់គាត់ពីបញ្ហានោះផង។

**លោក ញ៉ែម សំណាង៖**

បាទៗ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមព្រះរាជអាជ្ញាបន្តសំណួរទៀតចុះ!

[១១:១៥:១៩]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោក ឡុង នរិន្ទ លោកគឺជាអគ្គលេខាធិការ ហើយលោក អៀង សារី គឺជាប្រធានចលនានោះ។ ថាតើលោកបានធ្វើទំនាក់ទំនងអំពីចលនានេះ ឬក៏មិនបានធ្វើទំនាក់ទំនងពីចលនានេះជាមួយនឹងលោក អៀង សារីទេ?

**លោក ឡុង នរិន្ទ៖**

**ឆ៖** តាំងពីបង្កើតមកណា៎ មិនមានការអីដែលត្រូវបានប្រជុំជាមួយគ្នាពីរឿងចលនាហ្នឹងទេ។ មែនទែនអត់មានទាក់ទង។ ឥឡូវនេះខ្ញុំមិនដឹងគាត់នៅឯណាផង។ នៅភ្នំពេញក៏មិនដឹង នៅប៉ៃលិនក៏មិនដឹង នៅម៉ាឡៃអត់នៅ។

[១១:១៦:៣១]

**ស៖** ថាតើលោកអ៊ំក្លាយទៅជាអគ្គលេខាធិការនៃចលនានោះដោយយ៉ាងម៉េចដែរ បានក្លាយទៅជាអគ្គលេខាធិការនៃចលនានុ៎ង?

**ឆ៖** គាត់ថាម៉េច?

**លោក ញ៉ែម សំណាង៖**

ថាតើអ៊ំក្លាយទៅជាអគ្គលេខាធិការនៃចលនានុ៎ង ដោយយ៉ាងម៉េចដែរអ៊ំ?

**ឆ៖** មែនទែនទៅ គឺថាលោក អៀង សារី គាត់បង្កើតចលនាហ្នឹងមក ហើយគាត់ជាប្រធានទៅ ហើយខ្ញុំជាអគ្គលេខាធិការហ្នឹងទៅ។ តាមពិតធ្វើសកម្មភាពអីឲ្យនេះនោះ ឲ្យជាជាក់ស្តែងនោះអត់មានទេ។

**ស៖** ខ្ញុំសូមចូលសួរទៅដល់ចំណុចផ្សេងទៀត។ តើលោកអាចជម្រាបអង្គជំនុំជម្រះ ដែលឬទេថាតើក្រុមហ៊ុនពាណិជ្ជកម្មម៉ាឡៃហ្នឹង គឺជាអ្វីដែរ?

**លោក ម៉ៃខល កាណាវាស៖**

មុនពេលដែលឆ្លើយទៅនឹងសំណួរ ហើយខ្ញុំសូមសួរ ថាតើសហព្រះរាជអាជ្ញានោះ គាត់គិតថាតើក្រុមពាណិជ្ជកម្មម៉ាឡៃហ្នឹង វាមានការពាក់ព័ន្ធគ្នាទៅនឹងប្រវត្តិនៃកម្ពុជាប្រជាធិបតេយ្យនោះដោយរបៀបណា? ដោយសារតែក្នុងកថាខណ្ឌនេះ គឺមានព័ត៌មានតែបន្តិចបន្តួចតែប៉ុណ្ណោះដែលពាក់ព័ន្ធ។

[១១:១៨:២៨]

**លោក ឌេល លីសា៖**

សំណួររបស់ខ្ញុំនេះ គឺវាមានការបង្ហាញយ៉ាងច្បាស់លាស់អំពីភាពជឿជាក់របស់អ្នក-- រវាងទំនាក់ទំនងរបស់ជនជាប់ចោទ និងរបស់សាក្សី។

**លោក ម៉ៃខល កាណាវាស៖**

គឺវាមិនបង្ហាញឃើញយើងច្បាស់នោះទេ។ ខ្ញុំសូមឲ្យសហព្រះរាជអាជ្ញាធ្វើការបង្ហាញឲ្យបាន

ច្បាស់លាស់ ថាតើផ្នែកនៅក្នុងផ្នែកកន្លែងណា ដែលខាងសហព្រះរាជអាជ្ញាបានចង្អុលបញ្ជាក់ពាក់ព័ន្ធទៅនឹងចំណុចនេះនោះ?

**ប្រធានអង្គជំនុំ៖**

អញ្ជើញសហព្រះរាជអាជ្ញាបង្ហាញ! បង្ហាញសិនណ៎ាមុននឹងដាក់ដេញដោល។

**លោក ឌេល លីសាក់៖**

ខ្ញុំសូមធ្វើការបង្ហាញ។ យើងឃើញថា នៅពេលនេះសាក្សីគាត់ហាក់មានភាពស្ទាក់ស្ទើរក្នុងការផ្តល់ចម្លើយ និងសក្ខីកម្ម។ ដូច្នេះហើយ គឺខ្ញុំចង់សួរគាត់ទៅលើដំណាក់កាលមុនពេលដែលគាត់មកផ្តល់ចម្លើយនៅក្នុងដំណាក់កាលស៊ើបសួរ រហូតមកដល់ពេលដែលគាត់ចូលមកដល់សវនាការនេះ។

[១១:១៩:៥៤]

ដូច្នេះសំណួរនេះ គឺវាពាក់ព័ន្ធថាតើសាក្សីរូបនេះ គឺនៅតែមានទំនាក់ទំនងទៀតដែរឬទេ ជាមួយនឹងលោក អៀង សារី ក្រោយពីរបបកម្ពុជាប្រជាធិបតេយ្យ? សំណួរនេះ គឺវាអាចផ្តល់ជាហេតុផលចំពោះលោក អៀង សារី មកដល់រយៈពេលនេះ។ វាមានបញ្ហាពាក់ព័ន្ធទៅនឹងលោក អៀង សារី ជាមួយនឹងចលនានេះ ហើយនិងស្ថាប័នដែលសាក្សី និងលោក អៀង សារី គាត់មានការចាប់អារម្មណ៍ ហើយសំណួរនេះ វាបង្ហាញអំពីទំនាក់ទំនង និងហេតុផលដែលថាសាក្សីហាក់ដូចជាមានភាពស្ទាក់ស្ទើរក្នុងការបង្ហាញចម្លើយ និងផ្តល់ចម្លើយពាក់ព័ន្ធទៅនឹងរយៈកាលដែលពាក់ព័ន្ធនោះ។

[១១:២០:៤៥]

**លោក ម៉ៃខល កាណាវាស៖**

ខ្ញុំសូមធ្វើការឆ្លើយតបទៅលើបញ្ហានេះ។ សាក្សីដែលថា គាត់មានភាពស្ទាក់ស្ទើរក្នុងការផ្តល់សក្ខីកម្មនោះ គឺប្រសិនបើគាត់ស្ទាក់ស្ទើរនោះ គឺគាត់នឹងមិនផ្តល់សក្ខីកម្មនោះទេ មិនដូចពេលនេះឡើយ។ ខ្ញុំលើកឡើងករណីដែលថា សហព្រះរាជអាជ្ញាលើកឡើងថា សាក្សីមានការស្ទាក់ស្ទើរ។ ប្រសិនបើសហព្រះរាជអាជ្ញាគាត់ចង់លើកឡើងអំពីភាពស៊ីសង្វាក់គ្នានោះ គឺអាចលើកទៅបាន។ ក្រោយពីនេះ គឺយើងមិនអាចចូលទៅដល់ការលើកឡើងថា សាក្សីនេះមានភាពស្ទាក់ស្ទើរនៅឡើយ។ សាក្សីរូបនេះ គឺមិនមែនថា គាត់មានការកុហក ដើម្បីការពារទៅដល់លោក អៀង សារី នោះឡើយ។ នៅក្នុងពេលនេះ សហព្រះរាជអាជ្ញាហាក់ដូចជាកំពុងតែបង្ហាញ និងចង់លើកឡើងថា សាក្សីរូបនេះមានការស្ទាក់ស្ទើរក្នុងការឆ្លើយ និងផ្តល់សក្ខីកម្ម។ ក៏ប៉ុន្តែយើងត្រូវពិចារណា និងយកចិត្តទុកដាក់ទៅលើស្ថានភាព

សុខភាពរបស់ជនជាប់ចោទនេះ-- សាក្សីរូបនេះ ហើយនិងរយៈកាលដែលវាកន្លងមកយូរមកហើយ។

ដូច្នេះហើយយើងមិនអាចធ្វើការសន្និដ្ឋានដូចបែបនេះឡើយ យើងអាចធ្វើការពិនិត្យទៅលើផ្នែកដែលពាក់ព័ន្ធ ហើយយើងអាចធ្វើការស្នើសុំឲ្យពិនិត្យផ្នែកផ្សេងដែលនៅក្រៅវិសាលភាពនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ប្រសិនបើគាត់ធ្វើដូច្នេះ ខាងសហព្រះរាជអាជ្ញាវាហាក់ដូចជាបង្ហាញនូវភាពលម្អៀងទៅដល់សាក្សី យើងមិនអាចចូលទៅដល់ផ្នែកផ្សេងទៀតនោះឡើយ។

**ប្រធានអង្គជំនុំ៖**

ជំទាស់មានប្រសិទ្ធភាព។ អង្គជំនុំជម្រះមិនចាំបាច់ស្តាប់នូវចម្លើយពីសាក្សីនៅសំណួរនេះទេ។ អ៊ីចឹងសហព្រះរាជអាជ្ញា អាចបន្តនូវសំណួរផ្សេងទៀត។

[១១:២២:៥៨]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន ខ្ញុំនឹងទទួលយកនូវអ្វីដែលបានលើកឡើងដោយខាងមេធាវីកាណាវាស។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី ឡុង នរិន្ទ តើលោកចាំទេថា មានបុគ្គលិកមកពីខាងការិយាល័យសហចៅក្រមស៊ើបអង្កេតចុះទៅស្តាប់ចម្លើយរបស់លោកនៅក្នុងខែធ្នូ ឆ្នាំ២០០៧?

**លោក ញ៉ែម សំណាង៖**

អ៊ំយល់សំណួរទេអ៊ំមិញ?

**លោក ឡុង នរិន្ទ៖**

**ឆ៖** បាទ?

**លោក ញ៉ែម សំណាង៖**

អ៊ំយល់សំណួរទេអ៊ំមិញ?

**ឆ៖** អត់យល់ គាត់ៗចង់សួរម៉េចពីឆ្នាំ២០០៧?

**លោក ញ៉ែម សំណាង៖**

សួរថា តើអ៊ំមានបានចាំទេថា មានបុគ្គលិកមកពីៗការិយាល័យសហចៅក្រមស៊ើបអង្កេតណាមកជួបអ៊ំនៅក្នុងកំឡុងឆ្នាំ២០០៧ តើអ៊ំមានចាំទេអ៊ំ?

**ឆ៖** អត់ចាំទេ។

[១១:២៤:២៥]

**ស៖** មុនពេលដែលលោកអ៊ំមកតុលាការនេះ ផ្តល់សក្ខីកម្ម តើលោកអ៊ំមានត្រូវបានបុគ្គលិកខាងតុលាការបង្ហាញនូវកំណត់ហេតុនៃការស្តាប់ចម្លើយដែលបានធ្វើឡើងនៅក្នុងខែធ្នូ ឆ្នាំ២០០៧ ដែរឬទេ?

**ឆ៖** ខ្ញុំមែនទែន ជួនកាលអាចមកសួរខ្ញុំ ប៉ុន្តែខ្ញុំមិនបានចាប់អារម្មណ៍ថា ជាខាងថៅក្រមស៊ើបអង្កេតរបស់តុលាការទេទេ។

**ស៖** លោកអ៊ំចាំថា មានគេមកពីខាងតុលាការ ទៅចុះជួបអ៊ំស្តាប់ចម្លើយអ៊ំ មែនដែរឬទេ?

**លោក ញ៉ែម សំណាង៖**

អ៊ំស្តាប់បានសំណួរទេ?

**ឆ៖** បាន។ ប៉ុន្តែមែនទែនទៅ ២០០៧ ហ្នឹង ដឹងថាមានគេមកសួរខ្ញុំ ឬអត់យ៉ាងម៉េច ខ្ញុំភ្លេចទៅអត់ចាំ។

**ស៖** តើនៅពេលថ្មីៗនេះ លោកអ៊ំមានបានមើលចម្លើយ ដែលលោកអ៊ំបានឆ្លើយជូនតុលាការដែរឬទេ?

**ឆ៖** *(ឮមិនច្បាស់)*

[១១:២៦:៣៨]

**ស៖** តើលោកអ៊ំមានការនិយាយដោយស្មោះត្រង់ និងការពិតដែរឬទេ នៅពេលដែលបុគ្គលិកពីខាងតុលាការចុះទៅស្តាប់ចម្លើយអ៊ំនោះ?

**លោក ញ៉ែម សំណាង៖**

ស្តាប់បានសំណួរទេអ៊ំ?

**ឆ៖** បាទ។ ប៉ុន្តែមិនដឹងជាគេមកសួរ (ឮមិនច្បាស់) ខាងថៅក្រមហ្នឹងចុះមកសួរពីអង្កាល់ណាថ្មីៗ?

**ស៖** ខ្ញុំមិនមែនសួរថា គេសម្ភាសន៍អ៊ំនាពេលថ្មីៗនោះទេ។ ខ្ញុំចង់សួរលោកអ៊ំថា តើលោកអ៊ំបានមើលកំណត់ហេតុនៃការផ្តល់ចម្លើយរបស់លោកអ៊ំ ដែលលោកអ៊ំបានផ្តល់ជូនតុលាការនាពេលថ្មីៗនេះដែរឬទេ?

[១១:២៧:៣០]

**ឆ៖** អត់បានមើលទេ។

**ស៖** សំណួរ ខ្ញុំសួរសំណួរមួយទៀត។ នៅពេលដែលមានមនុស្សពីតុលាការ ទៅស្តាប់ចម្លើយលោកអ៊ំនោះ តើលោកអ៊ំនិយាយដោយស្មោះត្រង់ ដោយការពិតដែរឬទេ?

**លោក ញ៉ែម សំណាង៖**

យល់សំណួរទេអ៊ំ?

**ឆ៖** ខ្ញុំអត់យល់។

**លោក ញ៉ែម សំណាង៖**

នៅពេលដែលមន្ត្រីស៊ើបអង្កេតមកសួរអ៊ំ តើអ៊ំឆ្លើយទៅនឹងមន្ត្រីស៊ើបអង្កេតនោះ ដោយស្មោះត្រង់ដែរឬទេ?

**ឆ៖** អ៊ូ! ខ្ញុំឆ្លើយដោយស្មោះត្រង់។

[១១:២៨:៤៩]

**ស៖** លោកប្រធាន ថាតើយើងដឹងថា អង្គភាពគាំពារជនរងគ្រោះមានកំណត់ហេតុស្តាប់ចម្លើយសាក្សីរូបនេះដែរឬទេ នៅពេលនេះ ដែលគាត់បានផ្តល់ជូនទៅដល់សាក្សីហ្នឹង?

**ប្រធានអង្គជំនុំ៖**

សំណាង នៅក្នុងដៃរបស់សាក្សីហ្នឹងមានកំណើតហេតុដែលស៊ើបអង្កេតដោយមន្ត្រីស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ?

**លោក ញ៉ែម សំណាង៖**

ឯកសារនោះខ្ញុំបានអានឲ្យគាត់ស្តាប់នៅថ្ងៃទី៦។ នៅថ្ងៃទី៦ លោកប្រធាន ហើយឯកសារនោះខ្ញុំបានយកទៅទុកនៅក្នុងកាបូបរបស់ខ្ញុំវិញហើយ មិនបានជូនទុកសាក្សីទេ ដោយសារនេះត្រូវខាងលោកស្រី វីនឌី ថាឲ្យយកត្រឡប់ទៅវិញ ព្រោះជាឯកសារសម្ងាត់។

[១១:២៩:៥០]

**ប្រធានអង្គជំនុំ៖**

អរគុណ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** តើលោក ឡុង នរិន្ទ អាចបញ្ជាក់ដែរឬទេថា នៅថ្ងៃទី០៦ ខែធ្នូ គេបានអានកំណត់ហេតុ

ចម្លើយដែលលោកបានផ្តល់ជូនចៅក្រមស៊ើបអង្កេតនោះ តើនៅថ្ងៃនោះ គេមានអានឲ្យលោកអ៊ំស្តាប់ដែរឬទេ?

**លោក ញ៉ែម សំណាង៖**

ស្តាប់បានទេអ៊ំ? ស្តាប់សំណួរបានទេ?

**ឆ៖** បាន តើ! ចៅក្រមស៊ើបអង្កេត អង្កាល់ហ្នឹងមិនដឹងជារឿងអី ខ្ញុំមែនទែនទៅ ខ្ញុំអត់បានចាប់អារម្មណ៍ថាមកសួរពីរឿង ស៊ើបអង្កេត ចៅក្រម--។

**លោក ញ៉ែម សំណាង៖**

សូមអនុញ្ញាត សុំប្រាប់សំណួរទៅសាក្សីម្តងទៀត ហើយខាងសហព្រះរាជអាជ្ញាសួរអ៊ំថា តើអ៊ំបានស្តាប់មន្ត្រីពីតុលាការមកអានអំពីការឆ្លើយទៅនឹងឯកសារដែលអ៊ំឆ្លើយទៅនឹងក្រុមស៊ើបអង្កេតហ្នឹងកាលពីថ្ងៃទី០៦ យើងប៉ុន្មានថ្ងៃមុននេះអ៊ំណា។ ទី០៦ ខែធ្នូ ឆ្នាំ២០១១ ហ្នឹងអ៊ំ តើអ៊ំបានស្តាប់ទេអ៊ំ?

[១១:៣១:៤២]

**ឆ៖** បានស្តាប់ហើយ ក៏ប៉ុន្តែភ្លេចអស់ហើយ មិនដឹងជាអង្កាល់ហ្នឹងខ្ញុំមិនដឹងនិយាយពីរឿងអីផង។ កាលហ្នឹងឯកសារហ្នឹង--

**ស៖** លោកអ៊ំបានជម្រាបថា លោកអ៊ំនិយាយដោយស្មោះត្រង់នៅពេលដែលគេស្តាប់ចម្លើយលោកអ៊ំ។ ដើម្បីឲ្យប្រតិចារឹកនេះបានច្បាស់លាស់នោះ គឺខ្ញុំសូមឲ្យបង្ហាញនៅក្នុងអេក្រង់នេះ ត្រង់ទំព័រដែលមានហត្ថលេខារបស់សាក្សីផ្តិតនៅថ្ងៃផ្តល់ចម្លើយ។ ដូច្នេះហើយគឺខ្ញុំចង់បង្ហាញទៅលើស្នាមមេដៃនោះនៅលើអេក្រង់។

**លោក ឌេល លីសាក់៖**

លោកប្រធាន យើងសូមធ្វើការបង្ហាញនូវផ្ទាំងដែលមានបង្ហាញហត្ថលេខារបស់សាក្សី។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី ឡុង នរិន្ទ នៅកន្លែងដែលមានស្នាមមេដៃ និងហត្ថលេខានោះគឺជាស្នាមមេដៃនិងហត្ថលេខារបស់លោកមែនដែរឬទេ?

**ឆ៖** បាទ, ជារបស់ខ្ញុំ។

**ស៖** នៅពេលដែលមន្ត្រីពីតុលាការចុះទៅស្តាប់ចម្លើយអ៊ំ ក្នុងឆ្នាំ២០០៧ នោះ គឺអ៊ំបាននិយាយដូច្នេះថា ខ្ញុំសូមដកស្រង់សម្តីអ៊ំ “ក្រោយពីបានទៅទីនោះ ប្រហែលជានៅក្នុងឆ្នាំ១៩៧៧ ខ្ញុំមិនច្បាស់ទេ

គឺក្រោយពីចាប់ ហាក់សៀង ឡាយនី និង តូច ខាំឌឿន និងបុគ្គលដែលនៅ ប-១ ដែលត្រូវបានគេចាប់ខ្លួននិងបាត់ខ្លួន។ អៀង សារី បានកោះហៅប្រជុំនៅ ប-១ ហើយលោកបានដឹងថា មានបុគ្គលមួយចំនួនបានបាត់ខ្លួន។

ខ្ញុំចង់សួរសំណួរទៅកាន់លោកអ៊ំ ថានៅក្នុងឆ្នាំ១៩៧៧ លោកអ៊ំបានដឹងអំពីការចាប់ខ្លួន ហាក់សៀងឡាយនី និង តូច ខាំឌឿន មែនដែរឬទេ?

**ឆ៖** ចាប់ខ្លួនពីរនាក់។

**លោក ញ៉ែម សំណាង៖**

សូមអធ្យាស្រ័យឈ្មោះ ចាប់ខ្លួនពីរនាក់ហ្នឹងសាក្សីអត់បានច្បាស់។

**ឆ៖** ហាក់សៀង ឡាយនី មួយ។

**ស៖** ខ្ញុំសូមអភ័យទោសដែលថា ខ្ញុំអានឈ្មោះ មិនត្រឹមត្រូវ។ តើត្រឹមត្រូវដែរឬទេ លោកអ៊ំបានដឹងអំពីការចាប់ខ្លួនរបស់លោក-- តើលោកអ៊ំបាន-- ពិតជាត្រឹមត្រូវដែរឬទេ នៅពេលលោកអ៊ំដឹងថាមានការចាប់ខ្លួន ហាក់ សៀងឡាយនី និង តូច ខាំឌឿន?

**ឆ៖** បាទ, ដឹង ពេលក្រោយមកដល់គេចាប់រួចហើយហ្នឹងបានដឹង។

[១១:៣៧:០៧]

**ស៖** ហេតុអ្វីបានជាកាលពីម្សិលមិញលោកអ៊ំបាននិយាយថា លោកអ៊ំមិនបានដឹងអំពីការចាប់ខ្លួន និងការបាត់ខ្លួនបុគ្គលមួយចំនួនដែលធ្វើការនៅក្រសួងការបរទេសនោះទេ?

**លោក ញ៉ែម សំណាង៖**

អ៊ំយល់សំណួរទេ អ៊ំ? គេសួរថា ហេតុអ្វីបានជាកាលពីម្សិលមិញអ៊ំឆ្លើយថា អ៊ំមិនបានដឹងអំពីការចាប់ខ្លួនអ្នកនៅក្នុងក្រសួងការបរទេសនោះទេ?

**ឆ៖** ពីព្រោះថា អង្កាល់ដែល-- ទាល់តែបាត់មនុស្សទៅបានខ្ញុំដឹងថា គេចាប់ហើយអាហ្នឹង។ មិនមែនគ្រាន់តែប៉ុណ្ណឹងទេ ដល់បាត់ទៅអ្នកដែលរៀននៅប្រទេសសង្គមនិយមក៏បាត់ ទោះជាសញ្ញាបត្រធំប៉ុនណាក៏ដោយគេ ទៅបាត់ៗអស់ទៅ។ ហាក់ សៀងឡាយនី ហ្នឹងបែបចាប់ទាំងប្តីទាំងប្រពន្ធ។

**លោក ម៉ែខល កាណាវាស៖**

មុននឹង-- ខ្ញុំសូមឱ្យផ្តល់ឱកាសថាតើសហ-- សូមឱ្យអានកថាខណ្ឌទាំងមូលតែម្តង ព្រោះថាគាត់បានចូលរួមក្នុងការប្រជុំហ្នឹងហើយ ហើយក៏មានពន្យល់អាចជាការលម្អិត។ ដូច្នេះ ដើម្បីឱ្យមាន

ភាពត្រឹមត្រូវ អ៊ីចឹងសហព្រះរាជអាជ្ញាអាចអានកថាខណ្ឌទាំងមូលដើម្បីឲ្យសាធារណជនអាចស្ដាប់បានផង។

ហើយពិនិត្យមើលទៅលើកថាខណ្ឌនេះ ទាំងមូលនេះតែម្ដង។ សូមអរគុណលោកប្រធាន។

**លោក ខេល លីសាក់៖**

លោក កាណាវាស ខ្ញុំនឹងចូលទៅកថាខណ្ឌនេះ ប៉ុន្តែខ្ញុំសូមលើកវាមួយចំណុចម្ដងៗសិន បើសិនណាខ្ញុំអាចធ្វើទៅបាន។

[១១:៣៩:៥២]

**ប្រធានអង្គជំនុំ៖**

ធ្វើតាមអ្វីដែលសហព្រះរាជអាជ្ញា មានវិធីសាស្ត្រក្នុងការចោទសួរដេញដោលចំពោះសាក្សីរូបនេះ។ មិនធ្វើអាស្រ័យទៅលើកការស្នើសុំរបស់មេធាវីការពារក្ដីទេ។ ចំណែកឯចំណុចណា ដែលជាចំណុចដោះបន្ទុកដែលមានប្រយោជន៍សម្រាប់ក្នុងការសួរតទៅមុខទៀតនោះ គឺជាសិទ្ធិរបស់មេធាវីការពារក្ដីក្នុងការច្បិច ឬក៏ដកស្រង់ដើម្បីតាំងសំណួរចំពោះសាក្សីរូបនេះ ឬក៏សាក្សីដទៃទៀតចំពោះករណីដទៃទៀត។

**សួរដោយលោក ខេល លីសាក់៖**

**ស៖** លោក ឡុង នរិន្ទ នៅពេលដែលមានបុគ្គលិកក្រសួងការបរទេសបាត់ខ្លួន តើលោកបានគិតថាមានអ្វីកើតឡើងចំពោះអ្នកទាំងនោះដែរឬទេ?

**ឆ៖** នៅពេលមានបុគ្គលិកបាត់ខ្លួន ដំបូងគឺខ្ញុំដឹងថាគេទៅរៀនសូត្រ ប៉ុន្តែដល់ក្រោយមកអត់ទេ ខ្ញុំថាអូ៎!ពួកហ្នឹងពួកសន្តិសុខគេចាប់ហើយ។ ហើយដំបូងដូចឃើញថា ខ្ញុំគិតខ្លួនឯងទេថា អេ៎! មើលទៅបែបអ្នកដែលទៅរៀននៅស្រុកសង្គមនិយមបែបមិនអីទេយ៉ាង។ ប៉ុន្តែដល់ឃើញអ្នកដែលទៅរៀននៅសង្គមនិយមក៏គេចាប់ អ្នករៀននៅស្រុកបារាំងក៏គេចាប់ទៅបាត់ទៅ។

[១១:៤២:០៤]

**ស៖** អ្នកណាដែលបានប្រាប់លោកថា អ្នកទាំងអស់នេះត្រូវបានគេបញ្ជូនទៅឲ្យរៀនសូត្រ?

**ឆ៖** មែនទែនទៅ ខ្ញុំសួរអ្នកដែលនៅក្នុងក្រសួងជាមួយគ្នាហ្នឹងទៅ គេថានាំទៅរៀនសូត្រ។

**ស៖** ខ្ញុំសុំសួរលោកថា លោកអាចប្រាប់ឈ្មោះមនុស្សដែលបានប្រាប់ទៅលោកថា អ្នកដែលបាត់ខ្លួនទាំងនេះ គឺថាត្រូវគេបញ្ជូនឲ្យទៅឲ្យរៀនសូត្រ?

**ឆ៖** (ឮមិនច្បាស់) ប៉ុន្តែវាបាត់មនុស្សទៅហ្នឹងគឺអ្នកនៅហ្នឹងក្រសួងហ្នឹងចេះតែនិយាយគ្នាទៅ។ ជួនកាលពេលទៅហូបបាយអីគេនិយាយគ្នាទៅ ថាទៅរៀនសូត្រហើយ ហើយដល់មែនទែនទៅ តែឮសូរពាក្យរៀនសូត្រហ្នឹង វាស្រៀវឆ្អឹងខ្នង។

**ស៖** តើលោកយល់ថាអ្នកដែលគេទៅថាបញ្ជូនទៅរៀនសូត្រហ្នឹង គឺយល់ត្រូវបានគេចាប់ខ្លួននឹងយកទៅសម្លាប់ទេ?

**ឆ៖** អត់ដឹង។

**ស៖** តើលោកបានចូលរួមនៅក្នុងកិច្ចប្រជុំមួយជាមួយលោក អៀង សារី ដែលលោក អៀង សារី គាត់បានធ្វើបទឧទ្ទេសនាមនៅក្នុងវគ្គបណ្តុះបណ្តាលមួយ?

ខ្ញុំសុំសួរម្តងទៀត តើលោកបានចូលប្រជុំនៅក្នុងកិច្ចប្រជុំមួយដែលលោក អៀង សារី ជាអ្នកធ្វើបទឧទ្ទេសនាម ជាអ្នកបង្រៀនអំពីវគ្គនយោបាយនោះដែរឬទេ?

[១១:៤៥:១២]

**ឆ៖** បាទ, ពីព្រោះគាត់ជារួមទៅថាបើកវគ្គហ្នឹង គឺថាបើកវគ្គក្រសួងការបរទេសហ្នឹង គឺលោក អៀង សារី គាត់ឧទ្ទេសនាម។ ហើយក្នុងការដែលធ្វើរឿងនេះ ទាល់មានឯកសារអីពីខាងបក្សមក គាត់ឧទ្ទេសនាម។ បើខ្ញុំមិនដឹងត្រង់នេះ ត្រង់ណាដល់ទៅលោកសួរខ្ញុំអ៊ីចឹង ខ្ញុំអត់ដឹង។ បើខ្ញុំថា(ឮមិនច្បាស់) ច្បាស់។

**ស៖** តើលោក អៀង សារី បាននិយាយអំពីការចាប់ខ្លួនមនុស្សនៅក្នុងវគ្គបណ្តុះបណ្តាលមួយនេះដែរឬទេ?

**ឆ៖** មែនទែនទៅជារួម គាត់ច្រើនតែនិយាយពីមាគ៌ានយោបាយរបស់បក្ស។ ត្រង់ថា បើគាត់ប្រាប់-- បើគាត់មិនប្រាប់ថាខ្លួនទេ ប្រាប់ថាភ្នាក់ងារ សេ.អ៊ី.អា ភ្នាក់ងារ កា.ហ្សេ.បេ អីខ្លះហ្នឹង គឺដូចកណ្តុរធ្លាក់ទឹកអ៊ីចឹង ញ័រ។ ដែលថាឲ្យគាត់ប្រើពាក្យថាចាប់ខ្លួនហើយនុំង គឺអត់-- ដូចមិនដែលប្រើទេ។

[១១:៤៧:១៧]

**ស៖** ខ្ញុំសូមអានផ្នែកមួយនៃកំណត់ហេតុស្តាប់ចម្លើយខែធ្នូ ឆ្នាំ២០០៧ ដែលលោកបានផ្តល់ចម្លើយនេះមកជូនតុលាការ។ គឺឯកសារ D91/3។ ឆ្លើយតបទៅនឹងសំណួរ ដើម្បីពន្យល់អំពីវគ្គនយោបាយដែលលោក អៀង សារី ជាអ្នកបង្រៀននោះ គឺលោកបានជម្រាបដូចតទៅ-- ឆ្លើយដូចតទៅនេះ៖

គឺគាត់និយាយអំពីមាគ៌ានយោបាយ ដូចជា ហើយនិងនិយាយអំពីការដាំបន្លែសម្រាប់ផ្គត់ផ្គង់ក្រសួង ហើយក៏និយាយអំពីអ្នកដែលត្រូវបានចាប់ខ្លួន។ ជាពិសេស ទាក់ទងទៅនឹងអ្នកដែលត្រូវចាប់ខ្លួនមកពីមូលដ្ឋាន ដូចជា កុយ ធួន ហើយសម្រាប់អ្នកដែលមកពី ប-១ គឺគាត់មិនដែលនិយាយឈ្មោះទេ គាត់គ្រាន់តែនិយាយថា ឥឡូវនេះ គឺថាទាំងអ្នកអស់នោះខ្មាំងដូចកណ្តុរផ្លាក់ទឹកអ៊ីចឹង។ លោកក៏បានរំឭកឡើងវិញថា លោក អៀង សារី បាននិយាយនៅក្នុងអង្គប្រជុំដែលលោកបានចូលរួមនៅក្នុងអង្គប្រជុំនោះ នៅក្នុងវគ្គបណ្តុះបណ្តាលនោះ។

[១១:៤៩:៣៧]

**លោក ញ៉ែម សំណាង៖**

លោកប្រធាន សាក្សីសុំអនុញ្ញាតទៅបន្ទប់ទឹក លោកប្រធាន។

លោកប្រធាន សាក្សីសុំអនុញ្ញាតទៅបន្ទប់ទឹក លោកប្រធាន។ ចៅក្រមអត់ទាន់អនុញ្ញាតអ៊ីចឹង-- អាឡូ! លោកប្រធានឮ?

**ប្រធានអង្គជំនុំ៖**

អនុញ្ញាតៗ ឲ្យគាត់សម្រាកចុះ! ហើយ--។

*(សាក្សីទៅបន្ទប់ទឹក)*

[១១:៥២:២៧]

**ប្រធានអង្គជំនុំ៖**

យ៉ាងម៉េចទៅ សំណាង? ត្រឡប់មកវិញនូវ?

**លោក ញ៉ែម សំណាង៖**

ទៅហើយលោកប្រធាន។ សាក្សីបានត្រឡប់មកវិញហើយលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណ! បាទ សូមបន្តទៀត។

សូមអញ្ជើញ!

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** សូមអរគុណលោកប្រធាន។ ដោយសារតែយើងផ្អាកបន្តិចអម្បាញ់មិញនេះ។ ខ្ញុំសូមអានសម្រង់សម្តីនៃចម្លើយដែលគាត់បានប្រគល់ជូនមកឲ្យតុលាការកាលពីខែធ្នូ ឆ្នាំ២០០៧។ ខ្ញុំសូមដកស្រង់

សម្តី៖ គឺដែលនិយាយអំពីការឆ្លើយតបទៅនឹងសំណួរ ទាក់ទងទៅនឹងការពិភាក្សារបស់លោក អៀង សារី ទៅលើគោលនយោបាយ។ ខ្ញុំសូមដកស្រង់សម្តី៖ គាត់និយាយអំពី មាគ៌ានយោបាយ ម្ចាស់ការ ដាំបន្លែ សម្រាប់ក្រសួង និងនិយាយអំពីអ្នកដែលត្រូវបានគេចាប់ខ្លួន និងចម្លើយពាក់ព័ន្ធទៅនឹងអ្នកដែលត្រូវគេចាប់ខ្លួនពីមូលដ្ឋានមក ដូចជា កុយ ធួន នេះជាដើម។ ហើយសម្រាប់បុគ្គលិកដែលមកពីមន្ទីរប-១ គឺគាត់មិនបាននិយាយឲ្យចំឈ្មោះទេ គ្រាន់តែនិយាយថា ឥឡូវនេះគឺថាបុគ្គលិកទាំងអស់ហ្នឹងខ្លាចញ័រខ្លួនដូចកណ្តុរធ្លាក់ទឹកអ៊ីចឹង។

ខ្ញុំសួរថាតើលោកនៅចាំទេថា លោក អៀង សារី បាននិយាយអំពីចំណុចទាំងអស់នេះ មែនឬទេ?

**លោក ញ៉ែម សំណាង៖**

អ៊ឹំយល់សំណួរអំមិញទេ?

**លោក ឡុង នរិន្ទ៖**

**ឆ៖** (ឮមិនច្បាស់) ខ្ញុំអត់ចាំទេមែនទែនទៅ យូរណាស់មកហើយ។

[១១:៥៤:៥០]

**ស៖** តើលោកនិយាយដោយស្មោះត្រង់ដែរឬទេ នៅពេលដែលលោកផ្តល់ចម្លើយមកឲ្យមន្ត្រីតុលាការនៅក្នុងឆ្នាំ២០០៧នោះ? លោក ឡុង នរិន្ទ តើលោកពេលនោះផ្តល់ចម្លើយដោយស្មោះត្រង់ដែរឬទេ?

**ឆ៖** បាទ, ខ្ញុំនិយាយដោយស្មោះត្រង់ហើយនុ៎ង។

[១១:៥៥:៣៣]

**ស៖** ខ្ញុំសូមត្រឡប់ទៅក្រោយបន្តិច ទាក់ទងទៅនឹងលោក ថាច់ ជា ជាមនុស្សដែលលោក អៀង សារី បានបញ្ជាក់ថាជា សេ.អ៊ី.អា ហើយឲ្យលោកពន្យល់អំពីទំនាក់ទំនងនេះ។ តើលោកស្គាល់ភរិយា ហើយនិងកូនៗរបស់លោក ថាច់ ជា ដែរឬទេ?

**ឆ៖** អត់ស្គាល់។ មែនទែនទៅខ្ញុំមិនដឹងជា ថាច់ ជា ហ្នឹងការជាមួយអ្នកណាទេក្រោយមក។

**ស៖** នៅពេលដែលលោក អៀង សារី សួរលោកអំពីការជាប់ទាក់ទងរបស់លោកជាមួយលោក ថាច់ ជា ហើយក្រោយមកគាត់បានឲ្យលោក គឺថា មានគេឲ្យលោកសរសេរប្រវត្តិរូបរបស់លោក។ តើលោកបានដឹងថា ភរិយា និងកូនៗរបស់អ្នកទាំងនោះ គឺថាត្រូវបានចាប់ទេ បន្ទាប់ពីការជម្លៀសខ្លួន

ចេញពីទីក្រុងភ្នំពេញ ហើយក្រោយមកត្រូវគេបញ្ជូនទៅកាន់មន្ទីរសន្តិសុខស-២១?

**ឆ៖** ខ្ញុំអត់ដឹងទេ មិនដឹងជាចាប់ខ្លួនពេលណា ស្អីៗពេលណា អត់ (ឮមិនច្បាស់)។

**ស៖** ខ្ញុំចង់បង្ហាញថា ការកត់ត្រានេះ គឺជាការត្រឹមត្រូវ គឺថាមិនមែន ថាច់ ជា ទេដែលត្រូវចាប់ខ្លួន។ ខ្ញុំសួរថា តើលោកបានដឹងថា ប្រពន្ធ និងកូនៗរបស់គាត់ត្រូវបានចាប់ខ្លួន នឹងសម្លាប់ចោលនៅ ស-២១ ដែរឬទេ?

**ឆ៖** អត់ដឹងទេ។

**ស៖** ប៉ុន្មាននាទីមុននេះ គឺថាលោកបានមានប្រសាសន៍ថា លោកស្ថិតនៅក្នុងស្ថានភាពមួយភ័យខ្លាច ទាក់ទងទៅនឹងការបាត់ខ្លួនរបស់កម្មាភិបាលនៅក្រសួងការបរទេស ជាពិសេសទាក់ទងទៅនឹងអ្វីដែលលោក អៀង សារី និយាយអំពី សេ.អ៊ី.អា នេះ។ តើលោកមិនខ្លាចទេឬ នៅពេលដែលលោក អៀង សារី សួរលោកថាតើលោកជាភ្នាក់ងារ សេ.អ៊ី.អា ឬក៏មិនមែន? ហើយក្រោយមកឲ្យលោកសរសេរប្រវត្តិរូប។ ថាតើលោកមិនមានការភ័យខ្លាចទេឬ?

**ឆ៖** ខ្ញុំចេះតែមានការគិតដែលថា ថ្ងៃណាមួយបែបធ្លាក់មកដល់ខ្ញុំហើយមើលទៅ។

[១១:៥៨:៣៩]

**ស៖** តើលោកមានប្រយ័ត្នប្រយែងពាក្យសម្តីរបស់លោកមែនទែនដែរឬទេ នៅពេលដែលលោកសរសេរប្រវត្តិរូបរបស់លោកនេះ?

**ឆ៖** ខ្ញុំប្រយ័ត្នប្រយែងដែរ ប៉ុន្តែប្រហែលជាដឹងគ្រប់ជ្រុងជ្រោយដឹងអត់ទេ ពីព្រោះវាវែងពេកប្រវត្តិរូប។

**ស៖** តើលោកប្រគល់ប្រវត្តិរូបរបស់លោកហ្នឹងទៅឲ្យអ្នកណា នៅពេលដែលលោកបានសរសេរប្រវត្តិរូបរបស់គាត់ចប់សព្វគ្រប់រួចរាល់ហើយនោះ?

**ឆ៖** ខ្ញុំសរសេរប្រវត្តិរូបហ្នឹងចប់ បានប្រគល់ឲ្យទៅប្រធានក្រុមខ្ញុំហ្នឹង។

[១១:៥៩:៤៨]

**ស៖** និយាយអំពីប្រធានក្រុមរបស់លោកហ្នឹង គឺប្រធានក្រុមដែលលោកនិយាយឈ្មោះពីម្សិលមិញ ឈ្មោះ ស៊ីគឿន ហ្នឹងមែនទេ? ដើម្បីបញ្ជាក់ថា កំណត់ត្រានេះ ច្បាស់លាស់គឺលោក គង់ ស៊ីគឿន នេះជាអ្នកដែលលោកបានប្រគល់ប្រវត្តិរូបរបស់លោកទៅឲ្យនៅពេលដែលលោកសរសេរចប់ហើយ។ តើមែនទេ?

**ឆ៖** បាទ។

**ស៖** តើលោកដឹងថា លោក សួង ស៊ីគឿន ហ្នឹងគាត់ចាត់ចែងដោយរបៀបម៉េចក្រោយពីគាត់បានទទួលប្រវត្តិរូបរបស់លោកហើយទៅ?

**ឆ៖** (មិនឮសំឡេង)។

**ប្រធានអង្គជំនុំ៖**

អត់ឮទេ សំណាង គាត់ឆ្លើយចុងក្រោយអំមិញ ឲ្យគាត់ឆ្លើយម្តងទៀត។

**លោក ញ៉ែម សំណាង៖**

បាទ, លោកប្រធាន។ សូមឆ្លើយម្តងទៀត។

**ឆ៖** មែនទែនទៅខ្ញុំសរសេរប្រវត្តិរូបហ្នឹងហើយ ប្រគល់ទៅឲ្យគាត់ ហើយខ្ញុំអត់ដឹងថាគាត់ឲ្យអ្នកណា ហើយប្រវត្តិរូបនុ៎ងទៅណាទៀត ខ្ញុំអត់ដឹង។

[១២:០១:៣២]

**ស៖** ក្រោយពីលោកប្រគល់ប្រវត្តិរូបរបស់លោកទៅឲ្យគាត់ តើលោកមានបានទទួលការទិតៀន ឬក៏ទទួលចម្លើយតបណាមួយពីអ្នកណាមកដែរទេ ក្រោយពីលោកប្រគល់ប្រវត្តិរូបទៅឲ្យគេហើយ?

**ឆ៖** អត់មានទេ។

**ស៖** តើលោកមានបានដឹងថា កម្មាភិបាលផ្សេងទៀតនៅក្រសួងការបរទេសក៏ត្រូវគេបញ្ជាឲ្យសរសេរប្រវត្តិរូបដូចលោកនេះដែរឬទេ?

**ឆ៖** តាមមើលទៅបែបគ្រប់គ្នាទេ ដែលត្រូវសរសេរប្រវត្តិរូប។

**ស៖** លោកនៅចាំបានទេ អ្នកដែលលោកធ្លាប់ធ្វើការជាមួយហើយត្រូវបានសរសេរប្រវត្តិរូបដូចលោកដែរនោះ? ថាតើលោកអាចនៅនឹកឃើញនៅចាំបានទេ?

**ឆ៖** ខ្ញុំមិនដឹងជាអ្នកណាខ្លះដែលគេឲ្យសរសេរប្រវត្តិរូប។

**ស៖** លោក ឡុង នរិន្ទ តើលោកបានឃើញអ្នកខាងក្រៅក្រសួងការបរទេស មានន័យថាកម្មាភិបាលក្រៅក្រសួងការបរទេសត្រូវបានគេចាប់ខ្លួនដែរឬទេ?

**ឆ៖** អត់ដែលឃើញទេ។

**ប្រធានអង្គជំនុំ៖**

អរគុណលោក ឡុង នរិន្ទ ឥឡូវនេះដល់ពេលសមល្មមនឹងឈប់សម្រាក ដើម្បីពិសាថ្ងៃត្រង់

ហើយ។ ហើយល្ងាចនេះ ម៉ោងមួយ និងសាមសិបនាទីជួបគ្នាទៀត។ ដូច្នេះ អង្គជំនុំជម្រះប្រកាសសម្រាក ដើម្បីពិសាអាហារថ្ងៃត្រង់ត្រឹមនេះរហូតដល់ម៉ោងមួយ និងសាមសិបនាទី សូមអញ្ជើញភាគីនិងសាធារណជនចូលមកកាន់ទីកន្លែងវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

អនុរក្សមន្ទីរឃុំនាំជនជាប់ចោទទាំងបីនាក់ ទៅកាន់បន្ទប់រង់ចាំនៅខាងក្រោម ហើយនឹងឲ្យនាំគាត់ត្រឡប់មកវិញ មកកាន់សាលសវនាការនេះនៅរសៀលនេះឲ្យបានមុនម៉ោងមួយ និងសាមសិបនាទី។

អញ្ជើញសម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១២:០៤ នាទី ដល់ម៉ោង ១៣:៣០ នាទី)*

[១៣:៣៤:៥៧]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ គឺស្តាប់សក្ខីកម្មរបស់សាក្សី ឡុង នរិន្ទ ជាបន្ត។ តែមុននឹងប្រគល់វេទិកាជូនទៅសហព្រះរាជអាជ្ញា អង្គជំនុំជម្រះសូមជម្រាបជូនដល់ភាគី និងសាធារណជន និងមន្ត្រីនៃ អ.វ.ត.ក ដែលពាក់ព័ន្ធនៅក្នុងកិច្ចគាំទ្រដល់ការរៀបចំកិច្ចដំណើរការសវនាការរបស់អង្គជំនុំជម្រះសាលាដំបូងថា អង្គជំនុំជម្រះនឹងលើកបន្តទៅធ្វើការស្តាប់សក្ខីកម្មរូបនេះនៅថ្ងៃស្អែកទៀត។ ទីពីរអង្គជំនុំជម្រះសួរទៅសហព្រះរាជអាជ្ញាថា តើសហព្រះរាជអាជ្ញាត្រូវការពេលវេលាប៉ុន្មានទៀត នៅក្នុងការតាំងសំណួរចំពោះសាក្សី ឡុង នរិន្ទ នេះ?

**លោក ឆេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំជិតបញ្ចប់សំណួររបស់ខ្ញុំហើយ ខ្ញុំសង្ឃឹមថាខ្ញុំប្រហែលជាចំណាយពេលតែ១៥នាទីទៀតតែប៉ុណ្ណោះជាមួយនឹងសាក្សីនេះ។ បន្ទាប់មកគឺខ្ញុំសូមបង្វែរវេទិកា ផ្តល់វេទិកានេះជូនសហសេវិករបស់ខ្ញុំ។ ប្រហែលជាលោកសហព្រះរាជអាជ្ញាជាតិនោះត្រូវការកន្លះម៉ោង។

ដូច្នេះហើយការបញ្ចប់ការតាំងសំណួររបស់យើងខ្ញុំ ប្រហែលជាត្រឹមតែមួយម៉ោងតែប៉ុណ្ណោះពីពេលនេះទៅ។

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណ។ ចុះមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីវិញ តើមានបំណងក្នុងការសួរសាក្សីរូបនេះដែរឬទេ?

[១៣:៣៧:៣១]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន យើងមានសំណួរពីរបីដែរ ហើយយើងនឹងសួរជាបន្តបន្ទាប់ បន្ទាប់ពីសហព្រះរាជអាជ្ញា ហើយយើងត្រូវការពេលវេលាមួយម៉ោង។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយជាបន្តដោយសារសក្ខីកម្មរបស់សាក្សីរូបនេះមានការពាក់ព័ន្ធខ្លាំងទៅនឹងជនជាប់ចោទ អៀង សារី។ ដូច្នេះអង្គជំនុំជម្រះសូមសួរទៅក្រុមមេធាវីការពារក្តីពីរក្រុមទៀត គឺមេធាវីការពារក្តី នួន ជា ហើយនិងមេធាវីការពារក្តី ខៀវ សំផន ថាតើក្រុមមេធាវីរបស់លោកអាចប្រគល់ភារកិច្ចក្នុងការតាំងសំណួរចំពោះសាក្សីរូបនេះទៅក្រុមមេធាវីការពារក្តី អៀង សារី បានដែរឬទេ?

អង្គជំនុំជម្រះសូមសួរទៅក្រុមមេធាវីការពារក្តី នួន ជា និងការពារក្តី ខៀវ សំផន ដោយសារតាមអ្វីដែលបានដេញដោលនេះ ឃើញថាសាក្សីរូបនេះគឺមានការពាក់ព័ន្ធជាខ្លាំងទៅនឹងជនជាប់ចោទ អៀង សារី។ ហេតុដូច្នេះហើយអង្គជំនុំជម្រះសូមសួរថា តើក្រុមមេធាវីការពារក្តី នួន ជា និងក្រុមមេធាវីការពារក្តី ខៀវ សំផន នេះតើអាចប្រគល់ភារកិច្ចក្នុងការតាំងសំណួរសួរសាក្សីរូបនេះ ទៅក្រុមមេធាវីការពារក្តី អៀង សារី បានដែរឬទេ?

[១៣:៣៩:០៨]

**លោក សុន អរុណ៖**

សូមគោរពលោកប្រធាន។ ក្រុមមេធាវី នួន ជា មានសំណួរទៅខាងលោក ឡុង នរិន្ទ ទាំងពីរនាក់ ទាំងបរទេសផង ខ្ញុំផង មានប្រហែលជាមួយម៉ោង។ ហើយម្ល៉ោះហើយសូមសួរផ្ទាល់។

សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណមេធាវី។ ចុះមេធាវី ខៀវ សំផន?

**លោក អាកទូរ វែកគែន៖**

បាទ, លោកប្រធាន។ យើងពិបាកឆ្លើយសំណួរលោកប្រធានណាស់ ព្រោះថាស្ដាប់សាក្សីហ្នឹងមិនទាន់ចប់ផង។ អ៊ីចឹងដូចដែលសហភាគាខ្ញុំបានរៀបរាប់អម្បាញ់មិញអ៊ីចឹង គឺថាសំណួរគឺថាយើងនឹងធ្វើតាមអាស្រ័យនឹងការងាររបស់សហព្រះរាជអាជ្ញា ក៏ប៉ុន្តែទោះយ៉ាងក្ដីបើសិនជាយើងត្រូវចោទសំណួរទៅសាក្សីនោះគឺថា សំណួរយើងមិនច្រើនទេ។ អ៊ីចឹងយ៉ាងណាខ្ញុំមិនចង់ឲ្យលើសពីរយៈពេលកន្លះម៉ោងនោះ ទេ។

[១៣:៤០:១៤]

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណនូវការផ្ដល់ព័ត៌មានដូច្នេះ។

សួស្ដីលោក ឡុង នរិន្ទ។

សូមអញ្ជើញលោក អាង ឧត្ដម!

**លោក អាង ឧត្ដម៖**

សូមគោរពលោកប្រធាន។ សូមអង្គសវនាការ។

សូមអភ័យទោស ដែលខ្ញុំបាទកាត់លោកប្រធានបន្តិច។ ខ្ញុំមានពីរចំណុច ដែលសូមទាញការចាប់អារម្មណ៍ពីតុលាការហ្នឹង ក៏ដូចអង្គសវនាការដែរ។

មួយព្រឹកមិញនេះសហព្រះរាជអាជ្ញា គាត់បានលើកយកឯកសារមកអះអាង គាត់បានបង្ហាញតែឈ្មោះឯកសារទេ ដោយឡែកលេខ ERN ឬក៏លេខទំព័រក៏អត់បានប្រាប់។ ដូច្នេះធ្វើឲ្យយើងខ្ញុំប្រហែលជាមានផ្សេងទៀតមានការពិបាក្នុងការតាមដាន។ អ៊ីចឹងយើងសុំតុលាការមេត្តាបង្គាប់បញ្ជាទៅភាគី នៅពេលដែលលើកយកឯកសារមកអះអាង គឺសូមបញ្ជាក់ពីលេខទំព័រ នៃឯកសារនោះ ឬក៏លេខ ERN ផង ក៏ប៉ុន្តែដោយឡែកសម្រាប់ក្រុមយើងខ្ញុំ បើតុលាការតម្រូវឲ្យខ្ញុំបង្ហាញលេខ ERN នៅលើឯកសារដែលជាភាសាបារាំង ក្រុមខ្ញុំបាទនឹងមិនអាចធ្វើបានទេ ពីព្រោះក្រុមខ្ញុំបាទប្រើតែភាសាពីរគឺអង់គ្លេស ហើយនិងខ្មែរ។ នេះទីមួយ។

[១៣:៤១:៤៥]

ចំណុចទីពីរ ទាក់ទងទៅរឿងសាក្សី។ ខ្ញុំបាទមិនដឹងថា ជាធម្មតាសាក្សីត្រូវបានដឹងឮការពិភាក្សាទាំងមូលនៅក្នុងតុលាការ។ ក៏ប៉ុន្តែខ្ញុំបាទមិនដឹងថា សាក្សីដែលមានកិច្ចពិភាក្សាពីចម្ងាយបែប

នេះ បានឮបានច្បាស់ពីកិច្ចពិភាក្សាដេញដោលរវាងភាគីទាំងឡាយ នៅក្នុងបន្ទប់សវនាការ ឬអត់? ខ្ញុំបាទក្រែងតែសាក្សីដែលនៅពីចម្ងាយបែបនេះ មិនអាចចាប់បានយល់បាននូវកិច្ចពិភាក្សារវាងគូភាគី នៅក្នុងបន្ទប់សវនាការ។ តើបើសិនជា-- ពីព្រោះដើមបណ្តឹងរដ្ឋប្បវេណី ឬក៏សាក្សី គួរតែបានស្តាប់កិច្ចសួរដេញដោលគ្នារវាងភាគីដែរ។ តែខ្ញុំបាទមិនបានដឹងថា តើភាគី ឬដើមបណ្តឹងរដ្ឋប្បវេណី ដែលនៅពីចម្ងាយបែបនេះបានឮកិច្ចពិភាក្សារបស់សវនាការយើងនៅក្នុងបន្ទប់នេះដែរឬអត់? បើសិនជាមិនបានឮ ខ្ញុំគិតថា ឬបើឮមិនច្បាស់ ក៏ខ្ញុំគិតថា វាជាបញ្ហាមួយជាដុំកំភួនដែរ ពីព្រោះសាក្សីក៏ត្រូវដឹងថាភាគីគេនិយាយអីខ្លះ ដើម្បីឲ្យគាត់មានការចូលរួមផង។ សូមអរគុណ។

[១៣:៤៣:១០]

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណច្រើន ដែលលោកបានកត់សម្គាល់លើបញ្ហាពីរចំណុចនេះ។ ចំពោះបញ្ហាទីមួយនេះគឺសូមរំឭកដល់សហព្រះរាជអាជ្ញា ហើយក៏ដូចជាភាគីផ្សេងទៀតដែរ នៅពេលដែលបង្ហាញឯកសារគឺសូមបង្ហាញលេខកូដជាទូទៅ ហើយនិងពេលដែលបង្ហាញនូវទំព័រណាមួយ គឺសូមបង្ហាញជាលេខ ERN ទាំងបីភាសា។ ហើយចំពោះបច្ចេកទេសថា មានការបង្ហាញបីភាសា ហើយមានតែពីរភាសានោះ យើងនឹងសម្របសម្រួលជាមួយនឹងមន្ត្រីច្បាប់នៅទីនេះ ដើម្បីឲ្យជួយរៀបចំនូវការបង្ហាញជាឯកសារដូចជាភាសាបារាំងក្នុងករណីដែលភាគីលោកអត់មានជាដើម។

បញ្ហាទីពីរ លើបញ្ហានៃការធ្វើសក្ខីកម្ម តាមមធ្យោបាយសោតទស្សន៍នេះក៏ជាបញ្ហាមួយដែរ បើនិយាយពីបទពិសោធន៍នៅក្នុងប្រទេសកម្ពុជា ហើយខ្លួនខ្ញុំផ្ទាល់ក្នុងការគ្រប់គ្រងកិច្ចដំណើរការសវនាការនេះ គឺមិនមានបទពិសោធន៍ជ្រៅជ្រះទេ នៅក្នុងការគ្រប់គ្រងសវនាការដោយធ្វើការស្តាប់សក្ខីកម្មអ្នកជំនាញ ឬក៏សាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីពីចម្ងាយ។ ជាការពិតណាស់ យើងបានមានបទពិសោធន៍កន្លងមកនៅក្នុងសំណុំរឿង០០១ យើងធ្លាប់បានធ្វើស្រដៀងគ្នានេះដែរ ពីបណ្តាប្រទេសមួយចំនួននៅអឺរ៉ុបដូចជានៅប្រទេសបារាំងអីជាដើម។ ហើយយើងទទួលលទ្ធផលដូចជាមិនមានបញ្ហាអ្វីទេ។

បញ្ហាមួយទៀត ដែលលោកបានលើកឡើងហ្នឹង គឺខ្ញុំយល់ថា វាដូចជាមិនមានសារៈសំខាន់ដល់ថ្នាក់ថា លុះត្រាតែគាត់ស្តាប់ការពិភាក្សាដេញដោលគ្រប់សព្វនោះ ទើបអាចដំណើរការបានល្អទេ សំខាន់គឺសំណួរដែលសួរទៅគាត់ហ្នឹង គាត់បានស្តាប់បាន ហើយគាត់ឆ្លើយតាមសំណួរ ឬក៏ឆ្លើយនូវសំណួរដែលភាគីបានសួរ។ ក្នុងករណីសួរមិនច្បាស់ គាត់ស្តាប់មិនឮ គឺឲ្យសួរសាជាថ្មីម្តងទៀត។

ដោយឡែកបញ្ហាប្រសិនបើករណីមួយទៀត យើងបានឲ្យមន្ត្រីរបស់គាំពារសាក្សី អ្នកជំនាញហ្នឹងនៅអមគាត់ ហើយយើងបានអនុញ្ញាតឲ្យគាត់បានអាចនិយាយឡើងវិញនូវអ្វីដែលគាត់កត់ត្រា នៅពេលដែលសាក្សីមិនចងចាំ។ អ៊ីចឹងការអនុវត្តពីម្សិលមិញរហូតដល់ពេលនេះយើងគិតថា មិនមានបញ្ហាអីធំដុំទេ ហើយយើងនឹងអាចដោះស្រាយ។

[១៣:៤៥:៤៤]

ជាការពិតណាស់យើង-- បញ្ហាដែលយើងធ្វើលើកនេះ គឺជាលើកដំបូងនៅក្នុងកិច្ចរបៀបធ្វើការផ្តល់សក្ខីកម្មពីចម្ងាយ។ យើងគិតថា យើងនឹងមានបទពិសោធន៍សម្រាប់រឿងក្រោយទៀត នឹងអាចកែប្រែ ឬក៏រៀបចំធ្វើយ៉ាងណាឲ្យល្អជាងនេះជាមិនខាន។ ខ្ញុំសង្ឃឹមថា នឹងដំណើរការទៅបានល្អ។

សូមប្រគល់វេទិកាជូនទៅសហព្រះរាជអាជ្ញា។ សូមបន្តសំណួរ។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ជាការឆ្លើយតបជាដំបូងទៅកាន់លោក អៀង សារី។ ខ្ញុំគិតថា ខ្ញុំបានបង្ហាញថា ទំព័រណារួចហើយ។ ទោះបីជាយើងមិនបានបង្ហាញលេខERN ជាភាសាខ្មែរ អង់គ្លេស បារាំងក៏ដោយ។ ខ្ញុំសូមបញ្ជាក់ថា ប្រវត្តិរូបដែលខ្ញុំលើកឡើងនោះ គឺទំព័រដំបូង ភាសាអង់គ្លេស លេខ ERN គឺ០០៧៥៤២៦៨ លេខភាសាខ្មែរ គឺ ០០៣៧១០។ ខ្ញុំពិតជាបានសួរសាក្សីទៅលើទំព័រចុងក្រោយ តែនៅក្នុងនោះអង់គ្លេសមានលេខ ៧៥៣០៦ ហើយចំពោះខ្មែរគឺ ០០៣៧២៤។ ហើយសំណួរដែលយើងបានសួរចេញពីប្រវត្តិរូបទំព័រចុងក្រោយនោះ គឺខ្ញុំប្រហែលជាបានលើកឡើងលេខទំព័រហើយ។ លេខ ENR គឺ ៧៥៤៣០២។ លេខERN ជាភាសាខ្មែរគឺ ០០៣៧១៦ និងភាសាបារាំងគឺ ០០៧៥២៣៥៨។

[១៣:៤៨:១៨]

**ប្រធានអង្គជំនុំ៖**

អញ្ជើញសហព្រះរាជអាជ្ញាបន្តនូវសំណួរដេញដោលចំពោះសាក្សីបន្តទៀត។ បញ្ហានេះគ្រាន់តែជាការរំឭកបញ្ជាក់បន្ថែមទេ យើងគិតថាវាអាចមានការខ្វះចន្លោះក្នុងករណីបង្ហាញនូវទំព័រខ្លះ ដែលមិនបានសព្វគ្រប់ប៉ុណ្ណោះ។ អ៊ីចឹងគ្រាន់តែទៅមុខទៀត យើងត្រូវតែរៀបចំឲ្យបានជាក់ច្បាស់ជាងមុនប៉ុណ្ណោះ។ ជាពិសេសដូចជា ពាក់ព័ន្ធនឹងកំណត់ហេតុដែលយកមកដេញដោល។ នេះគឺនៅចុងក្រោយនេះ ដែលអាចមានបញ្ហាលើបញ្ហាការបង្ហាញអំពីលេខERN ចំពោះលេខ D ហ្នឹងគឺបានប្រាប់រួចហើយ បានបង្ហាញជម្រាបរួចហើយ ប៉ុន្តែនៅលេខERN។ អ៊ីចឹងគ្រាន់តែទៅមុខទៀតទេ ថាបើសិនយើងលើក

ឯកសារហ្នឹងមកបង្ហាញហ្នឹង បង្ហាញទាំងលេខD ផង ហើយទាំងលេខERN ទៀត ដែលនៅបញ្ចោទំព័រនីមួយៗ ជាភាសាខ្មែរ ឬក៏ភាសាអង់គ្លេសយ៉ាងតិច។ ហើយដែលអាចធ្វើទៅបាននោះទាំងភាសាបារាំងផង ដើម្បីឱ្យភាគីដែលពាក់ព័ន្ធអាចតាមទាន់ ហើយកត់ត្រានិងពិនិត្យនូវឯកសារជាលាយលក្ខណ៍អក្សរដែលបានចែកជូនគាត់រួចហើយ។

[១៣:៤៩:២៣]

អរគុណ។ សូមអញ្ជើញ!

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោក ឡុង នរិន្ទ តើលោកបានស្តាប់ខ្ញុំឮដែរឬទេ?

[១៣:៥០:០០]

**លោក ញ៉ែម សំណាង៖**

អ៊ំស្តាប់បានឮទេ? ស្តាប់ឮទេ?

**លោក ឡុង នរិន្ទ៖**

គេសួរថាម៉េចអំមិញ?

**លោក ញ៉ែម សំណាង៖**

តើអ៊ំស្តាប់លោកសហព្រះរាជអាជ្ញាសួរច្បាស់ទេ?

**លោក ឡុង នរិន្ទ៖**

បាទ។

**ស៖** សូមអរគុណ។ នៅពេលដែលយើងឈប់អាហារថ្ងៃនោះ គឺខ្ញុំបានសួរទៅលោកអ៊ំ ក៏ប៉ុន្តែសហសេវិករបស់ខ្ញុំគឺគាត់ប្រាប់ថាមិនបានបកប្រែទេ ចំណុចនុ៎ង។ ដូច្នេះ នៅពេលនេះ គឺខ្ញុំសួរសំណួរឡើងវិញ។ អ្វីដែលខ្ញុំបានព្យាយាមសួរលោកអ៊ំនោះ គឺថាក្នុងពេលដែលលោកអ៊ំធ្វើការនៅក្រសួងការបរទេសនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យនោះ ថាតើលោកអ៊ំបានចាំហេតុការណ៍ដែលមានគេមកពីខាងក្រៅក្រសួងការបរទេសហ្នឹង គេមកចាប់កម្មាភិបាលនៅក្នុងក្រសួងការបរទេសដែរឬទេ?

**លោក ញ៉ែម សំណាង៖**

អ៊ំយល់ទេអ៊ំ? យល់សំណួរទេអ៊ំ?

**លោក ឡុង នរិន្ទ៖**

 សួរថា--

**លោក ញ៉ែម សំណាង៖**

តើអ៊ំមានបានដឹងថា មាននរណាគេមកចាប់កម្មាភិបាលពីក្រសួងការបរទេសដែរ?

[១៣:៥១:៤៦]

**លោក ឡុង នរិន្ទ៖**

**ឆ៖** សំណួរហ្នឹងមែនទែនទៅ គេមកគេច្រើនទាក់ទងទៅ--។ មែនទែនទៅ ខ្ញុំជាយុទ្ធជនហ្នឹងង អត់មានទាក់ទងទៅ-- បើគេមកពីក្រោមក គឺថាគេទៅផ្ទាល់ទៅការិយាល័យផ្នែកគេត្រូវយកមនុស្ស ហ្នឹងទៅ ហើយទាក់ទងនឹងប្រធានការិយាល័យហ្នឹងទៅ។ ចុះដូច្នោះ ខ្ញុំអត់មានដឹងទេអង្គាល់ហ្នឹង។

**ស៖** ខ្ញុំនឹងអានជូនលោកអ៊ំនូវសំណួរ និងចម្លើយដែលលោកអ៊ំបានឆ្លើយជូនទៅក្រុមស៊ើប អង្កេត ដែលចម្លើយនោះ យើងបានពិភាក្សាមុនអាហារថ្ងៃត្រង់ផងដែរ។ សំណួរដែលគេសួរនៅពេល នោះ គឺថានៅពេលគេចាប់នៅក្រសួងការបរទេស តើបញ្ជាឲ្យចាប់នោះ ចេញមកពីណា? លោកអ៊ំ ឆ្លើយថា បញ្ជានោះគឺចេញមកពីមជ្ឈិម ឬក៏ចេញមកពី ប៉ុល ពត មកឲ្យបញ្ជាទៅ ស-២១ ហើយ បន្ទាប់មក ស-២១ គឺមកប្រាប់បុគ្គលនោះថា ហើយសួរថាតើអ្នកនុ៎ងនៅបន្ទប់លេខប៉ុន្មាន? បន្ទាប់មកគឺ នឹងទៅដល់បន្ទប់នោះ ហើយចាប់បុគ្គលរូបនោះ ហើយបុគ្គលដែលត្រូវបានចាប់នោះ មិនដែលឃើញ ត្រឡប់មកវិញនោះឡើយ។ តើលោកអ៊ំចាំទេ ថាមានគេមកចាប់មនុស្សនៅក្រសួងការបរទេស?

**លោក ញ៉ែម សំណាង៖**

អ៊ំយល់សំណួរទេអ៊ំ?

**ឆ៖** បាទ, ថាមានអ្នកពីក្រោមមកចាប់ នែ៎ អ្នកធ្វើការនៅក្រសួងការបរទេស។ តើខ្ញុំបានដឹងទេ? អាហ្នឹងទាល់ដល់គេចាប់រួចទៅហើយ យកទៅបាត់ហើយ បានដឹងថាគេមកចាប់ពីក្រសួងទៅតែម្តង។

[១៣:៥៤:៣៦]

**ស៖** ថាតើលោកអ៊ំដឹងថា គេចាប់ខ្លួននោះតាមនរណាគេ? តាមរបៀបណាដែរ ក្រោយពីគេចាប់ បុគ្គលនោះចេញទៅនោះ?

**ឆ៖** មិនដឹងតាមរបៀបណាទេនោះ (ឮមិនច្បាស់) ចេញទៅរបៀបណា ក៏អត់-- សុទ្ធតែ-- ដល់តែមនុស្សនោះទៅ គឺអ្នកក្នុងភូមិគ្នាឯងហ្នឹង គេតាំងឡេមឡឺមហើយ ដល់ទៅឡេមឡឺមទៅគេថា

ឲ្យទៅរៀនសូត្រ។ ហ្នឹងចម្លើយដែលច្រើនលេចមកហ្នឹង គឺអ៊ីចឹង។

[១៣:៥៥:៣៩]

**ស៖** ខ្ញុំចង់សួរលោកអ៊ំថា តើលោកអ៊ំអាចនិយាយបានប៉ុន្មានភាសាដែរលោកអ៊ំ?

**លោក ញ៉ែម សំណាង៖**

អ៊ំយល់ទេ?

**ឆ៖** (ឮមិនច្បាស់)

**លោក ញ៉ែម សំណាង៖**

សំណួរចង់សួរថា តើអ៊ំអាចនិយាយបានប៉ុន្មានភាសាដែរ?

**ឆ៖** ខ្ញុំអាចនិយាយខ្មែរ បារាំង អង់គ្លេសខ្លះ ហើយនិងឆេក។

**ស៖** ថាតើភាសាអង់គ្លេសរបស់លោកអ៊ំហ្នឹងអាចនិយាយបានល្អទេ ហើយលោកអ៊ំអាចស្ដាប់យល់សំណួរដែលខ្ញុំសួរជាភាសាអង់គ្លេសដែរ ឬទេ?

**ឆ៖** ភាសាអង់គ្លេសហ្នឹងខ្ញុំស្ដាប់បាន អាចយល់ខ្លះៗ កុំឲ្យតែជ្រៅពេកៗអត់យល់ទេ។

**ស៖** តើលោកអ៊ំអាចចេះនិយាយភាសាចិនដែរ ឬទេ?

**ឆ៖** អត់ទេ អត់ចេះទេ។

**ស៖** តើលោកអ៊ំមានសញ្ញាប័ត្រពីខាងមហាវិទ្យាល័យដែរ ឬទេ?

**ឆ៖** សញ្ញាប័ត្រខាងណា?

**លោក ញ៉ែម សំណាង៖**

មហាវិទ្យាល័យ?

**ឆ៖** មានសញ្ញាប័ត្រពីមហាវិទ្យាល័យមកដែរ ក៏ប៉ុន្តែឥឡូវហ្នឹងកណ្ដៀរកាត់សេចក្ដីឲ្យអស់ហើយ។

**ស៖** សូមអរគុណលោក ឡុង នរិន្ទ។ តើលោកបានដឹងដែរឬទេថា លោក អៀង សារី មានអំណាចក្នុងការរារាំងកុំឲ្យគេចាប់កម្មាភិបាលនៅក្នុងក្រសួងការបរទេស។ តើលោកអ៊ំអាចដឹងថា គាត់មានអំណាចបែបហ្នឹងដែរឬទេ?

[១៣:៥៨:៤៩]

**ឆ៖** ខ្ញុំគ្រាន់តែដឹងថា គឺពេលដែលគាត់មិននៅ បើនរណាមកយកបុគ្គល បុគ្គលិកក្រសួងការ

បរទេស គាត់ផ្តាំផ្ញើនឹងកម្មាភិបាលនៅហ្នឹងគឺថា កុំឲ្យគេយក។

**ស៖** អ៊ីចឹងថា តើអ៊ំដឹងអ៊ីចឹងតាមនរណាគេដែរ? បានន័យថា ស្តាប់អ៊ីចឹងនៅពេលដែលគាត់និយាយតែម្តង ឬក៏ដឹងពីគេមក?

**លោក ញ៉ែម សំណាង៖**

អ៊ំយល់ទេអ៊ំ?

**ឆ៖** អត់ទេ សួរថាម៉េច?

**លោក ញ៉ែម សំណាង៖**

សួរថា តើអ៊ំដឹងតាមរយៈអ្នកណាដែរ ដែលអ៊ំដឹងថា លោក អៀង សារី ហ្នឹងពេលគាត់មិននៅគាត់ហាមមិនគេយកឲ្យបុគ្គលិកនៅក្នុងក្រសួងការបរទេសណាអ៊ំ?

[១៤:០០:១៤]

**ឆ៖** ខ្ញុំដឹងតាមកម្មាភិបាលនៅក្នុងផ្នែករបស់ខ្ញុំ គឺគាត់ថា "នែ! បើគេមកយកបុគ្គលិកក្រសួងយើង កុំឲ្យគេយក។" ប៉ុណ្ណឹង។

**ស៖** តើលោកអ៊ំអាចពន្យល់ជូនខាងអង្គជំនុំជម្រះថា តើមជ្ឈិមពហុបទីយកម្មនៃរបបកម្ពុជាប្រជាធិបតេយ្យនោះគឺអ្វី? តើលោកអ៊ំអាចពន្យល់ថា ប្រជាធិបតេយ្យប្រមូលផ្តុំហ្នឹង គឺមានន័យយ៉ាងម៉េចនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ?

**ឆ៖** ក្នុងហ្នឹងគឺថា ខ្ញុំយល់ អង្កាល់ពេលហ្នឹងគឺថា ទាំងអស់ការងារហ្នឹង គឺបក្សអ្នកចាត់ចែង។

**ស៖** តើលោកអ៊ំមានដែលចូលរួមប្រជុំនៅក្នុងកិច្ចប្រជុំរបស់គណៈមជ្ឈិម ឬក៏នៅក្នុងសន្និបាតដែរឬទេ?

**ឆ៖** សន្និបាតមានពេលខ្លះ ខ្ញុំទៅចូលរួម ទៅស្តាប់ ដូចជាពេលសន្និបាតអីអាហ្នឹងគឺទៅ ប៉ុន្តែដល់ទៅប្រជុំអត់ទេ។ ពីព្រោះអាហ្នឹងទាល់តែសមាជិកមជ្ឈិមបានទៅបាន។

**ស៖** ថាតើការប្រជុំរបស់គណៈមជ្ឈិមហ្នឹង អ៊ំដឹងថាគេប្រជុំនៅឯណាដែរ?

**ឆ៖** ខ្ញុំអត់ដឹង។

**ស៖** ចុះសន្និបាតបក្សវិញ តើនៅពេលដែលអ៊ំចូលរួមហ្នឹង គេប្រជុំសន្និបាតហ្នឹងនៅឯណាដែរ?

**ឆ៖** សន្និបាតហ្នឹងគឺថា ច្រើនតែធ្វើនៅពហុកីឡដ្ឋានអូឡាំពិក នៅៗ-- មែនទែនទៅកីឡដ្ឋានអូឡាំពិក នៅភ្នំពេញហ្នឹង។

**ស៖** ថាតើនរណាគេជាអ្នកឧទ្ទេសនាមនៅក្នុងពេលសន្និបាតនៅពហុកីឡដ្ឋានជាតិអូឡាំពិកនុ៎ង?

**ឆ៖** ពេលនោះ អ៊ំ ប៉ុល ពត គាត់អ្នកឧទ្ទេសនាម។

[១៤:០៣:៥៦]

**ស៖** តើលោកអ៊ំបានចូលរួមសន្និបាតបក្សដែលមាន ប៉ុល ពត ជាប្រធាននុ៎ង តើអ៊ំបានចូលរួមប៉ុន្មានដងដែរ នៅស្តាតអូឡាំពិកនោះ?

**ឆ៖** នៅសន្និបាតនៅស្តាតអូឡាំពិកហ្នឹងគឺថា ច្រើនតែសមាជិកក្រសួងហ្នឹងទៅទាំងអស់គ្នាហ្នឹងទៅស្តាប់។

**ស៖** ថាតើសន្និបាតនេះ គេរៀបចំឡើងប៉ុន្មានដងដែរ រយៈពេលប៉ុន្មានដងក្នុងមួយឆ្នាំ? តើញឹកញាយដែរឬទេ គេរៀបចំឡើងហ្នឹង?

[១៤:០៤:៥៧]

**ឆ៖** បាទ ក្នុងមួយឆ្នាំរៀបចំតែម្តងហ្នឹង សន្និបាតហ្នឹង។ ហើយអ្នកដែលរៀបចំ គឺមជ្ឈិមអ្នករៀបចំហ្នឹង។

**ស៖** តើមានកម្មាភិបាលណាផ្សេងទៀត ចូលរួមនៅក្នុងសន្និបាតដែរឬទេ ក្រៅពីកម្មាភិបាលក្រសួងការបរទេស?

**ឆ៖** មាន មានដែរ។ មានកម្មាភិបាលក្រសួងផ្សេងៗគេមក។ ព្រោះអានេះវាជាបញ្ហាបក្សដូច្នោះ អ្នកណាដែលគេចូលបក្ស គេមកស្តាប់ហ្នឹងហើយ។

**ស៖** ថាតើកម្មាភិបាលមកពីភូមិភាគ មកពីទីជនបទអី គេមកចូលរួមក្នុងសន្និបាតនេះដែរឬទេ?

**ឆ៖** ហ្នឹងខ្ញុំមិនដឹងទេ មិនដឹង។

**ស៖** ថាតើអ្នកចូលរួមក្នុងសន្និបាតនោះមានមកពីខាងយោធាដែរឬទេ?

**ឆ៖** បាទ នេះក៏មិនដឹងដែរ។

**ស៖** តើលោកអ៊ំចាំទេ នៅពេលដែលសន្និបាតនោះគេបាននិយាយអ្វីខ្លះ? គេនិយាយប្រធានបទអ្វីខ្លះ?

**ឆ៖** ក្នុងហ្នឹងគឺមែនទែនទៅច្រើនតែនិយាយពីមាគ៌ា ឲ្យយល់ច្បាស់ពីមាគ៌ា។

[១៤:០៧:១៥]

**សះ** មានតែប៉ុល ពត តែម្នាក់ឯងដែលឧទ្ទេសនាមនៅក្នុងសន្និបាតនេះតែប៉ុណ្ណោះ ឬក៏មានកម្មាភិបាលណាផ្សេងនៅក្នុងជួរបក្សគាត់ឡើងឧទ្ទេសនាមដែរ?

**ឆះ** ជួនកាលមានកម្មាភិបាលដែលមកពីជនបទហ្នឹង ក៏មិននេះទេ លើកជាសំណួរជាអីអីចឹងអាហ្នឹង។ ប៉ុន្តែកម្មាភិបាលច្រើនតែកម្មាភិបាលធំៗ។ កម្មាភិបាលដែលសុទ្ធតែថ្នាក់មជ្ឈិម ថ្នាក់មជ្ឈិមអចិន្ត្រៃយ៍អីៗហ្នឹង។

**សះ** ថាតើលោកនួន ជា មានបានឡើងឧទ្ទេសនាមនៅក្នុងសន្និបាតនោះដែរឬទេ?

**លោក ញ៉ែម សំណាង៖**

*(ឮមិនច្បាស់)* នួន ជា បានឡើងក្នុងមហាសន្និបាតហ្នឹងដែរទេ?

**ឆះ** គាត់អង្គុយនៅហ្នឹង នៅគណៈអធិបតីនៅក្នុងជួរហ្នឹង។

**សះ** ចុះលោក ខៀវ សំផន វិញ ថាតើគាត់មានវត្តមាន និងមានធ្វើបទឧទ្ទេសនាមក្នុង នៅទីនោះទេ?

**ឆះ** លោក ខៀវ សំផន មិនដឹងទេ។ ប៉ុន្តែមែនទែនទៅ គឺតែបក្សជនទៅត្រូវតែទៅស្ដាប់ហើយ។

[១៤:១០:០០]

**សះ** ចុះលោក អៀង សារី វិញ ថាតើគាត់មានវត្តមាន គាត់មានឡើងទៅលើវេទិកាថ្លែងសុន្ទរកថាធ្វើបទឧទ្ទេសនាមអីទេ?

**ឆះ** ខ្ញុំឃើញច្រើនតែអ៊ំ ប៉ុល ពត, នួន ជា ដែលនៅគណ:-- នៅអង្គុយគណៈអធិបតីហ្នឹង។

**សះ** តើសមាជិកបក្ស ដែលចូលរួមនៅក្នុងសន្និបាតហ្នឹងមានប្រគល់ឯកសារជាលាយលក្ខណ៍អក្សរទាក់ទងទៅនឹងគោលនយោបាយរបស់បក្សនោះដែរឬទេ?

**ឆះ** ខ្ញុំមិនដឹងដែរទេ អាហ្នឹង។

**សះ** ហើយសំណួរខ្ញុំចុងក្រោយចំពោះសន្និបាតនេះ តើលោកមានដឹង មានការពិភាក្សាគ្នាទាក់ទងទៅនឹងគោលនយោបាយរបស់បក្សដែរឬទេ? គោលនយោបាយពាក់ព័ន្ធនឹងខ្មាំងដែរឬទេ?

[១៤:១១:២៩]

**ឆះ** ជាបញ្ហារួមគឺថា ក្នុងសន្និបាតហ្នឹងនិយាយហើយ។

**សះ** ខ្ញុំសូមសួរលោកពីរបីសំណួរទៀតលោក ឡុង នរិន្ទ ហើយខ្ញុំនឹងជូននាទីទៅសហការីរបស់ខ្ញុំ។ នៅពេលដែលលោក អៀង សារី ធ្វើដំណើរទៅបរទេស តើគាត់នៅតែមានទំនាក់ទំនងជាមួយនឹង

ក្រសួងការបរទេសដែរឬក៏អត់ នៅពេលដែលគាត់ធ្វើដំណើរទៅកាន់ប្រទេសខាងក្រៅនុ៎ង?

**ឆ៖** នរណាគេ?

**លោក ញ៉េម សំណាង៖**

លោក អៀង សារី។

**ឆ៖** លោក អៀង សារី កាលណាគាត់អញ្ជើញទៅក្រៅ អាហ្នឹង មានអ្នកដែលគេមកជំនួសគាត់ ប៉ុន្តែអត់មាននេះទេ គ្រាន់តែមកជំនួស។

**ស៖** អ្នកណាដែលមកចូលជំនួសធ្វើជាប្រធានស្ថាប័នស្តីទីជាជំនួសឲ្យលោក អៀង សារី នៅពេលគាត់ទៅបរទេស?

**ឆ៖** ពេលដែលគាត់មិននៅ ជួនកាល ខៀវ សំផន មកជំនួស ហើយដូចមានអ្នកណាម្នាក់ទៀតទេ ខ្ញុំមិនចាំដែរ។

[១៤:១៣:៣២]

**ស៖** តើអ្នកនោះឈ្មោះ វន វ៉េត មែនទេ?

**ឆ៖** បាទ។

**ស៖** នេះគឺជាសំណួរចុងក្រោយហើយ លោក ឡុង នរិន្ទ លោកបានលើកឡើងនៅពេលដែលយើងនិយាយអំពីការសន្ទនាគ្នា និយាយគ្នារវាងលោក អៀង សារី និង សេ.អ៊ី.អា បានបញ្ជាក់ពីរឿងនេះ តើគេមានបានប្រាប់លោកថា លោកជាប់ពាក់ព័ន្ធ ដើម្បីឆ្លើយពាក់ព័ន្ធទៅនឹងកម្មាភិបាលដែលត្រូវគេបញ្ជូនខ្លួនទៅ ស-២១ ដែរឬទេ?

[១៤:១៤:១៨]

**ឆ៖** អត់មាននរណាប្រាប់ទេ ប៉ុន្តែមានមនុស្សបាត់ខ្លួនៗពីក្រសួងទៅហ្នឹង ហើយប្រជុំគេលើកពី សេ.អ៊ី.អា ហ្នឹង តែដល់ពេលនេះទៅគេលើកមតិមកឲ្យមកនេះ ពីរឿង សេ.អ៊ី.អា ហ្នឹង ខ្ញុំចេះតែភ័យទៅ។

**ស៖** សូមអរគុណច្រើនលោក ឡុង នរិន្ទ។ មុននឹងខ្ញុំប្រគល់នាទីសួរសំណួរទៅសហការីរបស់ខ្ញុំដើម្បីជាសម្រាប់ប្រតិចារឹកនេះ។ ខ្ញុំសូមបង្ហាញជូននូវចម្លើយសារភាពបីពីស-២១នោះសម្រាប់រួមមានចម្លើយសារភាពរបស់ អ៊ី សឿន គឺដែលមានលេខ D366/7.1.8.3 និងលេខ ERN00520251-00520755 (ស៊ីក) និង ដល់56។

**លោក អាកទូរ វែកគែន៖**

សូមទោសលោកប្រធាន។ អ្នកបកប្រែទៅជាភាសាបារាំង សូមឲ្យលោកនិយាយឡើងវិញពីព្រោះថាគាត់ស្តាប់អត់ទាន់ទេ។

**លោក ឌេល លីសាក់៖**

នេះគឺជាលេខ ERN សម្រាប់ចម្លើយសារភាពទីមួយគឺ 00520251 និង 00520255 ដល់56 គឺជាសម្រាប់សារភាពរបស់លោក និល សារ៉ន និងដែលមានលេខ ERN00185410-00185411។ ហើយនិងមានលេខ IS5.61។

ចម្លើយសារភាពពីស-២១ ចម្លើយសារភាពទីបី ដែលឆ្លើយពាក់ព័ន្ធនោះគឺ ឈ្មោះ ខាំ ភួន មាន IS5.113 មានលេខ ERN00183780-00183781។ សូមអរគុណច្រើន ហើយសូមជូនវេទិកានេះទៅសហការីជាតិ សហព្រះរាជអាជ្ញារងជាតិ។ សូមអរគុណ។

[១៤:១៧:៥៤]

**លោក ច័ន្ទ តារាស្មី៖**

បាទ, សូមគោរពលោកប្រធាន!

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក ហ្សង់ម៉ាក!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំចង់បានការបញ្ជាក់ពាក់ព័ន្ធទៅនឹងការឯកសារយោង ដែលបានផ្តល់អម្បាញ់មិញនេះ។ តើវាជាឯកសារ គឺជាឯកសារចម្លើយសារភាព ដែលទទួលបានពីមន្ទីរស-២១ ឬក៏តើឯកសារហ្នឹងត្រូវបានចាត់ទុកថា ជាឯកសារដាក់ចូលទៅក្នុងការជជែកដេញដោលហើយ ឬក៏គ្រាន់តែជាការជម្រាបជូនព័ត៌មានដល់តុលាការទេ? តើឯកសារទាំងអស់នេះត្រូវបានទទួលក្រោមការធ្វើទារុណកម្ម ឬក៏យ៉ាងណា?

[១៤:១៨:៥៦]

**លោក ឌេល លីសាក់៖**

លោកប្រធានឯកសារនេះ គឺជាឯកសារដែលដាក់នៅក្នុងបញ្ជីឯកសារសម្រាប់សវនាការ។ នៅពេលនេះ ខ្ញុំមិនអាចប្រគល់ភស្តុតាងជូននេះបានទេ គ្រាន់តែសូមបញ្ជាក់ជូនថាសម្រាប់ប្រតិចារឹក

នៃសវនាការនេះ។ ហើយវាជាភស្តុតាងមួយដែលស្របច្បាប់ យើងខ្ញុំជឿជាក់ថាមិនមែនវាពាក់ព័ន្ធទៅនឹងការបង្ហាញការពិត។ វាគ្រាន់តែបង្ហាញថាតើឯកសារនេះត្រូវបានប្រើប្រាស់ដោយរបៀបណា។ នេះគឺជាបញ្ហាដែលយើងខ្ញុំយល់ថាត្រូវធ្វើការពិភាក្សាគ្នា។ ប៉ុន្តែ យើងខ្ញុំមិនបានផ្តល់ឯកសារនេះទៅជាភស្តុតាងនៅពេលនេះនៅឡើយទេ។ សូមអរគុណ។

[១៤:២០:០០]

**លោក ម៉ៃខល កាណាវាស៖**

បើតាមខ្ញុំឮ ទីមួយគឺសម្រាប់ប្រតិចារឹកនេះគឺ សម្រាប់ធ្វើនៅពេលក្រោយគឺមិនមែនសម្រាប់នៅពេលនេះទេ ពីព្រោះជាបញ្ហាដែលត្រូវធ្វើទៅនៅពេលខាងមុខ។ ហើយមានការបដិសេធចំពោះបញ្ហានេះប៉ុន្មានឆ្នាំមកហើយនេះ មិនដឹងថាតើឯកសារមានបន្ទុកប៉ុនណា ទម្ងន់ប៉ុនណានោះទេ ហើយវាមានការពាក់ព័ន្ធទៅដល់សាក្សីប៉ុនណានោះទេ។ បើសិនណាជាមិនមានការបញ្ជាក់ឲ្យបានច្បាស់ ហើយមានការពិភាក្សាគ្នាថាតើមនុស្សទាំងអស់នោះជាអ្នកណា ហើយតើគេស្គាល់មនុស្សទាំងអស់នេះនៅក្នុងឯកសារនេះដោយរបៀបណាជាដើម។ល។ បញ្ជាក់ឲ្យបានច្បាស់ថាតើវាមានពាក់ព័ន្ធទៅនឹងសក្ខីកម្មរបស់សាក្សីរូបនេះដែរឬក៏អត់នោះ។ ហើយអ្វីដែលខាងសហព្រះរាជអាជ្ញាលើកឡើងនេះគ្រាន់តែជា *តាក់ទិក* មួយដើម្បីទាក់ទាញអារម្មណ៍ ហើយខ្ញុំគិតឃើញថា វានឹងធ្វើឲ្យប៉ះពាល់ទៅដល់សក្ខីកម្មដ៏មានតម្លៃរបស់តុលាការ ដូចដែលសហព្រះរាជអាជ្ញាគាត់បានលើកឡើងថា នេះដើម្បីជាសម្រាប់កំណត់ត្រាសម្រាប់ប្រតិចារឹកតែប៉ុណ្ណោះ។ សូមអរគុណ។

[១៤:២១:០៩]

**លោក ខេល លីសាក់៖**

ខ្ញុំសូមធ្វើការឆ្លើយតបថា គឺថាឯកសារនេះបញ្ជាក់ថាតើសាក្សីរូបនេះត្រូវបានគេឆ្លើយ ពាក់ព័ន្ធដោយរបៀបណា ពាក់ព័ន្ធទៅនឹងចម្លើយសារភាពទាំងអស់នេះ។ ហើយដំណើរការនីតិវិធីនៅក្នុងសវនាការគឺដើម្បីពិចារណាទៅលើការពិត និងទៅលើអង្គហេតុទាំងឡាយ ដែលមានតាំងពីឈ្មោះអ្នកពាក់ព័ន្ធ ឆ្លើយពាក់ព័ន្ធនៅក្នុងចម្លើយសារភាពទាំងនេះ។ នេះគឺជា ច្បាស់ណាស់ជាផ្នែកមួយនៃសំណុំរឿងនេះតែម្តង។ ហេតុដូច្នេះឯងបានជាយើងខ្ញុំជម្រាបជូន ដើម្បីឲ្យអង្គជំនុំជម្រះបានជ្រាប ថាវាសម្រាប់ពេលនេះវាគ្រាន់តែសម្រាប់ប្រតិចារឹកតែប៉ុណ្ណោះ ដើម្បីសម្រាប់ដំណើរការនីតិវិធីនៅពេលក្រោយទៀត។

**លោក ម៉ៃខល កាណាវ៉ាស៖**

ខ្ញុំមិនមែន-- នេះមិនមែនជាការពិភាក្សាតតាំងគ្នាទេ។ ប៉ុន្តែអ្វីដែលខ្ញុំទើបបានឮនោះគឺទីមួយបដិសេធថាគាត់មិនបានសារភាព ហើយទីពីរ ហើយគាត់បានគេឆ្លើយដាក់ ប៉ុន្តែមិនមានអ្វីដែលគេហៅថាដែលជាទ្វេគ្រោះនោះទេ។ នៅក្នុងសវនាការជាសាធារណៈមួយគឺថា ត្រូវតែមានការពិភាក្សាគ្នាថាតើមានការធ្វើទារុណកម្ម ឬក៏យ៉ាងណាដើម្បីឈានទៅដល់ការឆ្លើយសារភាពនេះ ហើយត្រូវតែមានការដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរ។ មិនត្រូវសុំដាក់ឯកសារទាំងអស់នេះ នៅចំពោះមុខសាក្សីហើយឆ្លើយថាសម្រាប់តែដើម្បីជាផលប្រយោជន៍នៃប្រតិចារឹកនោះទេ។ អ៊ីចឹងខ្ញុំគិតថា អង្គជំនុំជម្រះមិនគួរទទួលយកឯកសារទាំងនេះជាភស្តុតាងនោះទេ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះធ្វើការកត់សម្គាល់នូវ-- ទទួលស្គាល់នូវការកត់សម្គាល់របស់មេធាវីការពារក្តីចំពោះការស្នើសុំដាក់ឯកសាររបស់សហព្រះរាជអាជ្ញា ដែលបានធ្វើអម្បាញ់មិញនេះ។

ជាបន្តអនុញ្ញាតប្រគល់វេទិកាជូនទៅសហព្រះរាជអាជ្ញាជាតិ ដើម្បីបន្តការតាំងសំណួរ។

**លោក ច័ន្ទ តារាស្មី៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំឈ្មោះ ច័ន្ទ តារាស្មី ជាព្រះរាជអាជ្ញារងជាតិនៅសាលាក្តីខ្មែរក្រហមនេះ។ ខ្ញុំសូមអនុញ្ញាតបន្តសួរសំណួរទៅលោក ឡុង នរិន្ទ ក្នុងនាមសហព្រះរាជអាជ្ញាដូចតទៅ។ ប៉ុន្តែខ្ញុំសូមអនុញ្ញាតពីលោកប្រធាន ដើម្បីអង្គុយ ដើម្បីសម្រួលនៅក្នុងការសួរជាមួយលោក ឡុង នរិន្ទ ពីព្រោះយើងប្រើប្រព័ន្ធសោតទស្សន៍បាទ បើសិនជាលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អង្គជម្រះអនុញ្ញាតតាមការស្នើសុំ។

[១៤:២៤:២៨]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ច័ន្ទ តារាស្មី៖**

**ស៖** ជម្រាបសួរលោកអ៊ំ នរិន្ទ! លោកអ៊ំឮខ្ញុំនិយាយទេបាទ?

**លោក ញ៉ែម សំណាង៖**

អ៊ំឮសហព្រះរាជអាជ្ញារងជាតិនិយាយទេអ៊ំ? អ៊ំឮទេអ៊ំ?

**លោក ឡុង នរិន្ទ៖**

បាទ ឮអំមិញ។

[១៤:២៤:៤៧]

**ស៖** ខ្ញុំសូមអនុញ្ញាតជម្រាបសួរលោកអ៊ំបន្ត ពីសំណួររបស់សហការីរបស់ខ្ញុំដែលបានសួរអម្បាញ់មិញ។ លោកអ៊ំបានបញ្ជាក់ថា នៅ ប-១ លោក ខៀវ សំផន និងលោក វន វ៉េត គឺជាមនុស្សដែលមកជំនួសនៅក្នុងករណី ដែលលោក អៀង សារី ជនជាប់ចោទ អៀង សារី អវត្តមានម្តងម្កាល។ ខ្ញុំចង់ឲ្យលោកអ៊ំបញ្ជាក់ថា តើជនជាប់ចោទ ខៀវ សំផន និងលោក វន វ៉េត មានសិទ្ធិអំណាចសម្រេចអ្វីខ្លះនៅក្នុងពេលដែល អៀង សារី អវត្តមាននៅក្នុងពេលនោះបាទ?

**ឆ៖** ពេលដែលលោក អៀង សារី អត់នៅហ្នឹង លោក វន វ៉េត ឬក៏ ខៀវ សំផន ដែលមកហ្នឹងអត់មានសម្រេចអីទេ។

**ស៖** ប៉ុន្តែតើ អៀង សារី គាត់ផ្តល់សិទ្ធិអំណាចឲ្យជនជាប់ចោទ ខៀវ សំផន និង វន វ៉េត ហ្នឹងមានសិទ្ធិអំណាចសម្រេចអ្វីខ្លះ? សិទ្ធិអំណាចដែលគេប្រគល់ឲ្យគាត់ហ្នឹង តើគាត់មានសិទ្ធិអំណាចសម្រេចអ្វីខ្លះ?

[១៤:២៥:៥៥]

**ឆ៖** មែនទែនទៅ ខ្ញុំឃើញតែបើភ្ញៀវមកធ្វើទស្សនកិច្ចអី ជួនកាលគេមកគួរសមជាមួយនឹង វន វ៉េត ឬក៏ ខៀវ សំផន នៅក្រសួងប៉ុណ្ណឹង។

**ស៖** នៅប-១ តើមានមនុស្សណាសំខាន់ក្រៅពីលោក អៀង សារី ដែរឬទេ? លោកអ៊ំ ឡុង នរិន្ទ តើនៅ ប-១ មានមនុស្សណាខ្លះផ្សេងពីលោក អៀង សារី ដែលជាមនុស្សសំខាន់នៅក្នុងការទទួលខុសត្រូវការងារនៅ ប-១ ដែរឬទេ?

**ឆ៖** សួរថាម៉េចអំមិញ?

**លោក ញ៉ែម សំណាង៖**

សួរ ថាតើមានមនុស្សណាសំខាន់ជាងគេ ក្រៅពីលោក អៀង សារី ធ្វើការនៅ ប-១ ដែរឬទេ?

[១៤:២៧:០៦]

**ឆ៖** ហ្នឹងខ្ញុំមិនដឹងទេ មិនដឹងជាអ្នកណាដែលសំខាន់ជាងលោក អៀង សារី នៅក្នុង ប-១ ហ្នឹងទេ។

**ស៖** បាទ, នៅ ប-១ លោកអ៊ំបានបញ្ជាក់ថា លោក អៀង សារី គឺជាប្រធាន។ អ៊ីចឹងខ្ញុំចង់ដឹងថាតើគាត់ធ្វើការងារហ្នឹងទទួលផែនការពីលើមកទៀត ឬក៏គាត់ចាត់ចែងសម្រេចការងារហ្នឹងដោយខ្លួនឯង។

**ឆ៖** ក្រសួងការបរទេសហ្នឹង គឺលោក អៀង សារី គាត់ជាប្រធាន អ៊ីចឹងហើយ។ ដូច្នោះមានអ្នកណាធំជាងគាត់ទៀតទេ ធំទៅទៀតបែប ប៉ុល ពត ក៏មិនដឹង ឬធំទៅទៀតគណៈមជ្ឈិមតែម្តង មជ្ឈិម អចិន្ត្រៃយ៍អីតែម្តង។

[១៤:២៨:១៨]

**ស៖** បាទ, លោកអ៊ំ តើអ៊ំអាចបញ្ជាក់បានទេ រវាងភាពខុសគ្នាសមាជិកមជ្ឈិម និងសមាជិកគណៈអចិន្ត្រៃយ៍? តើសមាជិកពីរប្រភេទហ្នឹងមានអត្ថន័យខុសគ្នាដូចម្តេច? បាទ, សូមអ៊ំមេត្តាបញ្ជាក់បាទ។

**ឆ៖** គណៈមជ្ឈិម ហើយនិងមជ្ឈិមអចិន្ត្រៃយ៍ គឺមជ្ឈិមអចិន្ត្រៃយ៍ធំជាង ពីព្រោះគណៈមជ្ឈិមជួនកាលមានការប្រជុំ អត់ចូលក៏អត់អីដែរ។ គឺមជ្ឈិមអចិន្ត្រៃយ៍ធំជាង មជ្ឈិមអចិន្ត្រៃយ៍ត្រូវតែទៅហើយ។

[១៤:២៩:០៣]

**ស៖** លោកអ៊ំ ដើម្បីក្លាយជាសមាជិកមជ្ឈិម និងដើម្បីក្លាយជាសមាជិកគណៈអចិន្ត្រៃយ៍ តើគេជ្រើសរើសមនុស្សប្រភេទយ៉ាងដូចម្តេច? មានលក្ខណៈសម្បត្តិយ៉ាងដូចម្តេច ដើម្បីក្លាយជាសមាជិកមជ្ឈិម ឬក៏ក្លាយជាសមាជិកគណៈអចិន្ត្រៃយ៍ក្នុងពេលនោះបាទ?

**ឆ៖** គឺដំបូងត្រូវជាសមាជិកគណៈមជ្ឈិម ហើយទៅបានក្រោយទៀតទៅជាសមាជិកគណៈមជ្ឈិមអចិន្ត្រៃយ៍។

**ស៖** ដើម្បីក្លាយជាសមាជិកមជ្ឈិម ឬក៏ក្លាយជាសមាជិកគណៈអចិន្ត្រៃយ៍ហ្នឹង តើគេរើសមនុស្សចូលជាសមាជិកហ្នឹងត្រូវមានលក្ខណៈសម្បត្តិបែបណាខ្លះលោកអ៊ំ?

**ឆ៖** អាហ្នឹងទៅមែនទែនជាអាយុជីវិតបក្ស-- អ៊ំ! អាយុបក្សទេមែនទែន ហើយនិងខាងនយោបាយ។

**ស៖** លោកអ៊ំអាចបញ្ជាក់បានទេ ថាសមាជិកគណៈអចិន្ត្រៃយ៍ មនុស្សសំខាន់ៗនៅក្នុងសមាជិកគណៈអចិន្ត្រៃយ៍មានអ្នកណាខ្លះ?

**ឆ៖** ក្នុងមជ្ឈិមគណៈអចិន្ត្រៃយ៍ហ្នឹងមាន អ៊ំ ប៉ុល ពត និងអ៊ំ នួន ជា, អ៊ំ អៀង សារី ហើយនិងអ្នកណាទៀតទេ ប៉ុន្តែដូចអស់ហើយមើលទៅ។

[១៤:៣០:៥២]

**ស៖** បាទ, ពួកគាត់ឧស្សាហ៍ជួបប្រជុំគ្នាជាញឹកញាប់ដែរឬទេ នៅក្នុងរង្វង់នៃគណៈអចិន្ត្រៃយ៍ហ្នឹង បាទ?

**ឆ៖** សួរថាម៉េចអំមិញ?

**លោក ញ៉ែម សំណាង៖**

សួរ ថាតើពួកគាត់មានជួបប្រជុំជាញឹកញាប់ទេ ក្នុងគណៈអចិន្ត្រៃយ៍ហ្នឹងអ៊ំ?

**ឆ៖** ហ្នឹង ខ្ញុំមិនដឹងទេ។ មិនដឹងគាត់ប្រជុំប៉ុន្មានដងអី រួចប្រជុំនៅឯណាហ្នឹង ក៏អត់ដឹងដែរ។

**ស៖** តាមអ៊ំ មិនច្រឡំ ឬក៏អ៊ំចាំច្បាស់ ថាតើការប្រជុំជាទូទៅនៅក្នុងគណៈអចិន្ត្រៃយ៍ ឬក៏ក្នុងគណៈមជ្ឈិមហ្នឹង គេលើកប្រធានបទនៃការប្រជុំហ្នឹង សំដៅទៅលើអ្វីខ្លះជាសំខាន់ បាទ? តើអ៊ំអាចបញ្ជាក់បានទេ ប្រធានសំខាន់ដែលគេលើកឡើងនៅក្នុងអង្គប្រជុំហ្នឹង ជាអ្វីនៅពេលនោះ?

[១៤:៣១:៣៨]

**ឆ៖** មែនទែនទៅ ខ្ញុំអត់ដឹងទេអាហ្នឹង។ ព្រោះខ្ញុំជាយុទ្ធជនមិនអាចដឹងបានទេ។

**ស៖** បាទ សូមអ៊ំ មេត្តាបញ្ជាក់ថាតើលោក អៀង សារី កាលសម័យនោះ គាត់ជាសមាជិកអ្វីដែរឬទេ? កាលសម័យនោះ គាត់ជាសមាជិកស្ថិតនៅក្នុងគណៈណាមួយដែរ បាទ?

**ឆ៖** អ្នកណាអ៊ីចេះ?

**ស៖** អៀង សារី បាទ។

**ឆ៖** តាមខ្ញុំដឹងក្នុងសម័យនុ៎ង គាត់ជាមជ្ឈិមអចិន្ត្រៃយ៍ហើយ។

**ស៖** លោកអ៊ំ អាសាជួបគាត់ញឹកញាប់ដែរឬទេ នៅក្នុងពេលប្រជុំគណៈអចិន្ត្រៃយ៍ ឬក៏គណៈមជ្ឈិម ឬក៏នៅពេលដែលអ៊ំចូលរួមក្នុងសកម្មភាពផ្សេងៗទៀត ដែលគាត់ចូលរួមនោះ តើលោកអ៊ំមានបានចូលរួមជួបធ្វើការងារជាមួយគាត់ញឹកញាប់ដែរឬទេ នៅក្នុងសម័យកាលនោះ?

**ឆ៖** សួរថាម៉េចអំមិញ? ថាខ្ញុំចូល--

**ស៖** ខ្ញុំចង់ដឹងថា លោកអ៊ំបានចូលរួមជាមួយសកម្មភាពរបស់លោក អៀង សារី នៅសម័យកាលនុ៎ង រាប់ទាំងការប្រជុំ រាប់ទាំងការធ្វើទស្សនកិច្ចនៅកន្លែងណាផ្សេងៗទៀត តើលោកអ៊ំបានទៅ

ចូលរួមជាមួយគាត់ដែរឬទេ? ហើយបើចូលរួមហ្នឹង ញឹកញាប់ដែរឬទេ? នៅកន្លែងណា? សូមអ៊ំមេត្តាបញ្ជាក់។ សូមអរគុណ។

[១៤:៣៣:០៧]

**ផ៖** ខ្ញុំបានចូលរួមក្នុងការប្រជុំដែលគាត់ប្រជុំក្រសួង ហ្នឹងខ្ញុំទៅចូលរួម។ ចូលរួមហ្នឹង មិនចូលរួមទេ ទៅស្ដាប់ណ៎ា។ ហើយទៅក្រៅជូនកាលគាត់-- ហើយឲ្យគាត់យកខ្ញុំទៅ ជូនកាលគាត់យកគេទៀតផ្សេងទៅជាមួយនឹងយុទ្ធជនដែរ ប៉ុន្តែយុទ្ធជនគឺថាអ្នកកាន់អាវុធម្នាក់ទៅជាមួយផង។

**ស៖** តើលោកអ៊ំបានចូលរួមជាមួយនឹងការប្រជុំជាមួយលោក នួន ជា, លោក ខៀវ សំផន ដែរឬទេ បាទ?

**ផ៖** អត់ទេ ជាមួយអ៊ំ នួន ជា ខ្ញុំអត់ដែលទៅទេ។ ហើយ ខៀវ សំផន ក៏អត់ដែលទេ គឺថាទាល់តែគេបើមានទៅទស្សនកិច្ចអីហ្នឹង ទាល់តែគេអញ្ជើញប្រធានគណៈ ប្រធានរដ្ឋ ហ្នឹងលោក ខៀវ សំផន គាត់ទៅ ហើយទៅជាមួយនឹងគឺលោក អៀង សារី គាត់ទៅ អាហ្នឹង ក៏ខ្ញុំទៅដែរ ជូនកាល។

[១៤:៣៤:៣៣]

**ស៖** តើលោកអ៊ំបានឃើញសកម្មភាពរបស់លោក ខៀវ សំផន, នួន ជា, លោក អៀង សារី នៅពេលនុ៎ង សកម្មភាពសំខាន់របស់គាត់មានអ្វីខ្លះដែរនៅពេលនុ៎ង អ៊ំបានឃើញផ្ទាល់នឹងភ្នែក អ៊ំ បានឮ អ៊ំបានដឹងដោយជាក់ច្បាស់ហ្នឹង នៅហ្នឹងសកម្មភាពរបស់គាត់ហ្នឹង គឺមានសកម្មភាពអ្វីខ្លះដែរលោកអ៊ំ?

**ផ៖** ស្អីខ្លះ? គេសួរយ៉ាងម៉េចអំមិញ?

**លោក ញ៉ែម សំណាង៖**

សូមសួរម្ដងទៀត។

**សួរដោយលោក ច័ន្ទ តារាស្មី៖**

**ស៖** ខ្ញុំចង់ឲ្យលោកអ៊ំមេត្តាបញ្ជាក់អំពីសកម្មភាពដែលលោកអ៊ំបានឃើញដោយផ្ទាល់ បានឮដោយផ្ទាល់ចំពោះសកម្មភាពរបស់លោក អៀង សារី លោក ខៀវ សំផន លោក នួន ជា នៅសម័យកាលនោះ តើអ៊ំបានដឹងឮ បានឃើញគាត់ធ្វើសកម្មភាពអ្វីខ្លះទៅបាទ? សកម្មភាពសំខាន់ៗដែលអ៊ំអាចសង្ខេបបានបាទ សូមអរគុណ។

[១៤:៣៥:២៧]

**លោក ឡុង នរិន្ទ៖**

**ឆ៖** ខ្ញុំឃើញតែគាត់នៅក្នុងក្រសួងហ្នឹង គឺថាគាត់រៀបជាប្រធានប្រជុំផ្សព្វផ្សាយមាគ៌ានយោបាយរបស់បក្ស។ ឯលោក ខៀវ សំផន ហើយនិងអ៊ំ នួន ជា ខ្ញុំអត់ដែលឃើញទេ។

**ស៖** ខ្ញុំចង់ដឹងមួយទៀត នៅពេលដែលអ៊ំធ្វើការនៅប-១ តាមឯកសារបានបង្ហាញថា មានឯកសារសម្ងាត់ខ្លះដែលលោកអ៊ំអត់បានវាយអត្ថបទដោយផ្ទាល់ទេ។ តើឯកសារសម្ងាត់ទាំងនោះអ្នកណាទទួលខុសត្រូវធ្វើការងារនោះលោកអ៊ំ?

**ឆ៖** ខ្ញុំមែនទែនទៅដូចមិនដែលវាយឯកសារសម្ងាត់ អាហ្នឹងផ្នែកផ្សេងគេធ្វើ។

**ស៖** អ្នកណាគេដែលទទួលខុសត្រូវធ្វើឯកសារសម្ងាត់ឲ្យលោក អៀង សារី នៅសម័យកាលនោះ?

**ឆ៖** ខ្ញុំមិនដឹងជានរណាដែរ ប៉ុន្តែគ្រាន់តែខ្លួនខ្ញុំអត់ដែលវាយទេ ខ្ញុំមិនដែលឃើញ-- ព្រោះខ្ញុំមិនដែលឃើញឯកសារសម្ងាត់។

[១៤:៣៧:០០]

**ស៖** ហេតុអ្វីបានជាគេមិនឲ្យអ៊ំវាយឯកសារសម្ងាត់នៅពេលនុ៎ង ហើយគេប្រើមនុស្សផ្សេងវិញ? លោកអ៊ំឮខ្ញុំនិយាយទេបាទ? ខ្ញុំសូមសម្រាបសួរលោកអ៊ំថា តើហេតុអ្វីបានជាឯកសារសម្ងាត់នៅប-១ កាលសម័យនោះ អ៊ំមិនបានវាយអត្ថបទហ្នឹងទេ តែមានអ្នកផ្សេងវាយ តើមូលហេតុអ្វីបានជាលោក អៀង សារី មិនឲ្យលោកអ៊ំវាយឯកសារសម្ងាត់ហ្នឹង?

**ឆ៖** មែនទែនទៅនៅឯកសារសម្ងាត់ ប-១ ហ្នឹង គឺថាព្រោះច្រើនតែឯកសារដែលគេបញ្ជូនពីមជ្ឈិមមក ដូច្នោះអត់ត្រូវវាយអីទៀតទេ។ ឯកសារហ្នឹងគេវាយហើយស្រេចហើយ។

**ស៖** លោកអ៊ំរាល់ពេលប្រជុំជាមួយនឹង គេប្រជុំជាមួយលោក អៀង សារី ឬក៏ប្រជុំនៅកន្លែងផ្សេងៗតើជាទម្លាប់មានបែងចែក មានចែកឯកសារឲ្យសមាជិកអ្នកចូលរួមប្រជុំហ្នឹងដែរឬទេ? ឯកសារជាក្រដាស តើមានការបែងចែកឯកសារឲ្យអ្នកចូលរួមសមាជិកអង្គប្រជុំហ្នឹងដែរឬទេ? បើប្រសិនជាមាន តើឯកសារហ្នឹងមានអត្ថន័យយ៉ាងដូចម្តេចទៅអ៊ំ?

[១៤:៣៨:២៩]

**ឆ៖** ការប្រជុំជាមួយនឹងលោក អៀង សារី ប្រជុំក្រសួងមិនសូវមានចែកឯកសារទេ គឺកត់ខ្លួនឯង គាត់និយាយទៅ យើងកត់ទៅ។ រួចយកមករៀនទៅ។

**ស៖** លោកអ៊ំ តើរាល់ឯកសារសំខាន់ៗដែលមាននៅ ប-១ ឯកសារដែលមាននៅ ប-១ ហ្នឹង

មុននឹងធ្វើការផ្សព្វផ្សាយចេញ ក្រៅ ប-១ ជាផ្លូវការ មុននឹងផ្សព្វផ្សាយចេញជាផ្លូវការទៅក្រសួងផ្សេង ជាសាធារណៈ តើឯកសារនុ៎ង មានការត្រួតពិនិត្យជាមុនពីខាងណាដែរ មុននឹងដាក់ចេញផ្សាយជាផ្លូវការលោកអ៊ំ?

**ឆ៖** ខ្ញុំហ្នឹងខ្ញុំមិនដឹងទេ មែនទែនវាហួសសមត្ថភាពខ្ញុំហើយ។

**ស៖** លោកអ៊ំមានបានដឹងឮអំពីឈ្មោះទស្សនាវដ្ដីមួយដែរឬទេ? ទស្សនាវដ្ដីទង់បដិវត្តន៍កាលសម័យនោះបាទ ទស្សនាវដ្ដីទង់បដិវត្តន៍ តើលោកអ៊ំមានបានដឹងឮដែរឬទេ? ដែលឮ ដែលឃើញទេបាទ?

**ឆ៖** អត់ទេ ខ្ញុំអត់បានដឹងទេ។

**ស៖** តើលោកអ៊ំមានឮគេនិយាយជជែកគ្នាក្នុងចំណោមកម្មាភិបាលថា ទស្សនាវដ្ដីទង់បដិវត្តន៍ហ្នឹងបង្កើតឡើងក្នុងបំណងអ្វី? ហើយចុះផ្សាយជាអត្ថបទអ្វីជាសំខាន់ដែរ ឬទេនៅក្នុងពេលនុ៎ងបាទ?

[១៤:៤០:០៤]

**ឆ៖** ខ្ញុំមិនដែលឮផង។ អង្កាល់ហ្នឹងមានទស្សាវដ្ដីអី? បដិវត្តន៍អី?

**ស៖** ទស្សនាវដ្ដីទង់បដិវត្តន៍បាទ ដែលឮទេអ៊ំ? ដែលឃើញ ដែលឮ ឬក៏ដែលឮគេនិយាយថាក្នុងចំណោមកម្មាភិបាលថាមានទស្សនាវដ្ដីហ្នឹងដែរឬទេ? អ៊ំៗទស្សនាវដ្ដីហ្នឹងអ៊ំដែលឮ ឬក៏អត់ដែលឮអត់ដែ។ឃើញទេ បាទ?

**ឆ៖** ខ្ញុំដែលឮតែទស្សនាវដ្ដីយុវជន។

**ស៖** បាទ អរគុណអ៊ំ ខ្ញុំសូមប្ដូរទៅសំណួរផ្សេងវិញ។ តើការចូលបក្សរបស់លោកអ៊ំហ្នឹង គឺក្នុងគោលបំណងអ្វីដែរ អង្កាល់សម័យកាលនោះ? អ៊ំចូលបក្ស បានចូលបក្ស ចូលក្នុងចលនាតស៊ូ អ៊ីចឹងចូលបក្សរបស់អ៊ំក្នុងសម័យនុ៎ងមានគោលបំណងអ្វី? ហើយនរណាជាអ្នកឧទ្ទេសនាមអ៊ំចូលក្នុងបក្សក្នុងសម័យកាលនោះ?

**លោក ញ៉ែម សំណាង៖**

អ៊ំស្ដាប់សំណួរបានទេ អ៊ំ?

**ឆ៖** ពីរឿងខ្ញុំចូលបក្ស?

**លោក ញ៉ែម សំណាង៖**

បាទ, ថាអ៊ំចូលបក្សដើម្បីគោលបំណងអ្វី? ហើយអ្នកណាឧទ្ទេសនាមអ៊ំឲ្យចូលបក្ស?

**ឆ៖** ខ្ញុំមែនទែនទៅ ខ្ញុំក្នុងស្មារតីស្នេហាជាតិហ្នឹង ដែលខ្ញុំចូលបក្សហ្នឹង។ ពីព្រោះអង្កាល់ហ្នឹងមានបក្សឯណាច្រើន មានតែមួយហ្នឹងហើយ។ ដូច្នោះ ខ្ញុំសូមចូលបក្សទៅ ហើយលោក អៀង សារី គាត់ក៏ទទួលខ្ញុំឲ្យចូលបក្សទៅ។

**ស៖** អរគុណលោកអ៊ំ។ តើពេលដែលអ៊ំចូលបក្សអ៊ំយល់ថា មាគ៌ានយោបាយរបស់បក្សនៅសម័យកាលនោះមានអត្ថន័យសំខាន់យ៉ាងដូចម្ដេច? ហើយមាគ៌ានយោបាយបក្សហ្នឹងកំណត់ដោយនរណាខ្លះ ជាអ្នកកំណត់នយោបាយបក្សហ្នឹងបាទ? លោកអ៊ំឮខ្ញុំ និយាយទេបាទ?

**ឆ៖** មែនទែនចូលបក្សហ្នឹងគឺថា មាគ៌ាគឺថាអង្កាល់ហ្នឹង គឺថាធ្វើម៉េចកសាងប្រទេសយើងឲ្យទៅជាប្រទេសសង្គមនិយម ហើយទៅជាកុម្មុយនីស្តនិយម។

[១៤:៤៣:១៥]

**ស៖** តើអ្នកណាខ្លះដែលជាអ្នកកំណត់មាគ៌ានយោបាយរបស់បក្សសម័យកាលនោះ?

**ឆ៖** ខ្ញុំមែនទែនទៅ ខ្ញុំអត់ដឹងច្បាស់ អត់ដឹងទេ។ ប៉ុន្តែខ្ញុំតាមតែអ៊ំៗហ្នឹង។

**ស៖** លោកអ៊ំនៅពេលដែលបក្សដាក់មាគ៌ាមកឲ្យថ្នាក់ក្រោមអនុវត្តតាម តើមាគ៌ារបស់បក្សហ្នឹងត្រូវបានគេអនុវត្តមានប្រសិទ្ធភាពតាមមួយរយភាគរយទាំងស្រុង ឬក៏មានការគ្មានប្រសិទ្ធភាពការអនុវត្តមានការខុសឆ្គងខ្លះពីមាគ៌ាបក្សពីថ្នាក់លើ? ឬក៏អនុវត្តត្រឹមត្រូវតាមមាគ៌ាបក្សរបស់ថ្នាក់លើ ឬក៏អនុវត្តទៅមានភាពមិនល្អ មានការអនុវត្តមិនត្រឹមត្រូវតាមមាគ៌ារបស់បក្សថ្នាក់លើបាទ? សូមអ៊ំមេត្តាបញ្ជាក់បាទ?

[១៤:៤៤:៣៥]

**ឆ៖** មែនទែនទៅការដែលអនុវត្តន៍មាគ៌ាហ្នឹងវាមិនត្រឹមត្រូវ ត្រង់ប្រិញដូចបន្ទាត់នោះទេ។ វាក្រវិកក្រវក់បន្តិចបន្តួចអ៊ីចឹងហើយអាហ្នឹង។

**ស៖** លោកអ៊ំ តើមកពីមូលហេតុអីបានជាការអនុវត្តមាគ៌ានយោបាយរបស់បក្សហ្នឹងមានបញ្ហាដូច្នេះលោកអ៊ំ?

**ឆ៖** ម៉េចមកសួរខ្ញុំរឿងមាគ៌ាបក្ស ម៉េចបានទៅជា--

**ស៖** ខ្ញុំចង់ដឹងថា ការអនុវត្តមាគ៌ារបស់បក្សហ្នឹង លោកអ៊ំមានប្រសាសន៍ថា អនុវត្តមិនបានត្រឹមត្រូវ ដោយសារតែមានការអនុវត្តហ្នឹងមិនបានល្អ អ៊ីចឹង។ ចង់ដឹងថា តើនេះមកពីមូលហេតុអីបានជាការអនុវត្តហ្នឹងពុំបានត្រឹមត្រូវតាមការកំណត់របស់បក្សថ្នាក់លើ? បាទ សូមលោកអ៊ំមេត្តាបញ្ជាក់

ប្រសិនជាអាច។

**ឆ៖** អាហ្នឹងមែនទែនមនុស្ស ហើយមួយចេញមកជាសម្រេចជាមាត៌ាហើយ ចេញមកនៅលើក្រដាសឲ្យអ្នកដែល មនុស្សដែលអនុវត្តន៍នោះ ជាទៅតាមខ្លួននឹកឃើញហ្នឹងខ្លះទៅ តាមមើលទៅវាអ៊ីចឹងហើយ។ បានជាវាមិនមែននេះទេ ខ្ញុំ តាមដែលខ្ញុំធ្លាប់ឮក្នុងមាត៌ាផ្សេងទៀត នៅក្នុងស្រុកផ្សេងៗហ្នឹងក៏អ៊ីចឹង ថាអ៊ំ! ខុសវាខុសមាត៌ាខ្លះ។

[១៤:៤៦:១៤]

**ស៖** បាទ អរគុណលោកអ៊ំ។

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណអ៊ំ ឡុង នរិន្ទ ឥឡូវដល់សមល្មម-- ដែលពេលសមល្មមនឹងឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក១៥នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរសវនាការ។

សូមសម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៦ នាទី ដល់ម៉ោង ១៥:០១ នាទី)*

[១៥:០១:00]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ! អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយមុននឹងផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញារងជាតិ។ អង្គជំនុំជម្រះសូមជម្រាបថា លោកមានពេល ១៥នាទីទៀតតែប៉ុណ្ណោះក្នុងការសួរសំណួរចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

**លោក ច័ន្ទ តាវារស្មី៖**

បាទ, អរគុណលោកប្រធាន។

ខ្ញុំសូមអនុញ្ញាតសួរទៅលោក ឡុង នរិន្ទ ជាបន្តទៀត។ សូមអរគុណ។

**សួរដោយលោក ច័ន្ទ តាវារស្មី៖**

**ស៖** លោកអ៊ំ ឡុង នរិន្ទ។ អម្បាញ់មិញលោកអ៊ំមានប្រសាសន៍អំពីទស្សនាវដ្តីយុវជន។ តើលោកអ៊ំអាចបញ្ជាក់បានទេថា ទស្សនាវដ្តីយុវជនហ្នឹងមានន័យដូចម្តេច?

**លោក ឡុង នរិន្ទ៖**

**ឆ៖** ទស្សនាវដ្ដីយុវជន?

**លោក ញ៉ែម សំណាង៖**

បាទ, ទស្សនាវដ្ដីយុវជនហ្នឹង តើមានន័យយ៉ាងដូចម្ដេច?

**ឆ៖** មែនទែនទស្សនាវដ្ដីយុវជនហ្នឹង គឺសម្រាប់អប់រំយុវជន។

**ស៖** តើការបោះពុម្ពផ្សាយហ្នឹង ត្រូវបែងចែកទៅខាងណាខ្លះលោកអ៊ំ? អ្នកណាខ្លះបានទទួលទស្សនាវដ្ដីហ្នឹង?

**ឆ៖** ខ្ញុំមិនដឹងទេអាហ្នឹង។ ល្អិតពេកខ្ញុំអត់ដឹងទេ គឺថាប៉ុន្តែមិនអាចចែកគ្រប់គ្នាទេ គឺថាចែកទៅតាមក្រសួងអីចឹងរួចយកទៅមើល ចែកគ្នាទៅ ស្ដាប់ទៅ។

**ស៖** តើទស្សនាវដ្ដីហ្នឹងនិពន្ធដោយអ្នកណាលោកអ៊ំ? អ្នកណាអ្នកនិពន្ធ? ក្រុមមនុស្សណាដែលអ្នកនិពន្ធខ្លឹមសារនៃអត្ថបទដែលត្រូវចុះផ្សាយក្នុងទស្សនាវដ្ដីយុវជនហ្នឹង?

**ឆ៖** ខ្ញុំមិនដឹងជាអ្នកណាអ្នកសរសេរ អ្នកណាជាអ្នករៀបចំទេមែនទែន។

[១៥:០៣:៣៨]

**ស៖** តើនៅក្នុងទស្សនាវដ្ដីយុវជនហ្នឹង មាននិយាយអំពីគោលនិយាយបាយរបស់បក្ស មាគ៌ារបស់បក្ស ឬក៏ផែនការសកម្មភាពផ្សេងៗទៀតរបស់បក្សដែរឬទេ?

**ឆ៖** ក្នុងហ្នឹងគឺមាននិយាយពីមាគ៌ារបស់បក្ស ហើយផែនការការពារប្រទេស។

**ស៖** ទស្សនាវដ្ដីហ្នឹងបោះពុម្ពជាទៀងទាត់ដែរឬទេអ៊ំ អាចគិតថាក្នុងរយៈពេលប៉ុន្មានដងចេញមួយលេខអីចឹង? ហើយមានរូបសញ្ញាសម្គាល់អ្វីដែរបាទ?

**ឆ៖** គាត់សួរថាម៉េចអំមិញហ្នឹង?

**ស៖** ខ្ញុំចង់ដឹងថាតើទស្សនាវដ្ដីហ្នឹង បានបោះពុម្ពផ្សាយជាទៀងទាត់ដែរឬទេ? ក្នុងរយៈពេលប៉ុន្មានចេញមួយលេខ? ហើយក្នុងទស្សនាវដ្ដីហ្នឹងមានរូបសញ្ញាសម្គាល់ជាអ្វី? មានរូបសញ្ញាទស្សនាវដ្ដីជាអ្វី?

**ឆ៖** មែនទែនទៅ ខ្ញុំមិនចាំទេ ភ្លេចអស់ហើយ។

[១៥:០៤:៥៣]

**ស៖** លោកអ៊ំ ខ្ញុំសូមសួរបន្តទៀត។ លោក អៀង សារី គឺជាអតីតរដ្ឋមន្ត្រីក្រសួងការបរទេស

នៅសម័យនុ៎ង។ អ៊ីចឹងគាត់ជាមនុស្សសំខាន់បង្កើត ប-១ មែនដែរឬទេ? មានន័យថា គាត់គឺជាមនុស្សដ៏សំខាន់បំផុតនៅក្នុង ប-១ មែនដែរឬទេ?

**ឆ៖** គាត់ជាប្រធាន ប-១ មែន ។

**ស៖** តើនរណាគេដែលជាអ្នកជ្រើសរើសបុគ្គលិក ឬក៏កម្មាភិបាលឲ្យមកធ្វើការនៅ ប-១?

**ឆ៖** ចាស់ៗគឺច្រើនតែទូតនៅបរទេស ត្រឡប់មកវិញគឺថាមកចូល ប-១ ហ្នឹងឯង ធ្វើការនៅហ្នឹង។

**ស៖** តើគេជ្រើសយកមកធ្វើការនៅទីនោះដោយស្ម័គ្រចិត្ត ឬក៏ដោយមានការលក្ខណៈចាប់បង្ខំ?

**ឆ៖** អត់មាននរណាបង្ខំទេតាមមើលទៅគឺថា គេទទួលយកនៅក្នុង ប-១ ហ្នឹងតែម្តង ឲ្យចូល ប-១ ហ្នឹង។

[១៥:០៦:០៩]

**ស៖** លោកអ៊ំអាចបញ្ជាក់បានអំពីតួនាទីពិតប្រាកដរបស់លោកឈ្មោះ សូ ហុង បានដែរឬទេ? តើលោក សូ ហុង ហ្នឹងមានតួនាទីជាអ្វីកាលសម័យកាលនោះ នៅក្នុងប-១ ហ្នឹង? លោក សូ ហុង បាទ។

**លោក ញ៉ែម សំណាង៖**

ឈ្មោះ សូ ហុង អ៊ំ។

**ឆ៖** អ៊ំ! លោក សូ ហុង គាត់តួនាទីគាត់មែនទែន ខ្ញុំមិនដឹងទេ ប៉ុន្តែខ្ញុំដឹងគឺថា គាត់គឺជាអគ្គលេខាធិការក្រសួង ប-១។

**ស៖** តើអគ្គលេខាធិការហ្នឹងគាត់មានតួនាទីសំខាន់ចម្បងអ្វីខ្លះ? តួនាទីសំខាន់របស់អគ្គលេខាធិការហ្នឹង តើសំខាន់បំផុតតួនាទីគាត់ធ្វើអីខ្លះនៅក្នុងក្រសួងហ្នឹង នៅក្នុង ប-១ ហ្នឹង?

**ឆ៖** មែនទែនទៅគាត់-- គាត់មិនដែលនឹងមកមិនសូវមកធ្វើការអីអង្គុយនៅ ប-១ នោះផង។

[១៥:០៧:១៣]

**ស៖** អ៊ីចឹងតើតួនាទីហ្នឹងត្រូវជំនួសដោយអ្នកណាវិញ នៅពេលដែលគាត់អត់សូវមកអ៊ីចឹង? នៅពេលដែលគាត់អត់មក អវត្តមានរបស់គាត់ តើអ្នកណាធ្វើកិច្ចការជំនួសគាត់លោកអ៊ំ?

**ឆ៖** មែនទែនទៅក្នុងហ្នឹងដល់នេះទៅ ក្រោយទៅគឺថា ច្រើនតែប្រធានផ្នែកពិធីការធ្វើការជំនួសគាត់ហ្នឹង។

**ស៖** អ៊ីចឹងមានន័យថា ប-១ ហ្នឹងមានបង្កើតជាផ្នែកទទួលបន្ទុកពិធីការមែនដែរឬទេអ៊ំ?

**ឆ៖** ពិធីការអង្គាល់ហ្នឹងលោក នី កន ឡើងម្តង ហើយលោកស្រី សូ សែ ម្តងនៅជាពិធីការប្រធានពិធីការហ្នឹង។

**ស៖** ចុះលោកអ៊ំស្គាល់ឈ្មោះ ជួន ប្រាសិទ្ធិ ដែរឬទេសម័យហ្នឹង? ជួន ប្រាសិទ្ធិៗ។

**ឆ៖** ជួន ប្រាសិទ្ធិ អ្ហែ?

**ស៖** បាទ។

**ឆ៖** ហ្នឹងក៏គាត់ទៅធ្វើការនៅក្រសួងការបរទេសហ្នឹងដែរ។

**ស៖** គាត់ទទួលខុសត្រូវផ្នែកអីដែរលោកអ៊ំ?

**ឆ៖** ខាងសរសេរអត្ថបទជាភាសាបារាំង។

**ស៖** លោកអ៊ំ តើនៅក្នុង ប-១ ហ្នឹងមានបង្កើតជាផ្នែកទទួលខុសត្រូវផ្នែកសន្តិសុខដែរឬទេ? មានការិយាល័យ ឬក៏ជាផ្នែកទទួលខុសត្រូវផ្នែកសន្តិសុខនៅក្នុង ប-១ ដែរឬទេ?

[១៥:០៩:០៣]

**ឆ៖** អង្គាល់ហ្នឹងខ្ញុំមិនដឹងច្បាស់ថា តើមានផ្នែកទទួលខុសត្រូវខាងសន្តិសុខហ្នឹងដែរឬក៏អត់នោះខ្ញុំអត់ដឹងទេ។

**ស៖** លោកអ៊ំនៅក្នុង ប-១ មានបង្កើតជាលេខាធិការដ្ឋានដែរឬទេ?

**ឆ៖** លេខាធិការដ្ឋានគឺ សរសេរអត្ថបទស្អីៗហ្នឹងឯង។

**ស៖** តើពេលនុ៎ងលេខាធិការដ្ឋានហ្នឹងដឹកនាំដោយអ្នកណាគេបាទ?

**ឆ៖** ខ្ញុំមិនដឹងដែរទេ មិនដឹងអ្នកណាទេ។

**ស៖** ពីណាគេគ្រប់គ្រងកិច្ចការលេខាធិការដ្ឋាននៅប-១ហ្នឹងលោកអ៊ំ?

**ឆ៖** អត់ដឹងទេខ្ញុំ។

**ស៖** តើលោកអ៊ំជាមនុស្សម្នាក់ដែលធ្វើកិច្ចការងារនៅក្នុងលេខាធិការដ្ឋាននៅ ប-១ ដែរឬទេ?

[១៥:១០:១០]

**ឆ៖** ខ្ញុំធ្វើអ្នកវាយអង្គុលីលេខតែប៉ុណ្ណឹង។ គឺដឹងថាគេយកឯកសារមកឲ្យវាយៗទៅ រួចវាយអ្នកណាដែលគេយកមកឲ្យហ្នឹង វាយរួចយកទៅប្រគល់ឲ្យគេវិញទៅហើយៗ។

**ស៖** តើអ្នកណាគេទទួលខុសត្រូវក្នុងបកប្រែភាសានៅពេលនុ៎ងលោកអ៊ំ នៅក្នុងប-១ ហ្នឹង?

អ្នកណាខ្លះទទួលខុសត្រូវក្នុងការបកប្រែភាសា?

**ឆ៖** ថាម៉េចទេ?

[១៥:១០:៣៨]

**លោក ញ៉ែម សំណាង៖**

តើអ្នកណាខ្លះជាអ្នកទទួលខុសត្រូវក្នុងការបកប្រែភាសា?

**ឆ៖** ក្នុងការបកប្រែភាសាហ្នឹង គឺមានមនុស្សច្រើនដែរ ប៉ុន្មានទេ ប្អូនដប់នាក់ដែរណ៎ា។

**ស៖** អ៊ំអាចរៀបរាប់បានអ្នកណាខ្លះ? ចាំ អ៊ំអាចចាំបានអ្នកណាខ្លះ?

**ឆ៖** មាន ជួន ប្រាសិទ្ធិ ហើយ ស្នួង ស៊ីគឿន ហើយអ្នកណាទៀតខ្ញុំមិនចាំទេ។

**ស៖** បាទ លោកអ៊ំការបកប្រែភាសាហ្នឹង គឺបកប្រែពីភាសាបារាំងទៅខ្មែរ និងពីខ្មែរទៅបារាំង ឬក៏ពីភាសាណាផ្សេងទៀតទៅភាសាណាផ្សេងទៀតបាទ?

[១៥:១១:២៦]

**ឆ៖** អាហ្នឹង គឺថាវាស៊ីសងនឹងសំបុត្រស្អីៗ ដែលគេផ្ញើមកហ្នឹងតើគេផ្ញើជាភាសាអីមក។ យើងសរសេរឆ្លើយទៅគេវិញជាភាសាន៎ុង។

**ស៖** អ៊ំមានប្រសាសន៍ថា ផ្ញើទៅគេវិញ តើផ្ញើទៅអ្នកណាគេ?

**ឆ៖** ផ្ញើមកក្រសួងការបរទេសហ្នឹង ឬក៏មានឯកសារខ្លះពីក្រសួងផ្សេងគេយកមកឲ្យក្រសួងការបរទេសហ្នឹងធ្វើឯកសារឆ្លើយទៅគេវិញអ៊ីចឹង--។

**ស៖** លោកអ៊ំ នៅទី--។

**ឆ៖** សំបុត្រជូនពរ--។

**ស៖** បាទ អរគុណ។ លោកអ៊ំនៅទីនោះមានបង្កើតជាកន្លែងទទួលៗជា កន្លែងទទួលព័ត៌មានគេហៅថា *រ៉ូសិបសិន* ឬក៏ *រ៉េសិបស្យុង* ដែរឬទេបាទ?

[១៥:១២:៣៤]

**ឆ៖** អង្គាល់ហ្នឹង គឺថាអ្នកដែលទទួលប្រទេសនោះមាន សម្រាប់ ហើយអ្នកដែលទទួលប្រទេសហ្នឹងហើយ ដែលយើងទាក់ទងជាមួយនឹងគេន៎ុង ដែលខ្មែរយើងទាក់ទង ឧបមាថាដូចថា ចិនគឺមានមួយផ្នែកដែលទាក់ទងជាមួយនឹងចិន។ ខាងលេខាធិដ្ឋានហ្នឹងក៏មានអ្នកបកប្រែចិន មាននេះអ៊ីចឹងទៅ។

**ស៖** សូមលោកអ៊ំជួយបញ្ជាក់អំពីទីតាំងនៃបឹងត្របែក ទីតាំងនៃបឹងត្របែក ហើយនិងច្រាំងចំរេះ។ បឹងត្របែក ហើយនិងច្រាំងចំរេះ តើជាមួយផ្នែកមួយរបស់ក្រសួងការបរទេសដែរឬទេ បាទ?

[១៥:១៣:២៦]

**ឆ៖** ច្រាំងចំរេះ ហើយនិង--។

**ស៖** បឹងត្របែក។

**ឆ៖** ខ្ញុំគ្រាន់តែដឹងៗ ហើយដឹងជាយ៉ាងម៉េចទេ គេថាហ្នឹងក៏ជាផ្នែកមួយរបស់ក្រសួងការបរទេសដែរ។

**ស៖** លោកអ៊ំបានដឹងអំពីការ នៅក្នុងឯកសារបានបញ្ជាក់ថា លោកអ៊ំបានធ្វើការនៅក្នុងព្រះបរមរាជវាំង។ តើលោកអ៊ំធ្វើកិច្ចការហ្នឹងមែនឬអត់ បាទ?

**ឆ៖** ខ្ញុំមែនទែន វាយម៉ាស៊ីនដូចខ្ញុំថាហ្នឹង តែប៉ុណ្ណឹង ហើយនិងជួនកាលរៀបចំផ្ទះសម្រាប់ទទួលភ្ញៀវ។

**ស៖** លោកអ៊ំបានដឹងអំពីការធ្វើ ការលាឈប់របស់សម្តេចនរោត្តម សីហនុ ដែរឬទេនៅសម័យនុ៎ងបាទ? សម្តេចនរោត្តម សីហនុ បានលាឈប់ តើរឿងព័ត៌មាននេះអ៊ំបានដឹងដែរឬទេ?

**ឆ៖** ស្អីគេ?

**លោក ញ៉ែម សំណាង៖**

តើអ៊ំបានដឹងអំពីការលាឈប់របស់សម្តេចព្រះនរោត្តម សីហនុ ដែរទេ?

**ឆ៖** ហ្នឹងខ្ញុំដឹង គឺថាអង្កាល់ហ្នឹងខ្ញុំនៅវាំងហើយ ឃើញតែអ៊ំៗហ្នឹងទៅសុំអង្វរព្រះករុណាកុំឱ្យឈប់ហ្នឹង លាឈប់ហ្នឹង។

[១៥:១៤:៥៦]

**ស៖** បាទ, លោកអ៊ំ តើលោកអ៊ំបានធ្វើដំណើរអមជាមួយនឹងលោក អៀង សារី ធ្វើដំណើរទៅប្រទេសនេះ ប្រទេសនោះ ទៅក្រៅប្រទេសច្រើនញឹកញាប់ដែរឬទេ នៅក្នុងពេលនុ៎ង?

**ឆ៖** ពេលនុ៎ង ខ្ញុំមែនទែនទៅ ព្រះករុណាលោកយាងទៅណាហ្នឹង ខ្ញុំទៅហ្នឹងដែរ។ ហើយអ៊ំអៀង សារី គាត់អញ្ជើញទៅណា ក៏ខ្ញុំទៅដែរ ជួនកាល។ ជួនកាលអត់ទៅដែរទេអង្កាល់នុ៎ង អ៊ីចឹង។

**ស៖** បាទ តើលោកអ៊ំ ចំពោះករណី ប-២០ តើករណីនេះ ជាផ្នែកមួយដ៏សំខាន់របស់ក្រសួងដែរឬទេបាទ ប-២០?

**ឆ៖** ប-២០ ទាក់ទងនឹងការបរទេសដែរ ក៏ជាមន្ទីរមួយរបស់ក្រសួងការបរទេសដែរ។

**ស៖** សូមអនុញ្ញាតសួរសំណួរចុងក្រោយលោកអ៊ំ។ សំណួរចុងក្រោយរបស់ខ្ញុំគឺ តើលោកអ៊ំស្គាល់ លោកស្រី ខៀវ ប៉ុណ្ណារី ដែរឬទេ?

**ឆ៖** (ឮមិនច្បាស់)?

**ស៖** ខៀវ ប៉ុណ្ណារី? នេះជាសំណួរចុងក្រោយរបស់ខ្ញុំលោកអ៊ំ។ តើលោកអ៊ំ ស្គាល់ លោកស្រី ខៀវ ប៉ុណ្ណារី ដែរឬទេ? ខៀវ ប៉ុណ្ណារី?

**ឆ៖** បាទ, នែ៎ លោកស្រី ខៀវ ប៉ុណ្ណារី ខ្ញុំស្គាល់។ គាត់ជាគ្រូខ្ញុំដែរ គ្រូភាសាខ្មែរ។

**ស៖** តើគាត់បានបង្រៀនអ៊ំអំពីបញ្ហានយោបាយដែរឬទេ នៅក្នុងពេលដែលជាសាស្ត្រាចារ្យរបស់លោកអ៊ំ នៅក្នុងសម័យកាលនោះ?

[១៥:១៦:៣៣]

**ឆ៖** ផ្នែកកាលនោះ គាត់បង្រៀនគឺថា ខ្ញុំយកឧទាហរណ៍មួយ គឺគាត់កំពុងតែបង្រៀនៗ ស្រាប់តែពួកលក់ពងទាកូនហ្នឹងពពាយនាយ ពងទាកូន កូនពងទា។ គាត់ថា ភ្លាមហ្នឹងគឺពួកនិស្សិតសើចគឹលទៅ គាត់ថាអាហ្នឹងជាជីវិតរបស់មនុស្ស។ ហើយគាត់និយាយពន្យល់ថា ជីវិតហ្នឹងវាយ៉ាងម៉េច ហើយស្អីៗអ៊ីចឹង។

**លោក ច័ន្ទ តារាស្មី៖**

ខ្ញុំអរគុណលោកអ៊ំដែលបានឆ្លើយសំណួររបស់ខ្ញុំ។ ខ្ញុំអស់សំណួរ សូមអរគុណលោកប្រធានដែលបានអនុញ្ញាតឲ្យខ្ញុំសួរ។ បាទ សូមអរគុណ។

[១៥:១៧:១១]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះ ដល់វេទិកានៃការសួរសំណួរចំពោះសាក្សីរូបនេះ ដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ ប៉ុន្តែមុននឹងផ្តល់វេទិកា អង្គជំនុំជម្រះសូមរំឭកដល់សហមេធាវីឲ្យបានជ្រាបថា សូមសហមេធាវីគប្បីសួរសំណួរ-- ចៀសវាងនូវការសួរសំណួរណាដែលច្រំដែលឬក៏សំណួរដែលមិនពាក់ព័ន្ធនឹងអង្គហេតុដែលបានចោទប្រកាន់ចំពោះជនជាប់ចោទ។

អង្គជំនុំជម្រះសូមប្រគល់វេទិកាទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីសួរ ហើយឱកាសសួរ គឺត្រឹមពេលនេះទៅ រហូតដល់ម៉ោងសម្រាកប៉ុណ្ណោះ សម្រាប់ល្ងាចនេះ។

សូមអញ្ជើញ!

[១៥:១៨:០៧]

**លោក ពេជ អង្គ៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ អស់លោក លោកស្រីដែលមានវត្តមាននៅទីនេះ។ មេធាវីនាំមុខ សូមប្រគល់សិទ្ធិនៅក្នុងការសួរសំណួរទៅលើសាក្សីនេះ ជូនទៅលោកមេធាវី សំ សុគង់ និងលោកស្រីមេធាវី នូស៊ីន សាកាវ៉ាទី។

សូមលោកប្រធានអនុញ្ញាត!

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាតតាមសំណើសុំនេះ។ សូមអញ្ជើញមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីដែលបានទទួលសិទ្ធិ។

**លោក សំ សុគង់៖**

សូមអរគុណលោកប្រធាន។ ដោយសារតែការធ្វើសក្ខីកម្មនេះ យើងធ្វើតាមរយៈសោតទស្សន៍ ខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន សូមធ្វើការសួរទៅលើសាក្សី ដោយធ្វើការ-- ទៅអង្គុយសួរដូចដែលលោកសហព្រះរាជអាជ្ញាគាត់ធ្វើ សូមការអនុញ្ញាតពីលោកប្រធាន។

[១៥:១៩:០២]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាតតាមការស្នើសុំ។ សូមអញ្ជើញ!

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី៖**

**សួរដោយលោក សំ សុគង់៖**

**ស៖** ជម្រាបសួរលោកពូ លោកអ៊ំ ឡុង នរិន្ទ។ ស្ដាប់ខ្ញុំឮទេ លោកពូ លោកអ៊ំ?

**លោក ឡុង នរិន្ទ៖**

**ឆ៖** បាទ។

**ស៖** ស្ដាប់ឮទេ លោកអ៊ំ?

**ឆ៖** បាទ ឮ។

**ស៖** ឮ បាទ។ ខ្ញុំសូមសួរសំណួរមួយចំនួនទៅលោកអ៊ំ ទាក់ទងនឹងកាលពីមុនដែលលោកអ៊ំចូល

បដិវត្តន៍។ លោកអ៊ំ ថានៅពេលដែលមុនពេលចូលបដិវត្តន៍ លោកអ៊ំបានទៅរៀននៅប្រទេសឆេកូស្លូវ៉ាគី ចំនួន១០ឆ្នាំ មែនទេលោកអ៊ំ?

[១៥:១៩:៤៦]

**ឆ៖** បាទ ទៅពីឆ្នាំ១៩៥៦ ដល់ ៦០ ឆ្នាំសិក្សា។

**ស៖** នៅពេលដែលលោកអ៊ំរៀន ចប់នៅប្រទេសឆេកូស្លូវ៉ាគី ចំនួនរយៈពេល ១០ឆ្នាំហ្នឹង លោកអ៊ំបានសម្រេចចិត្តចូលជាមួយនឹងរណសិរ្សរួមរួបជាតិដែលមានឈ្មោះថា ហ្វុនហ្វឹង តើហេតុអ្វីបានជាលោកអ៊ំចូលទៅក្នុងរណសិរ្សហ្នឹង?

**ឆ៖** ពីព្រោះខ្ញុំស្រឡាញ់ជាតិខ្ញុំ ហើយកាលហ្នឹង គឺថាជាតិយើងត្រូវគេឈ្លានពាន អ៊ីចឹងបានខ្ញុំចូល ុន៊ុង។

**ស៖** នៅពេលដែលលោកអ៊ំចូលហ្នឹង តើលោកអ៊ំឃើញមាននិស្សិតមកពីប្រទេសឆេកូស្លូវ៉ាគីហ្នឹង ហើយនិងប្រទេសផ្សេងៗទៀតមកចូលរួមដែរ ឬទេអ៊ំ?

**ឆ៖** ពេលដែលខ្ញុំចូលទៅហ្នឹង គឺឃើញតែ-- ឃើញមាននិស្សិតដែលមកពីប្រទេសពីបរទេស មានប្រទេសបារាំង មានហុងគ្រី មានអីអ៊ីចឹង។

**ស៖** នៅពេលដែលលោកអ៊ំធ្វើការនៅប៉េកាំង តើរយៈពេលប៉ុន្មានដែរលោកអ៊ំធ្វើការនៅប៉េកាំងហ្នឹង?

**ឆ៖** រយៈពេលដូចជាមួយឆ្នាំ ឬក៏មួយឆ្នាំប្រាំមួយខែអីមិនដឹងទេ។

**ស៖** មួយឆ្នាំប្រាំមួយខែ?

**ឆ៖** បាទ។

[១៥:២១:២៨]

**ស៖** សំណួរមួយទៀតទាក់ទងទៅនឹង លោកអ៊ំបាននិយាយកាលពីម្សិលមិញថា នៅពេលដែលលោកអ៊ំត្រឡប់ពីប៉េកាំង វិញ លោកអ៊ំបានមកធ្វើការនៅហាណូយ ដែលនៅស្ថានីយវិទ្យុ លោកអ៊ំបានមានប្រសាសន៍ថា អៀង ធីរិទ្ធ គាត់ជាអ្នកទទួលខុសត្រូវ។ ចុះខ្ញុំចង់សួរសំណួរថា ក្រៅពី អៀង ធីរិទ្ធ តើលោកអ៊ំមានឃើញអ្នកណាផ្សេងទៀតទេទទួលខុសត្រូវលើប៉ុស្តិ៍ហ្នឹង វ៉ាដ្យូហ្នឹង?

**ឆ៖** នៅទទួលខុសត្រូវនៅហ្នឹង នៅក្នុងវិទ្យុហ្នឹង មានមនុស្សផ្សេងទៀតដែលខ្ញុំស្គាល់ ដូចជាលោក ចាន់។ ឈ្មោះគាត់មែនទែនមិនដឹងឈ្មោះអីទេខ្ញុំ។ ខ្ញុំស្គាល់តែ ចាន់ ហ្នឹងប៉ុណ្ណឹង។

**ស៖** ស្គាល់លោក ចាន់?

**ផ៖** បាទ។

**ស៖** ហើយនៅហាណូយ តើលោកអ៊ំមានធ្លាប់ជួបជាមួយលោក អៀង សារី ទេនៅហាណូយ?

[១៥:២២:៤៣]

**ផ៖** នៅក្នុងហ្នឹងហ្អេ?

**ស៖** បាទ។

**ផ៖** ទៅនៅស្គាល់។

**ស៖** ជួបគាត់នៅហាណូយមែនទេលោកអ៊ំ?

**ផ៖** បាទ។

**ស៖** នៅពេលលោកអ៊ំធ្វើការនៅប៉ុស្តិ៍វិទ្យុនៅហាណូយ ហ្នឹង តើលោកអ៊ំធ្លាប់ជួបលោក អៀង សារី នៅហាណូយទេ?

**ផ៖** ថាម៉េចអំមិញ?

**លោក ញ៉ែម សំណាង៖**

តើអ៊ំបានជួបលោក អៀង សារី នៅហាណូយទេអ៊ំ? នៅកន្លែងប៉ុស្តិ៍វិទ្យុអ៊ំ?

**ផ៖** មានបានក្នុងការដែលគាត់ទៅឧទ្ទេសនាមឯកសារអីអីចឹង ហើយទៅអង្គុយស្តាប់អីចឹងជាមួយគេជាមួយឯងហ្នឹង។

**ស៖** នៅពេលដែលលោកអ៊ំបានជួបលោក អៀង សារី នៅហាណូយ ហើយគាត់ធ្វើបទឧទ្ទេសនាមហ្នឹង តើលោក អៀង សារី គាត់ធ្វើបទឧទ្ទេសនាមហ្នឹងពីប្រធានបទអ្វីដែរលោកអ៊ំ?

**ផ៖** អង្កាល់ហ្នឹង គឺថាគាត់ជាបេសកជនពិសេសរបស់ការតស៊ូនៅក្នុងប្រទេស។

**ស៖** ហើយតើនៅក្នុងបទឧទ្ទេសនាមគាត់ហ្នឹង តើគាត់មាននិយាយទាក់ទងនឹងគោលនយោបាយរបស់បក្ស ឬក៏រចនាសម្ព័ន្ធរបស់បក្សទេនៅពេលដែលគាត់ធ្វើឧទ្ទេសនាមនៅហាណូយហ្នឹងលោកអ៊ំ?

**ផ៖** មិនដឹងគាត់និយាយពីរឿងអីខ្លះទេ ខ្ញុំភ្លេចបាត់ហើយ វាយូរណាស់មកហើយ។

**ស៖** លោកអ៊ំអាចបញ្ជាក់បន្ថែមទៀតទាក់ទងនឹងប៉ុស្តិ៍វិទ្យុនៅហាណូយហ្នឹង ប៉ុស្តិ៍វ៉ាជ្យនៅហាណូយហ្នឹង។ ខ្ញុំចង់ដឹងថា តើនៅពេលដែលគេផ្សព្វផ្សាយទាំងក្នុងស្រុក និងក្រៅស្រុកហ្នឹង តើគេ

ធ្លាប់មានផ្សាយទាក់ទងនឹងគោលនយោបាយរបស់បក្សកុម្មុយនីស្តទេ ឬមួយក៏គេផ្សាយព័ត៌មានជាទូទៅលោកអ៊ំ?

[១៥:២៤:៤៣]

**ឆៈ** ផ្សាយព័ត៌មានពីក្នុងប្រទេសទៅក៏មានដែរ ប៉ុន្តែអង្កាល់ហ្នឹង គឺសាមគ្គីជាតិបីនៅឥណ្ឌូចិនដើម្បីវាយចក្រពត្តិអាមេរិកនោះ វាលុបជាង។

**សៈ** បាទ ឥឡូវខ្ញុំត្រឡប់មកដល់ពេលដែលលោកអ៊ំត្រឡប់មកចូលស្រុកខ្មែរ ស្រុកប្រទេសយើងវិញ។ លោកអ៊ំបានឆ្លើយពីម្សិលមិញថា នៅពេលដែលលោកអ៊ំចេញពីហាណូយមក លោកអ៊ំឆ្លងកាត់ស្ទឹងត្រង់ ហើយនិងកំពង់ចាម។ ហើយពេលនោះលោកអ៊ំធ្លាប់ធ្វើការនៅ ប-២០។

**ឆៈ** បាទ។

**សៈ** អ៊ីចឹងខ្ញុំសូមបញ្ជាក់បន្តិចថា តើលោកអ៊ំនៅធ្វើការនៅ ប-២០ នោះ លោកអ៊ំមានតួនាទីជាធ្វើអ្វីដែលនៅ ប-២០ ហ្នឹង?

**ឆៈ** នៅប-២០ គឺបង្កបង្កើនផល។

**សៈ** បង្កបង្កើនផល។ បង្កបង្កើនផលហ្នឹង តើលោកអ៊ំបង្កបង្កើនផលដោយខ្លួនឯង ឬមួយអ្នកណាគេប្រាប់ឲ្យអ៊ំឲ្យធ្វើ?

**ឆៈ** បាទ?

[១៥:២៦:០០]

**សៈ** គេអ្នកប្រាប់ឲ្យអ៊ំឲ្យធ្វើបង្កបង្កើនផល ឬមួយក៏លោកអ៊ំទៅដល់ធ្វើបង្កបង្កើនផលដោយខ្លួនឯង?

**ឆៈ** អាហ្នឹងអត់ទេ មានកម្មាភិបាលម្នាក់ទទួល ប-២០ ហ្នឹង ហើយខ្ញុំជាអ្នកចូលមករស់នៅក្នុង ប-២០ ហ្នឹង។ ដូច្នោះ ប-២០ ហ្នឹង មានភារកិច្ចបង្កបង្កើនផល ដាំពោត ដំឡូង។

**សៈ** នៅពេលដែលគេប្រាប់ឲ្យអ៊ំឲ្យលោកអ៊ំបង្កបង្កើនផលហ្នឹង តើគេមានប្រាប់ពីគោលបំណងថាគេបង្កបង្កើនផលហ្នឹងដើម្បីយកធ្វើអីទេ?

**ឆៈ** អាហ្នឹងគឺមានគេអប់រំ។

**សៈ** អប់រំហ្នឹង គេយកទៅធ្វើអីនៅពេលដែលយើងប្រមូលផលបាន?

**ឆៈ** មែនទែនទៅអាហ្នឹងគឺសម្រាប់ខ្លួនឯងហ្នឹង សម្រាប់ ប-២០ ហ្នឹង។

**ស៖** សម្រាប់ ប-២០ តែម្តង?

**ធ៖** ពេលខ្លះក៏ផ្តល់ទៅឲ្យមន្ទីរមជ្ឈិមដែរយ៉ាង។

**ស៖** នៅក្នុង ប-២០ លោកអ៊ំមានបាន អាចកត់សម្គាល់បានទេថា មានបុគ្គលិកប៉ុន្មាននាក់ធ្វើការនៅក្នុង ប-២០ ហ្នឹង?

**ធ៖** ខ្ញុំមិនដឹងច្បាស់ទេ មិនដឹងប៉ុន្មាននាក់ទេ ក្នុង ប-២០ ហ្នឹង ប៉ុន្តែកម្មាភិបាលដឹកនាំមិនច្រើនទេ។

**ស៖** នៅក្នុង ប-២០ តើលោកអ៊ំឃើញមានការិយាល័យផ្សេងទៀតនៅក្នុង ប-២០ ហ្នឹងទេលោកអ៊ំ?

**ធ៖** ថាម៉េចទេហ្នឹង សួរ?

**លោក ញ៉ែម សំណាង៖**

នៅ ប-២០ តើអ៊ំមានបានឃើញមានការិយាល័យអ្វីផ្សេងទៀតទេអ៊ំ?

**ធ៖** អត់ទេ ខ្ញុំអត់ឃើញមានការិយាល័យអីផ្សេងទេ មានឃើញតែ ប-២០ ហ្នឹង មានក្រុមនារីមួយក្រុមហ្នឹង គឺដាំបាយឲ្យសមាជិក ប-២០ហ្នឹ ង ហើយសមាជិកហ្នឹងគឺថារកឧសរកអីអ៊ីចឹងមកហើយឲ្យគេដាំបាយហ្នឹងទៅ។

[១៥:២៨:២០]

**ស៖** នៅក្នុង ប-២០ តើលោកអ៊ំមានឃើញមានអ្នកក្រៅចូលធ្វើការទំនាក់ទំនងជាមួយ ប-២០ ហ្នឹងទេ លោកអ៊ំ? អ្នកពីខាងក្រៅ ប-២០។

**ធ៖** មានអ្នកដែលមកពីមូលដ្ឋាន និងជាយុវជនដែលមកពីមូលដ្ឋាន មកដល់ចូល ប-២០ ហ្នឹងមួយរយៈទៅបានគេឲ្យ បញ្ជូនឲ្យទៅនៅ ប-១៥ ឬក៏មន្ទីរផ្សេងៗទៀត។

**ស៖** នៅអំឡុងពេលដែលយុវជនដែលគាត់ចូលមក ប-២០ មួយរយៈហ្នឹង តើគាត់ ពួកគាត់ហ្នឹងមកធ្វើអីនៅ ប-២០ ហ្នឹងលោកអ៊ំ?

**ធ៖** មកហ្នឹងគឺអារឧស អារអីអ៊ីចឹងទៅ។ ធ្វើការពលកម្ម។

**ស៖** នៅពេលដែលយុវជន គាត់មកនៅ ស្នាក់នៅ ប-២០ ហ្នឹង តើមានការបង្រៀន ឬក៏មានការប្រជុំអីទេ នៅក្នុង ប-២០ ហ្នឹងលោកអ៊ំ?

[១៥:២៩:៣៥]

**ឆ៖** ក្នុង ប-២០ ហ្នឹង មានតែប្រជុំទេ អត់មានការបង្រៀនអីទេ។

**ស៖** ទាក់ទងនឹងការប្រជុំ តើគេប្រជុំហ្នឹងជាញឹកញាប់ ឬមួយក៏គេប្រជុំយូរៗម្តង លោកអ៊ំ?

**ឆ៖** ប្រជុំហ្នឹង បើប្រជុំការងារអាហ្នឹងវាញឹកញាប់ដែរ គឺថារាល់ថ្ងៃអ៊ីចឹងទៅ ហើយគេឲ្យធ្វើទិតៀន ស្វ័យទិតៀនខ្លួនឯងទៅ ខ្វះខាតយ៉ាងម៉េចខ្លះ ឬពិនិត្យខ្លួនឯង ត្រួតពិនិត្យ មែនទែនត្រួតពិនិត្យខ្លួនឯងហ្នឹង។

[១៥:៣០:១៨]

**ស៖** ទាក់ទងនៅក្នុង ប-២០ ដែរ តើលោកអ៊ំដែលធ្លាប់ជួបលោក អៀង សារី ទៅ ប-២០ ទេលោកអ៊ំ?

**ឆ៖** ខ្ញុំធ្លាប់ឃើញគាត់ដែរ ប៉ុន្តែគ្រាន់តែគាត់ឆ្លងកាត់ដែរមែនទែនទៅ គាត់ចេញទៅក្រៅក៏គាត់ជួនកាលគាត់មកចូល ប-២០ ហើយ បានគាត់ឆ្លងទៅទៀត។

**ស៖** នៅពេលដែលមានកិច្ចប្រជុំ ដូចលោកអ៊ំថា ជួនកាលវាអាចច្រើនដង ជួនកាលវាអាចយូរៗម្តង តើអ្នកណាជាប្រធាននៃអង្គប្រជុំលោកអ៊ំ?

**ឆ៖** ប្រធាននៃអង្គប្រជុំនោះគឺថា បើរឿងតូចតាចអីទេ អាហ្នឹងគឺប្រធានមន្ទីរហ្នឹងឯង។ ខ្ញុំមិនចាំទេឥឡូវ មិនដឹងឈ្មោះអីទេ ហើយនៅរស់ ឬក៏ស្លាប់ក៏មិនដឹងទៀត ប៉ុន្តែគាត់ល្អណាស់។

**ស៖** នៅក្នុង ប-២០ លោកអ៊ំដឹងថាមានកិច្ចប្រជុំសម្ងាត់ខ្លះទេ នៅក្នុង ប-២០ នៅពេលដែលលោកអ៊ំស្នាក់នៅ ប-២០ ហ្នឹង?

លោកអ៊ំឮទេលោកអ៊ំ?

**ឆ៖** បាទ។

**ស៖** និយាយនៅក្នុង ប-២០ លោកអ៊ំ តើវាមានកិច្ចប្រជុំសម្ងាត់របស់បដិវត្តន៍ទេ ឬក៏មានតែប្រជុំជាមួយយុវជនធម្មតា លោកអ៊ំ?

**ឆ៖** ប្រជុំ ច្រើនតែប្រជុំធម្មតា។ ស្តាប់មិនច្បាស់ទេ។

**លោក ញ៉ែម សំណាង៖**

សូមអធ្យាស្រ័យលោកប្រធាន សាក្សីសូមទៅបន្ទប់ទឹក។

**ប្រធានអង្គជំនុំ៖**

អនុញ្ញាតតាមការស្នើសុំ។

*(សាក្សីទៅបន្ទប់ទឹក)*

[១៥:៣៤:៤១]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីតំណាង-- មេធាវីដើមបណ្តឹងរដ្ឋប្បវេណីបន្តសំណួរចំពោះសាក្សីបន្តទៀត។ សូមអញ្ជើញ!

[១៥:៣៥:០៦]

អត់បើកក្បាលមេក្រូផង។

**លោក សំ សុគង់៖**

ខ្ញុំសូមអនុញ្ញាតពីលោកប្រធាន ដើម្បីអានកំណត់ហេតុរបស់លោក ឡុង នរិន្ទ នូវឯកសារលេខ D91/3 ហ្នឹង ដើម្បីចង់បញ្ជាក់គាត់បន្តិចលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

ត្រង់ទំព័រប៉ុន្មានទៅ? ERN ប៉ុន្មាន?

**លោក សំ សុគង់៖**

ទំព័រទីពីរ ERN 00204006 ជាភាសាខ្មែរ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញ!

**សួរដោយលោក សំ សុគង់៖**

**ស៖** លោកអ៊ំ ឡុង នរិន្ទ លោកអ៊ំឮទេលោកអ៊ំ?

**លោក ឡុង នរិន្ទ៖**

**ឆ៖** បាទ។

**ស៖** ខ្ញុំសូមអានកំណត់ហេតុលោកអ៊ំដែលបានឆ្លើយជាមួយនឹងសហចៅក្រមស៊ើបសួរ នៅត្រង់ទំព័រទីពីរហ្នឹង លោកអ៊ំបានឆ្លើយថា អៀង សារី នាំចូលបដិវត្តន៍ នៅខែ៩ ឆ្នាំ៧២ ក្រោយមកទើបធ្វើការនៅហាណូយ បម្រើវិទ្យុមួយ អៀង ធីរិទ្ធ បានរយៈពេលមួយឆ្នាំ។ ឆ្នាំ៧៣ បានមកស្រុកខ្មែរនៅស្ទឹងត្រង់ខេត្តកំពង់ចាម ហៅថា B២០ ជាមន្ទីររបស់មជ្ឈិម គឺតំណាងឲ្យមន្ទីរក្រសួងការបរទេស។ ជាកន្លែងទទួលភ្ញៀវដែលមកពីភូមិភាគផ្សេងៗមករៀនសូត្រ តែ ប៉ុល ពត ច្រើនតែមកជួបនៅក្នុងព្រៃ

ជាសម្ងាត់។

តើនៅក្នុង B២០ ប២០ ហ្នឹង ប៉ុល ពត ធ្លាប់ទៅទីនោះដែរទេលោកអ៊ំ?

**ឆ៖** សួរថា អង្គាល់ហ្នឹងធ្លាប់ទៅណាអំមិញ?

**លោក ញ៉ែម សំណាង៖**

សួរថា តើនៅ ប២០ ប៉ុល ពត ធ្លាប់ទៅទីនោះដែរទេ?

**ឆ៖** អត់ទេ។ មិនសួរទេ។

**ស៖** លោកអ៊ំថា មិនសួរហ្នឹង បានថា-- ចង់សួរថាគាត់ធ្លាប់ដែលទៅទេ?

**ឆ៖** ដូចមិនដែលធ្លាប់ទេ ហើយមែនទែនទៅ ខ្ញុំមិនដឹងគាត់នៅមន្ទីរត្រង់ណាផង ប៉ុន្តែនៅមន្ទីរក្នុងព្រៃហ្នឹងដែរ។ ក្នុងព្រៃទៅម្ខាងនោះទៀត។

[១៥:៣៧:៤២]

**ស៖** សំណួរមួយទៀត ទាក់ទងនឹងការដែលគេចាត់តាំងលោកអ៊ំទៅព្រះវិហារ លោកអ៊ំបានឆ្លើយពីម្សិលមិញថា មានលោក នួន ជា ហើយនិងលោក ខៀវ សំផន បានជួបជាមួយលោកអ៊ំមុនលោកអ៊ំចេញទៅព្រះវិហារហ្នឹង។ នៅពេលដែលលោកអ៊ំជួបជាមួយលោក នួន ជា និង ខៀវ សំផន តើលោក នួន ជា ហើយនិងលោក ខៀង សំផន ហ្នឹងគាត់បានណែនាំលោកអ៊ំអ្វីខ្លះ មុនលោកអ៊ំចេញទៅព្រះវិហារហ្នឹង ជាមួយសមាជិកប្រាំនាក់ទៀតនោះ?

**ឆ៖** មុនទៅហ្នឹងគឺថាគាត់ គឺថាឲ្យទៅរៀនសូត្រពីប្រជាជន ឲ្យស្ដាប់សំណូមពរប្រជាជន។ សួរគាត់ថា ឯករាជ្យទៅតើគាត់ចង់បានអី? អ៊ីចឹង ហើយឲ្យចាំទូរលេខពីមជ្ឈិមទៅសឹមមកតាមហ្នឹង។ បើអត់ទេ គឺកុំអាលមក កុំអាលជ្រួលច្រាល់។

[១៥:៣៨:៥២]

**ស៖** នៅពេលដែលលោកអ៊ំទៅដល់ព្រះវិហារ តើលោកអ៊ំបានស្នាក់នៅព្រះវិហារប៉ុន្មានថ្ងៃដែរលោកអ៊ំ?

**ឆ៖** ស្នាក់នៅយូរដែរ ដូចជិតមួយឆ្នាំមិនដឹង អង្គាល់ហ្នឹង។

**ស៖** នៅពេលដែលលោកអ៊ំស្នាក់នៅៗព្រះវិហារហ្នឹង តើលោកអ៊ំបានបង្រៀន បានធ្វើអីខ្លះនៅក្នុងខេត្តព្រះវិហារហ្នឹង តើនៅពេលដែលលោកអ៊ំទៅក្ដាប់ហ្នឹង តើយើងក្ដាប់ទៅលើកម្មាភិបាលនៅព្រះវិហារ ឬក៏ទៅប្រជាពលរដ្ឋនៅព្រះវិហារហ្នឹង?

[១៥:៣៩:៣០]

**ឆ៖** អង្គាល់ស្នាក់នៅព្រះវិហារហ្នឹងឃើញថា ប្រជាជនយើងគាត់-- អង្គាល់ហ្នឹងដូចជាអត់មានត្រូវការអីឲ្យនេះទេ គឺគាត់ត្រូវតែអំបិលហើយថ្នាំពេទ្យ។ ហើយបើអ៊ីៗខាងដឹកនាំត្រូវការអង្ករ ឲ្យទៅដឹកចុះ ហ្នឹងតាមដែលប្រជាជនគាត់ផ្ដាំមកតាមខ្ញុំ។ ព្រោះខ្ញុំសួរគាត់ពីរឿង គាត់ត្រូវការអីហ្នឹង រួចទៅគាត់ឆ្លើយថា គាត់ត្រូវការអ៊ីចឹង ថ្នាំពេទ្យ ហើយនិងអំបិល។

**ស៖** នៅពេលដែលលោកអ៊ំជួបប្រជាពលរដ្ឋនៅខេត្តព្រះវិហារហ្នឹង តើលោកអ៊ំអាចប្រាប់បានទេ របៀបដែលលោកអ៊ំប្រជុំជាមួយប្រជាពលរដ្ឋហ្នឹង លោកអ៊ំរៀបចំប្រជុំរបៀបម៉េចដើម្បីសួរពីសំណូមពររបស់គាត់ហ្នឹង? លោកអ៊ំបានឮទេលោកអ៊ំ?

**ឆ៖** បាទ ឮ។ មែនទែនដែលជួបនឹងប្រជាជនហ្នឹងគឺថា ខ្ញុំគ្រាន់តែជម្រាបកម្មាភិបាលដែលទទួលខុសត្រូវនៅព្រះវិហារហ្នឹងថា អ៊ីៗផ្ដាំផ្ញើអ៊ីចឹងឲ្យខ្ញុំសួរអ៊ីចឹង ហើយគេរៀបចំប្រជុំប្រជាជនទៅ ហើយខ្ញុំប្រជុំនៅ-- ខ្ញុំជួបជាមួយនឹងប្រជាជនហ្នឹងនៅចំពោះមុខកម្មាភិបាលរបស់ព្រះវិហារហ្នឹង ហើយសួរគាត់អីក៏អ៊ីចឹងដែរ សួរនៅចំពោះមុខប្រជាជនហ្នឹង ហើយចំពោះមុខកម្មាភិបាលហ្នឹង។ ដល់បានទៅខ្ញុំយកមកវិញ ខ្ញុំជម្រាបមកដល់ ប-២០ វិញ ខ្ញុំជម្រាបទៅថ្នាក់លើ ហើយមិនដឹងជាបញ្ហាហ្នឹងវាទៅយ៉ាងម៉េចទៅវិញ ខ្ញុំអត់ដឹងទេ។ តើបានផ្ញើអំបិល និងថ្នាំពេទ្យទៅគាត់អត់ទេ។

[១៥:៤២:២៧]

**ស៖** ឮទេលោកអ៊ំ? អាឡូ! ប្រហែលជាអត់ឮ!

**ប្រធានអង្គជំនុំ៖**

បែបមានបញ្ហារអាក់រអួលផ្នែកខាងបច្ចេកទេសកំពុងតែពិនិត្យដោះស្រាយ។

[១៥:៤៥:០០]

*(មានបញ្ហាផ្នែកបច្ចេកទេស ប្រព័ន្ធសោតទស្សន៍មិនដំណើរការ)*

[១៥:៤៧:៥៧]

**ប្រធានអង្គជំនុំ៖**

ម៉េចទៅ សំណាង អាចចាប់ផ្ដើមដំណើរការបានទេ?

**លោក ញ៉ែម សំណាង៖**

បាទ, បានលោកប្រធាន ឥឡូវឃើញច្បាស់ហើយ។

**ប្រធានអង្គជំនុំ៖**

បាទៗអរគុណ។ សូមអញ្ជើញលោកមេធាវីបន្តសំណួរ។

**សួរដោយលោក សំ សុគង់៖**

**ស៖** ជម្រាបសួរលោកអ៊ំម្ដងទៀត។ នៅពេលដែលមានកិច្ចប្រជុំនៅខេត្តព្រះវិហារ ដែលលោកអ៊ំបានមានប្រសាសន៍ពីខាងលើថា កម្មាភិបាលគាត់ជាអ្នកប្រមូលប្រជាជនមកប្រជុំ ហើយនៅពេលនោះលោកអ៊ំមានវត្តមាននៅក្នុងអង្គប្រជុំដែរនោះ។ តើលោកអ៊ំមានបានឮទេថា កម្មាភិបាលហ្នឹងគេនិយាយអ្វីខ្លះជាមួយប្រជាពលរដ្ឋនៅខេត្តព្រះវិហារហ្នឹងលោកអ៊ំ?

**ឆ៖** អង្កាល់ហ្នឹងគឺថា កម្មាភិបាលហ្នឹងគេលើកពីបញ្ហាដែលខ្ញុំចង់ដឹង ថាតើសំណូមពររបស់ប្រជាជននៅពេលឯករាជ្យតើចង់បានអី? ហើយប្រជាជនមានបញ្ហាអីដែលត្រូវលើកទៅអ៊ំៗវិញ ខ្ញុំនាំយកទៅ ប៉ុណ្ណឹង។

[១៥:៤៩:២៨]

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំ។ ខ្ញុំសូមសួរ យើងត្រឡប់ទៅក្រោយបន្តិច ពីខាងលើលោកអ៊ំថា នៅពេលដែលចូលរួមនៅក្នុងប៉េកាំងហ្នឹងលោកអ៊ំថា មាននិស្សិតមកពីប្រទេសជាច្រើន ដូចជាបារាំង ឆេកូស្លូវ៉ាគី និងប្រទេសមួយចំនួនទៀត តើនៅពេលដែលមាននិស្សិតមកពីប្រទេសជាច្រើនអីចឹង តើវាមានចលនាប្រមូលផ្តុំនិស្សិតចូលរួមក្នុងបដិវត្តន៍ដែរឬទេលោកអ៊ំ?

[១៥:៥០:០៣]

**ឆ៖** អត់ឃើញទេ គឺថាអង្កាល់ហ្នឹងមកហើយ គេឲ្យចូលទៅធ្វើការនៅក្នុងក្រសួងការបរទេសហ្នឹងទៅ។ ហើយក៏ចូលទៅធ្វើការទៅ ម្នាក់ៗធ្វើទៅតាមដែលកម្មាភិបាលនៅក្នុងក្រសួងហ្នឹងចែកឲ្យធ្វើ។

**ស៖** មុនដែលនិស្សិតគាត់សម្រេចចិត្តចូលទៅ ចូលរួមនៅក្នុងចលនាបដិវត្តន៍ ក៏ដូចជានិស្សិតគាត់សម្រេចចិត្តមកប៉េកាំងហ្នឹង តើវាមានចលនាអំពាវនាវឲ្យចូលរួមដែរឬទេ? ឬមួយក៏អត់ទេលោកអ៊ំ?

**ឆ៖** មែនទែនទៅ គឺថានិស្សិតហ្នឹងមក ព្រោះថាអង្កាល់នៅឯក្រៅហ្នឹង គឺថានៅបរទេសហ្នឹងនិស្សិតមានសមាគមរបស់ខ្លួន។ ប្រធានអីគេៗរៀបចំជូនឡើងកប៉ាល់ហោះអីអីចឹងមក មកៗ។ ដូចខ្ញុំគឺខ្ញុំមកតាមរថភ្លើងមករហូតមកដល់ប៉េកាំងទៅ។

**លោក សំ សុគង់៖**

បាទ, ជម្រាបលោកប្រធានថា ដោយសារខ្ញុំអស់សំណួរហើយ។ ហើយសូមអរគុណលោកអ៊ំ ឡុង នរិន្ទ ហើយខ្ញុំទុកឱកាសនេះជូនទៅសហមេធាវីអន្តរជាតិរបស់ខ្ញុំ ដើម្បីសួរសំណួរបន្ត។

បាទ, សូមអរគុណ។

[១៥:៥១:៤០]

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណ។ សូមអញ្ជើញសហមេធាវីអន្តរជាតិដើមបណ្តឹងរដ្ឋប្បវេណី។ សូមអញ្ជើញ!

**សួរដោយលោកស្រី ឆ្វុីន សាកាវ៉ាទី៖**

សូមអរគុណលោកប្រធាន ខ្ញុំសូមអនុញ្ញាតសូមអង្គុយលោកប្រធានក្នុងពេល ដែលខ្ញុំធ្វើការពិនិត្យដេញដោលទៅលើសាក្សី។

**ស៖** សូមសួស្តីលោកអ៊ំ ឡុង នរិន្ទ។ ខ្ញុំចង់សួរថា នៅពេលដែលលោកអ៊ំនិយាយអំពី អៀង សារី ថាជាប្រធាននៅ ប-១។ អ៊ីចឹងថាតើមានអ្នកណាគេផ្សេងក្រៅពី អៀង សារី អាចចេញបញ្ជាបានដែរឬទេ? ប្រសិនបើមិនមានការឯកភាពពីលោក អៀង សារី នោះ។ តើចង់ឲ្យខ្ញុំសួរសំណួរនេះឡើងវិញ ឬក៏យ៉ាងម៉េចលោកអ៊ំ ឡុង នរិន្ទ?

[១៥:៥២:៣៨]

**លោក ឡុង នរិន្ទ៖**

**ឆ៖** បាទ មែនទែនទៅខ្ញុំអត់ដឹងទេ រឿង--។

**ស៖** ថាតើមាននរណាគេនៅ ប-១ អាចចេញបញ្ជាបានឬទេ ប្រសិនបើមិនមានការឯកភាពយល់ព្រមពី អៀង សារី? លោកអ៊ំ ឡុង នរិន្ទ តើស្តាប់ខ្ញុំឮដែរឬទេ?

**ឆ៖** បាទ ឮ! ប៉ុន្តែខ្ញុំអត់ដឹងរឿងហ្នឹង មិនដឹងជាខាង អាហ្នឹងគឺទាល់ថ្នាក់អ៊ំៗបានដឹងអារឿងហ្នឹង។

**ស៖** ការពីម្សិលមិញលោកអ៊ំបាននិយាយអំពី សុង សុឃឿន (ស៊ីក) ហើយលោកអ៊ំនិយាយថាគាត់ជាប្រធាននៅក្រុមរបស់លោកអ៊ំ។ ថាតើប្រធានក្រុមរបស់អ៊ំនៅ ប-១ ហ្នឹងគឺជាអ្វីដែលប្រធានក្រុមហ្នឹង?

[១៥:៥៣:៥៤]

**ឆ៖** ប្រធានក្រុមហ្នឹង គឺលោក សួង ស៊ីគឿន។

**ស៖** ថាតើលោក សួង ស៊ីគឿន ហ្នឹងមានទំនាក់ទំនងយ៉ាងម៉េចជាមួយនឹងលោក អៀង សារី? តើលោក សួង ស៊ីគឿន ហ្នឹងគឺជាបុគ្គលិកកម្មាភិបាលក្រោមលោក អៀង សារី ឬក៏យ៉ាងម៉េច?

**ឆ៖** គាត់មែនទែនទៅ គាត់ជាសមាជិកសមាគមន៍សហភាពនិស្សិតនៅប៉ារីស។

[១៥:៥៥:00]

**ស៖** ក្នុងនាមជាប្រធានក្រុមនៅ ប-១ ថាតើលោកនុ៎ងគាត់មានទទួលបញ្ជាផ្ទាល់ពីលោក អៀង សារី ដែរឬទេ?

**ឆ៖** អាហ្នឹង ក៏ខ្ញុំមិនដឹងដែរ ពីព្រោះពេលគាត់ប្រជុំជាមួយនឹងលោក អៀង សារី គឺថាគាត់ទៅប្រជុំទៅ ពួកប្រធានផ្នែកហ្នឹងទៅប្រជុំទៅ ហើយមានការសម្រេចអី ខ្ញុំមិនដឹងទេ។

**ស៖** ដោយសារតែ អៀង សារី គឺជាប្រធាន ប-១ ដូច្នេះ បានន័យថា លោក អៀង សារី នេះគឺជាមេរបស់លោក សួង ស៊ីគឿន ដែរ។ តើមែនដែរឬទេ?

**លោក ញ៉ែម សំណាង៖**

អ៊ំនិយាយទៅ។ សូមតាំងសំណួរម្តងទៀត។

**ស៖** ថាតើលោក អៀង សារី គឺជាមេផ្ទាល់របស់ សួង ស៊ីគឿន ដែរ នៅ ប-១ តើមែនដែរឬទេ?

**ឆ៖** មែនទែនទៅ គាត់ជាប្រធាន ប-១ ហ្នឹង គឺថាមេលើ សួង ស៊ីគឿន មេលើខ្ញុំ មេលើទូតនៅបរទេសអីអ៊ីចឹង។

[១៥:៥៦:៥៤]

**ស៖** ដូច្នេះ នៅពេលដែល សួង ស៊ីគឿន សុំឲ្យលោកសរសេរប្រវត្តិរូប ថាតើលោក សួង ស៊ីគឿន នេះ ឲ្យលោកសរសេរហ្នឹង គឺគាត់បញ្ជាទៅលោកដោយផ្ទាល់ ឬក៏គាត់ទទួលបញ្ជាពីគេដែរ ដើម្បីឲ្យលោកហ្នឹងអាចសរសេរបាន?

**ឆ៖** មែនទែនទៅ គាត់ទទួលបញ្ជាពីលោក អៀង សារី ឲ្យសរសេរប្រវត្តិរូបហ្នឹង។

**ស៖** សូមអរគុណច្រើន។ នៅពេលដែលលោក អៀង សារី ទៅបរទេសនោះ ថាតើលោក អៀង សារី មានដែលធ្វើយុទ្ធនាការអូសទាញនិស្សិតនៅទីនោះ នៅបរទេសដើម្បីឲ្យមកប្រទេសកម្ពុជាវិញដែរឬទេ?

[១៥:៥៧:៤៨]

**ឆ៖** អត់ទេ ខ្ញុំអត់ដឹងទេ។

**ស៖** តើលោកបានចាំដែរឬទេ នៅក្នុងចម្លើយឆ្នាំ២០០៧ ដែលលោកបានលើកឡើងថា អៀង សារី បានអូសទាញណែនាំនិស្សិតនៅបរទេសនោះ ឲ្យត្រឡប់មកប្រទេសកម្ពុជា។ លោកអ៊ំបាននិយាយហ្នឹង នៅក្នុងចម្លើយផ្តល់ជូនបុគ្គលិករបស់តុលាការនៅឆ្នាំ២០០៧។ ចាំទេចំណុចហ្នឹង?

លោក ឡុង នរិន្ទ តើលោកចាំទេ ថាលោកបាននិយាយថា នៅពេលដែលលោក អៀង សារី ទៅបរទេស គាត់បាននិយាយ-- ទៅបុលហ្គារី ហុងហ្គារី និងបុលហ្គារី ហើយណែនាំនិស្សិតនៅបរទេសថា ប្រទេសឯករាជ្យហើយ ដូច្នេះហើយសូមឲ្យវិលត្រឡប់មកប្រទេសកម្ពុជាវិញ។ តើលោកមានចាំថា បាននិយាយអ៊ីចឹងទេ នៅក្នុងចម្លើយប្រាប់ចៅក្រមហ្នឹង?

[១៥:៥៩:០២]

**ឆ៖** បាទ ខ្ញុំបានចាំ ប៉ុន្តែបែបនេះ ខ្ញុំចាំមិនចាំ។ អ៊ីចឹងគឺថាមួយពាក្យពីរពាក្យ មួយពាក្យទៅមួយពាក្យៗ គឺគាត់ណែនាំថាប្រទេសឯករាជ្យហើយ គឺពួកមិត្តសុទ្ធតែស្នេហាជាតិ សុំវិលត្រឡប់ទៅប្រទេសជាតិវិញ ដើម្បីយើងរួមគ្នាកសាងប្រទេសជាតិឲ្យបានរុងរឿងដូចគេ។

**ស៖** ថាតើនិស្សិតនៅបរទេសហ្នឹង មានត្រឡប់មក ប-១ វិញដែរឬទេ នៅពេលដែលលោកអ៊ំធ្វើការនៅ ប-១ ហ្នឹង?

[១៦:០០:០០]

**ឆ៖** មានខ្លះ ក៏ចូល ប-១ ខ្លះទៅផ្នែកផ្សេងៗទៀត ពីព្រោះអ្នកដែលទៅបរទេសហ្នឹង គឺទៅរៀន អ្នកខ្លះទៅរៀនតិចនិចផ្សេងៗ។

**ស៖** តើនិស្សិតទាំងអស់នោះវិលត្រឡប់មកប្រទេសកម្ពុជាវិញក្រោយពីលោក អៀង សារី ធ្វើយុទ្ធនាការអូសទាញនិស្សិតទាំងអស់នោះមកប្រទេសកម្ពុជាវិញ តើមែនដែរឬទេ?

**ឆ៖** មែនទែននិស្សិតទាំងអស់នុ៎ង ក៏សុទ្ធតែជាអ្នកស្នេហាជាតិដល់គាត់និយាយអ៊ីចឹងទៅ គេក៏វិលត្រឡប់មកប្រទេសវិញមក ប៉ុន្តែក៏មកឆ្លងកាត់តាមប៉េងកាំង អ៊ីចឹងមករហូតមក។ ជួនកាលអ្នកខ្លះមកជួយធ្វើការនៅប៉េកាំង មួយរយៈទៅ ហើយបានត្រឡប់មកចូលកម្ពុជា។

**ស៖** ថាតើនិស្សិតទាំងអស់នោះនៅបឹងត្របែក បានមកដល់បឹងត្របែកដែរ ឬទេ? ហើយបានមកដល់ច្រាំងចំរេះដែរឬទេ?

**ឆ៖** ដឹងខ្ញុំមិនដឹងច្បាស់ទេ។ ប៉ុន្តែខ្ញុំដឹងថា មានមកនៅបឹងត្របែក មានមកនៅមកធ្វើការនៅច្រាំងចំរេះហ្នឹង។

[១៦:០១:៤៥]

**សៈ** ថាតើលោកបានចូលរួមប្រជុំជាមួយនឹងលោក អៀង សារី ហើយមាននិស្សិតដែលមកវិញហ្នឹង គាត់លើកឡើងថា គាត់មកពីច្រាំងចំរេះ និងបឹងត្របែកដែរឬទេ?

**ឆ៖** (ឮមិនច្បាស់) ពួកហ្នឹង ខ្ញុំមិនដឹង។

**សៈ** តើលោកបានចាំថា បាននិយាយនៅក្នុងចម្លើយក្នុង២០០៧ នៅពេលដែលគេសួរលោកថា “ថាតើលោកបានចូលរួមប្រជុំជាមួយនឹង អៀង សារី ដែរ ឬទេ? លោកឆ្លើយថា លោកបានចូលរួមប្រជុំជាមួយនឹង អៀង សារី ដែលគេនិយាយអំពីមាគ៌ានយោបាយ ដែលក្នុងនោះមានការចូលរួមពីកសិករ កម្មករ និងបញ្ញវន្ត” តើលោកចាំថា ធ្លាប់បានចូលរួមជាមួយនឹងអ្នកដែលវិលត្រឡប់មកពីបរទេសទាំងអស់នោះដែរ ឬទេ?

**ឆ៖** ខ្ញុំមិនចាំទេ។

**សៈ** តើលោកបានចាំថា ធ្លាប់ចូលរួមជាមួយនឹង អៀង សារី ដែរ ឬទេ? ដែលនៅពេលប្រជុំហ្នឹង គេបានអប់រំពីគោលនយោបាយនៃបក្សកុម្មុយនីស្តកម្ពុជា?

**ឆ៖** ដែល។

[១៦:០៣:១៨]

**សៈ** ថាតើនៅពេលប្រជុំនោះគេបានលើកឡើងអ្វីខ្លះ? ហើយ អៀង សារី បាននិយាយអ្វីខ្លះដើម្បីធ្វើការអប់រំកម្មាភិបាលដែលបានចូលរួមប្រជុំនៅពេលនោះ?

**ឆ៖** មែនទែនទៅអប់រំពីរឿងបញ្ហានយោបាយ គឺរឿងបង្កបង្កើនផល ឲ្យម្ចាស់ការ ហើយឯករាជ្យ។

**សៈ** ថាតើនិស្សិតដែលវិលត្រឡប់មកពីបរទេសវិញនោះ មានបានបាត់ខ្លួនដែរឬទេ តាមដែលអ៊ំដឹង?

**ឆ៖** មាន។

**សៈ** ថាតើបាត់ខ្លួនប៉ុន្មាននាក់ដែរ? ហើយមានចាំឈ្មោះទេ ឈ្មោះអ្នកដែលបាត់ខ្លួនហ្នឹង តើបាត់ខ្លួនប៉ុន្មាននាក់ដែរ?

**ឆ៖** ខ្ញុំមិនដឹងទេ។

**ស៖** ថាតើលោកអ៊ំដឹងទេ ថានិស្សិតដែលវិលត្រឡប់មកប្រទេសកម្ពុជាវិញនោះ គឺត្រូវសរសេរប្រវត្តិរូបដែរ?

**ឆ៖** មានវិលត្រឡប់ទៅក្រៅវិញ គឺថាទៅធ្វើទូតនៅ-- ទៅចូលរួមធ្វើទូត មិនធ្វើទូតទេ ធ្វើបុគ្គលិកទូត។

[១៦:០៤:៥៥]

**ស៖** នៅពេលដែលនិស្សិតទាំងអស់នោះ វិលត្រឡប់មកប្រទេសកម្ពុជាវិញ តើគេមានបង្ខំឲ្យពួកគាត់ហ្នឹងសរសេរប្រវត្តិរូបដែរ ឬទេ? លោកអ៊ំ ឡុង នរិន្ទ តើស្ដាប់ខ្ញុំឮដែរឬទេ?

លោក ប្រធាន លោកលោកស្រីចៅក្រម ប្រហែលជាមានបញ្ហាបច្ចេកទេសខាងបច្ចេកទេសទើបអត់បានទំនាក់ទំនងដូច្នេះ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការទាក់ទងទៅខាងអ្នកបច្ចេកទេស។

**លោកស្រី នូស៊ីន សាកាវ៉ាទី៖**

លោកចៅក្រម ថាតើខ្ញុំសូមអនុញ្ញាតសូមថែមរយៈពេលដប់នាទីបន្ថែមទៀត ដើម្បីអនុញ្ញាតឲ្យខ្ញុំសួរបន្ថែមដោយសារតែវាមានបញ្ហាបច្ចេកទេសកាត់ផ្ដាច់ទៅលើការទំនាក់ទំនង។

លោកប្រធាន!

[១៦:០៦:៥៧]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតដល់មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីអាចសួរសាក្សីរូបនេះ ដប់មីនុតទៀត ប៉ុន្តែមិនអាចដំណើរការបានថ្ងៃនេះទេ គឺធ្វើនៅព្រឹកថ្ងៃស្អែក ដោយមូលហេតុនៅឯនោះ ដាច់ចរន្តអគ្គិសនីអស់ហើយ មិនអាចដំណើរការបានទេ។

ឥឡូវនេះកិច្ចដំណើរការសវនាការដេញដោលស្ដាប់សក្ខីកម្មសាក្សីសម្រាប់ថ្ងៃនេះ សមល្មមដល់ពេលត្រូវឈប់សម្រាកហើយ។ ដូច្នេះសវនាការសម្រាប់ថ្ងៃនេះ ត្រូវផ្អាកត្រឹមនេះសិន។ សវនាការនឹងលើកបន្តទៅធ្វើនៅថ្ងៃស្អែក ថ្ងៃសុក្រ ទី០៩ ខែធ្នូ ឆ្នាំ២០១១ ដោយចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹកតទៅ។ សូមភាគីសាធារណជនជ្រាបនិងសូមអញ្ជើញចូលរួមក្នុងដំណើរសវនាការឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

អនុរក្សមន្ទីរឃុំឃាំងឲ្យនាំជនជាប់ចោទទាំងបីរូបត្រឡប់ទៅមន្ទីរឃុំឃាំងវិញចុះ ហើយឲ្យនាំខ្លួនគាត់មកកាន់បន្ទប់សវនាការនៅព្រឹកថ្ងៃស្អែកឲ្យមុនម៉ោងប្រាំបួនជាកំណត់។

សូមអញ្ជើញសម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង១៦:០៨នាទី)*